# ថ្ងៃទី០២ ខែ វិច្ឆិកា ឆ្នាំ២០២០

## ប្រជាពលរដ្ឋខ្មែរ ចំនួន ៣៧នាក់លួចឆ្លងដែនទៅថៃ ត្រូវ កម្លាំងប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិភ្នំដី ឃាត់ខ្លួន អប់រំណែនាំឲ្យបញ្ឈប់ការធ្វើសកម្មភាពបែបនេះទៀត

https://www.cen.com.kh/ November 1, 2020

ព្រំដែនអន្តរជាតិភ្នំដី ៖ នៅថ្ងៃទី១ ខែវិច្ឆិកា ឆ្នាំ២០២០ វេលាម៉ោង ១២និង០០នាទី កម្លាំងប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិភ្នំដី បានធ្វើការល្បាតតាមរបៀងស្លាបឆ្វេង និងស្លាបស្តាំ ក្នុងវង្វង់ប្រតិបត្តិការណ៍របស់ប៉ុស្តិ៍ ដើម្បីទប់ស្កាត់ប្រជាពលរដ្ឋ កុំឲ្យធ្វើការឆ្លងដែនតាមរបៀង។ បន្ទាប់មកកម្លាំងប៉ុស្តិ៍ ក៏បានប្រទះឃើញប្រជាពលរដ្ឋខ្មែរ ចំនួន ៣៧នាក់ ស្រី ១៧នាក់ ក្នុងនោះកុមារ ០៥នាក់ ជាប្រជាពលរដ្ឋរស់នៅក្នុងមូលដ្ឋានស្រុកសំពៅលូន ដែលខ្លះជាអ្នកស៊ីឈ្នួលលើកសម្ភារៈ និងខ្លះទៀតជាអាជីវករ បានធ្វើការឆ្លងដែនចេញទៅផ្សារ បានខៅឌីន (ផ្សារជាប់ព្រំដែន) ស្រុកខ្លងហាត ខេត្តស្រះកែវ ប្រទេសថៃ តាមរបៀង (ស្លាបឆ្វេង និងស្លាបស្តាំ) របស់ប៉ុស្តិ៍។ ក្រោយមកកម្លាំងនគរបាលប៉ុស្តិ៍ បានធ្វើការអប់រំណែនាំ ដល់ប្រជាពលរដ្ឋទាំងអស់ខាងលើ ឲ្យបញ្ឈប់ការធ្វើសកម្មភាពបែបនេះទៀត និងបានអនុញ្ញាតឲ្យពួកគាត់ត្រលប់ទៅផ្ទះវិញរៀងៗខ្លួន៕ **ដោយៈបញ្ញាស័ក្តិ**

## ឯកអគ្គរដ្ឋទូតសិង្ហបុរី ៖ សិង្ហបុរី អាចបង្កើតការងាររាប់ម៉ឺនកន្លែង ដល់កម្មករ ពលករកម្ពុជា នាពេលខាងមុខ

https://www.cen.com.kh/ October 30, 2020

រាជធានីភ្នំពេញ៖ ឯកអគ្គរដ្ឋទូតសិង្ហបុរី បានគូសបញ្ជាក់ប្រាប់ឯកឧត្តមរដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ អំពីលទ្ធភាពដែលអាចបង្កើតការងាររាប់ម៉ឺនកន្លែង ដល់កម្មករ ពលករកម្ពុជា នាពេលខាងមុខ ពេលដែលកិច្ចសហប្រតិបត្តិការរវាងសិង្ហបុរី និងកម្ពុជា ក្នុងការអនុវត្តគម្រោងទាំង៣ នៃការអភិវឌ្ឍទីក្រុងភ្នំពេញត្រូវបានបញ្ចប់។ ឯកឧត្តម Michael Tan Keng Siong ឯកអគ្គរដ្ឋទូតសិង្ហបុរីប្រចាំកម្ពុជា ដែលនឹងបញ្ចប់បេសកកម្មនាពេលខាងមុខនារសៀលថ្ងៃទី២៨ ខែតុលា ឆ្នាំ២០២០នេះ បានចូលជួបសម្តែងការគួរសម និងជម្រាបលា ឯកឧត្តម ព្រុំ សុខា រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ នៅទីស្តីការក្រសួង។ ក្នុងឱកាសនៃជំនួបនេះ ឯកឧត្តមឯកអគ្គរដ្ឋទូតសិង្ហបុរី និងឯកឧត្តមរដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈកម្ពុជា បានសម្តែងនូវក្តីសោមនស្សរីករាយ ចំពោះភាពល្អប្រសើរក្នុងរយៈពេលកន្លងមកនៃទំនាក់ទំនងទ្វេភាគី ក៏ដូចជាកិច្ចសហប្រតិបត្តិការក្នុងក្របខណ្ឌអាស៊ានរវាងកម្ពុជា និងសិង្ហបុរី។

ឯកឧត្តមរដ្ឋមន្ត្រី ព្រុំ សុខា បានលើកឡើងថា ក្នុងរយៈពេលបំពេញបេសកកម្មការទូតរបស់ ឯកឧត្តម Michael Tan Keng Siong នៅកម្ពុជាទំនាក់ទំនងសហប្រតិបត្តិការទ្វេភាគីរវាងកម្ពុជា និងសិង្ហបុរីលើការកសាងសមត្ថភាពធនធានមនុស្ស ក្នុងវិស័យមុខងារសាធារណៈត្រូវបានពង្រីកគួរឱ្យកត់សម្គាល់។ ជាក់ស្តែងកម្មវិធីផ្លាស់ប្តូរពិសោធន៍ការងារ ទស្សនកិច្ចសិក្សា វគ្គបណ្តុះបណ្តាលរយៈពេលខ្លី ដែលបានរៀបចំឡើងនៅកម្ពុជានិងនៅសិង្ហបុរី និងវគ្គហ្វឹកហ្វឺនដទៃទៀតដែលជាកម្មវិធីសហការរវាងសាលាភូមិន្ទរដ្ឋបាលកម្ពុជា (ERA) និងសាលាមុខងារសាធារណៈសិង្ហបុរី (Singapore Civil Service College) មានមន្ត្រីរាជការកម្ពុជាជាច្រើនរយនាក់បានចូលរួម។

ឯកឧត្តមឯកអគ្គរដ្ឋទូតសិង្ហបុរី Michael Tan Keng Siong បានគូសបញ្ជាក់អំពីលទ្ធភាពដែលអាចបង្កើតការងាររាប់ម៉ឺនកន្លែងដល់កម្មករ ពលករកម្ពុជានាពេលខាងមុខ ពេលដែលកិច្ចសហប្រតិបត្តិការរវាងសិង្ហបុរី និងកម្ពុជា ក្នុងការអនុវត្តគម្រោងទាំង៣ នៃការអភិវឌ្ឍទីក្រុងភ្នំពេញត្រូវបានបញ្ចប់ រួមមាន៖ គម្រោងគ្រប់គ្រងឡូជីស្ទីកភ្នំពេញ (Phnom Penh Logistics Complex Project) គម្រោងគ្រប់គ្រងសំរាម (Waste Management Project) និងគម្រោងបំប្លែងសំរាមទៅជាថាមពល (Waste to Energy Project)។

ចុងបញ្ចប់នៃជំនួបនេះ ឯកឧត្តមទាំងពីរបានប្តេជ្ញារួមគ្នា បន្តជំរុញទំនាក់ទំនងសហប្រតិបត្តិការទ្វេភាគីឱ្យកាន់តែល្អប្រសើរថែមទៀត ដើម្បីជាគុណប្រយោជន៍ដល់ចំណងមិត្តភាពរវាងរដ្ឋាភិបាល និងប្រជាជន នៃប្រទេសទាំងពីរកម្ពុជា សិង្ហបុរី។ **ដោយៈបញ្ញាស័ក្តិ**

## ប្រកាសដាក់ឲ្យដំណើរការក្រុមការងារ TASK FORCE របស់អគ្គស្នងការដ្ឋាននគរបាលជាតិ

http://freshnewsasia.com/ 2020-10-30 10:04pm

**(ភ្នំពេញ)៖** នាយឧត្តមសេនីយ៍ សន្តិបណ្ឌិត នេត សាវឿន អគ្គស្នងការនគរបាលជាតិ និងលោក Patrick Murphy ឯកអគ្គរដ្ឋទូតសហរដ្ឋអាមេរិកប្រចាំកម្ពុជា កាលពីរសៀលថ្ងៃទី២៧ ខែតុលា ២០២០ បានអញ្ជើញជួបសំណេះសំណាលជាមួយក្រុមការងារ សម្របសម្រួលកិច្ចសហប្រតិបត្តិការ (TASK FORCE GCNP-FBI) និងប្រកាសដាក់ដំណើរការការិយាល័យជាផ្លូវការ ដែលមានទីតាំងនៅអគ្គស្នងការដ្ឋាននគរបាលជាតិ។ គិតមកដល់ពេលនេះ នគរបាលជាតិកម្ពុជា មានការិយាល័យសម្របសម្រួលកិច្ចសហប្រតិបត្តិការ ជាមួយភាគីនគរបាលមិត្តបរទេសចំនួន ០៣ ហើយ រួមមាន ក្រុមប្រឆាំងបទល្មើសឆ្លងដែន (TCT) ជាមួយភាគីនគរបាលអូស្ត្រាលី AFP, ការិយាល័យសម្របសម្រួលកិច្ចសហប្រតិបត្តិការកម្ពុជា-ចិន និងក្រុមការងារ TASK FORCE GCNP-FBI នៅពេលនេះ។

ក្រុមការងារទាំង០៣ខាងលើ ត្រូវបាននាយឧត្តមសេនីយ៍ សន្តិបណ្ឌិត នេត សាវឿន អគ្គស្នងការនគរបាលជាតិ ប្រគល់ភារកិច្ចជូនឧត្តមសេនីយ៍ឯក ឌី វិជ្ជា អគ្គស្នងការរង ឲ្យទទួលដឹកនាំបញ្ជាបន្ថែមពីលើការងារដែលមានស្រាប់ គឺការងារដឹកនាំនាយកដ្ឋានកណ្តាលសន្តិសុខ និងការងារប្រឆាំងការសម្អាតប្រាក់។ ជារួមការិយាល័យសម្របសម្រួលកិច្ចសហប្រតិបត្តិការទាំង ០៣ ខាងលើ មានតួនាទីភារកិច្ចប្រហាក់ប្រហែលគ្នាគឺ ការពង្រឹងប្រសិទ្ធភាពកិច្ចសហការស៊ើបអង្កេត និងបង្ក្រាបជនល្មើសដែលប្រព្រឹត្តបទល្មើសជាអាទិ៍ អំពើភេរវកម្ម, ការជួញដូរ និងរត់ពន្ធមនុស្ស, ទេសចរណ៍ផ្លូវភេទ និងអំពើអនាចារកុមារ, ការជួញដូរគ្រឿងញៀនខុសច្បាប់, ការរត់ពន្ធអាវុធ, បទល្មើសសម្អាតប្រាក់, បើទល្មើសឧក្រិដ្ឋកម្មបច្ចេកវិទ្យា, ការតាមចាប់ជនល្មើសរត់គេចខ្លួន និងបទល្មើសផ្សេងៗទៀតតាមការឯកភាពគ្នារបស់ភាគីទាំងពីរ។

## លោក ព្រុំ សុខា ជួបសំណេះសំណាលជាមួយជនបង្គោលក្រុមការងារចំណាកស្រុកនៃភូមិទាំង១០៨ ក្នុងស្រុកបាភ្នំ ខេត្តព្រៃវែង

http://freshnewsasia.com/ 2020-10-31 08:19am

**(ព្រៃវែង)៖** លោក ព្រុំ សុខា រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ និងជាប្រធានក្រុមការងារស្រុកបាភ្នំ នារសៀលថ្ងៃទី៣០ ខែតុលា ឆ្នាំ២០២០ បានជួបសំណេះសំណាលជាមួយ ជនបង្គោលក្រុមការងារចំណាកស្រុកតាមភូមិនីមួយៗ ដែលតំណាងឲ្យបងប្អូនកម្មករ ពលករចំណាកស្រុក នៃភូមិទាំងអស់១០៨ ក្នុងស្រុកបាភ្នំ។ ពិធីនេះបានប្រព្រឹត្តទៅនៅទីស្នាក់ការគណបក្សប្រជាជនកម្ពុជាស្រុកបាភ្នំ ដោយមានការចូលរួមពីសំណាក់លោកស្រីអស់លោក អ្នកតំណាងរាស្ត្រ ថ្នាក់ដឹកនាំក្រសួង មន្ទីរ អង្គភាពនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិដែលជាអនុប្រធានជាសមាជិកក្រុមការងារស្រុក ប្រធានក្រុមប្រឹក្សា និងអភិបាលស្រុក មេឃុំ មេភូមិទាំងអស់ សរុបចំនួនប្រមាណជាង ៣០០នាក់។

ផ្អែកតាមរបាយការណ៍របស់លោក ទេព ភារុន អភិបាលស្រុកបាភ្នំ មកដល់បច្ចុប្បន្ន ក្នុងស្រុកបាភ្នំទាំងមូលមានកម្មករ ពលករចំណាកស្រុក ចំនួន២៥,៣១៣នាក់ ដែលកំពុងធ្វើការនៅតាមរោងចក្រ សហគ្រាស អង្គភាព

អាជីវកម្ម ការដ្ឋានសំណង់ឯកជន និងសេវាផ្នែកសេដ្ឋកិច្ចក្រៅប្រព័ន្ធ នៅរាជធានីភ្នំពេញ ទីប្រជុំជននានាក្នុងប្រទេស ក្នុងនោះ ២៩៥នាក់ជាកម្មករ ពលករចំណាកស្រុកក្រៅប្រទេស។

ខ្លឹមសារមតិសំណេះសំណាលរបស់ លោករដ្ឋមន្ត្រី ព្រុំ សុខា នាពេលនោះផ្ដោតជាសំខាន់លើ ការកសាងបណ្ដាញទំនាក់ទំនងផ្សាភ្ជាប់ជាប្រចាំរវាង ក្រុមការងារជាមួយកម្មករ ពលករចំណាកស្រុក សំដៅលើកកម្ពស់ស្មារតីសាមគ្គីភាពបំពេញការងារ ពុះពារការលំបាកជាបញ្ហាប្រឈមនានា រួមគ្នាប្រយុទ្ធឈ្នះកូវីដ-១៩ ដើម្បីបុព្វហេតុសុខសន្តិភាព និងការអភិវឌ្ឍរបស់មាតុភូមិ។ នៅចុងបញ្ចប់មានការរៀបចំហូបបាយសាមគ្គីមួយ ដើម្បីអបអរសាទរពិធីបុណ្យជាតិអុំទូក អកអំបុក សំពះព្រះខែផងដែរ៕

## ប៉ុស្ដិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិប៉ោយប៉ែត បានទទួលពលករខ្មែរឆ្លងដែនខុសច្បាប់ ដែលអាជ្ញាធរថៃបញ្ជូនមក ចំនួន ០៩នាក់

https://www.facebook.com/GDIOfficial 01-11-2020

ប៉ុស្ដិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិប៉ោយប៉ែត នាវេលាម៉ោង ១៦និង១៥នាទី ថ្ងៃទី៣១ ខែតុលា ឆ្នាំ២០២០ បានទទួលពលករខ្មែរ ឆ្លងដែនខុសច្បាប់ ដែលអាជ្ញាធរថៃបញ្ជូនមក មានចំនួន ០៩នាក់ ស្រី ០៥នាក់។ ចំពោះពលករខាងលើ ត្រូវបានកម្លាំងនគរបាលប៉ុស្ដិ៍ ធ្វើការអប់រំណែនាំ បន្ទាប់មកប្រគល់ជូនក្រុមការងារ ទទួលពលករមេដ្ឋមណ្ឌលសំចតប៉ោយប៉ែត ដើម្បីធ្វើការបន្ត។ ជាមួយគ្នានេះដែរ អាជ្ញាធរថៃនៅតែបន្តបិទច្រកទ្វារព្រំដែនមិនទាន់បើកឱ្យអ្នកដំណើរចេញ-ចូលឆ្លងកាត់នៅឡើយ ចំពោះអ្នកជំងឺសង្គ្រោះបន្ទាន់ និងរថយន្តដឹកទំនិញធន់ធំដំណើរការជាធម្មតា៕

## ពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ១៤៥នាក់

https://www.facebook.com/GDIOfficial 01-11-2020

នៅថ្ងៃទី១ ខែវិច្ឆិកា ឆ្នាំ២០២០ វេលាម៉ោង ១៥និង០០នាទី ភាគីថៃនៅតែបន្តបិទច្រកទ្វារព្រំដែនអន្តរជាតិធង ចម ខេត្តសុរិន្ទ ទល់មុខច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ ជាបណ្ដោះអាសន្ន មិនអនុញ្ញាតឲ្យអ្នកដំណើរ គ្រប់សញ្ជាតិចេញ-ចូល ឆ្លងកាត់ ដើម្បីបង្ការ និងទប់ស្កាត់ការរាតត្បាតនៃជំងឺឆ្លង កូវីដ-១៩។ ក្នុងការបិទច្រកនេះ ភាគីថៃបានលើកលែង ទំនិញដែលទទួលបានការអនុញ្ញាត និងអ្នកបើកបររថយន្តដឹកទំនិញ ដែលទទួលបានការអនុញ្ញាត ព្រមទាំងបានការឆ្លងកាត់ត្រួតពិនិត្យ ដោយសមត្ថកិច្ចទាំងភាគី កម្ពុជា-ថៃ បានត្រឹមត្រូវ និងពលរដ្ឋខ្មែរ ឬពលរដ្ឋថៃ ដែលត្រូវវិលត្រឡប់ចូលប្រទេសរៀងៗខ្លួន។ ចំណែកឯពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ១៤៥នាក់ ស្រី ៦៥នាក់៕

## ពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ១១៥នាក់

https://www.facebook.com/GDIOfficial 31-10-2020

នៅថ្ងៃទី៣១ ខែតុលា ឆ្នាំ២០២០ វេលាម៉ោង ១៥និង០០នាទី ភាគីថៃនៅតែបន្តបិទច្រកទ្វារព្រំដែនអន្តរជាតិ ធង ចម ខេត្តសុរិន្ទ ទល់មុខច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ ជាបណ្ដោះអាសន្ន មិនអនុញ្ញាតឲ្យអ្នកដំណើរ គ្រប់សញ្ជាតិចេញ-ចូល ឆ្លងកាត់ ដើម្បីបង្ការនិងទប់ស្កាត់ការរាតត្បាតនៃជំងឺឆ្លងកូវីដ-១៩។ ក្នុងការបិទច្រកនេះ ភាគីថៃបានលើកលែង ទំនិញដែលទទួលបានការអនុញ្ញាត និងអ្នកបើកបររថយន្តដឹកទំនិញ

ដែលទទួលបានការអនុញ្ញាត ព្រមទាំងបានការឆ្លងកាត់ត្រួតពិនិត្យ ដោយសមត្ថកិច្ចទាំងភាគី កម្ពុជា-ថៃ បានត្រឹមត្រូវ និងពលរដ្ឋខ្មែរ ឬពលរដ្ឋថៃ ដែលត្រូវវិលត្រឡប់ចូលប្រទេសរៀងៗខ្លួន។ ចំណែកឯពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ១១៥នាក់ ស្រី ៦៥នាក់៕

## ពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ៨២នាក់

https://www.facebook.com/GDIOfficial 30-10-2020

នៅថ្ងៃទី៣០ ខែតុលា ឆ្នាំ២០២០ វេលាម៉ោង ១៥និង០០នាទី ភាគីថៃនៅតែបន្តបិទច្រកទ្វារព្រំដែនអន្តរជាតិ ឆង ចម ខេត្តសុរិន្ទ ទល់មុខច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ ជាបណ្ដោះអាសន្ន មិនអនុញ្ញាតឲ្យអ្នកដំណើរ គ្រប់សញ្ជាតិចេញ-ចូល ឆ្លងកាត់ ដើម្បីបង្ការនិងទប់ស្កាត់ការរាតត្បាតនៃជំងឺឆ្លងកូវីដ-១៩។ ក្នុងការបិទច្រកនេះ ភាគីថៃបានលើកលែង ទំនិញដែលទទួលបានការអនុញ្ញាត និងអ្នកបើកបររថយន្តដឹកទំនិញដែលទទួលបានការអនុញ្ញាត ព្រមទាំងបានការឆ្លងកាត់ត្រួតពិនិត្យ ដោយសមត្ថកិច្ចទាំងភាគី កម្ពុជា-ថៃ បានត្រឹមត្រូវ និងពលរដ្ឋខ្មែរ ឬពលរដ្ឋថៃ ដែលត្រូវវិលត្រឡប់ចូលប្រទេសរៀងៗខ្លួន។ ចំណែកឯពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ៨២នាក់ ស្រី ៤៨នាក់៕

## ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិប៉ោយប៉ែត បានទទួលពលករខ្មែរឆ្លងដែនខុសច្បាប់ ដែលអាជ្ញាធរថៃបញ្ជូនមក មានចំនួន ១៨នាក់

https://www.facebook.com/GDIOfficial 29-10-2020

ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិប៉ោយប៉ែត នាវេលាម៉ោង ១៩ និង០០នាទី ថ្ងៃទី២៨ ខែតុលា ឆ្នាំ២០២០ បានទទួលពលករខ្មែរ ឆ្លងដែនខុសច្បាប់ ដែលអាជ្ញាធរថៃបញ្ជូនមក មានចំនួន ១៨នាក់ ស្រី ០៦នាក់។ ចំពោះពលករខាងលើ ត្រូវបានកម្លាំងនគរបាលប៉ុស្តិ៍ ធ្វើការអប់រំណែនាំ បន្ទាប់មកប្រគល់ជូនក្រុមការងារ ទទួលពលករមជ្ឈមណ្ឌលសំចតប៉ោយប៉ែត ដើម្បីធ្វើការបន្ត។ ជាមួយគ្នានេះដែរ អាជ្ញាធរថៃនៅតែបន្តបិទច្រកទ្វារព្រំដែន មិនទាន់បើកឱ្យអ្នកដំណើរចេញ-ចូលឆ្លងកាត់នៅឡើយ ចំពោះអ្នកជំងឺសង្គ្រោះបន្ទាន់ និងរថយន្តដឹកទំនិញធន់ធំដំណើរការជាធម្មតា៕

## ពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ១០៦នាក់

https://www.facebook.com/GDIOfficial 29-10-2020

នៅថ្ងៃទី២៩ ខែតុលា ឆ្នាំ២០២០ វេលាម៉ោង ១៥និង០០នាទី ភាគីថៃនៅតែបន្តបិទច្រកទ្វារព្រំដែនអន្តរជាតិ ឆង ចម ខេត្តសុរិន្ទ ទល់មុខច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ ជាបណ្ដោះអាសន្ន មិនអនុញ្ញាតឲ្យអ្នកដំណើរ គ្រប់សញ្ជាតិចេញ-ចូល ឆ្លងកាត់ ដើម្បីបង្ការនិងទប់ស្កាត់ការរាតត្បាតនៃជំងឺឆ្លងកូវីដ-១៩។ ក្នុងការបិទច្រកនេះ ភាគីថៃបានលើកលែង ទំនិញដែលទទួលបានការអនុញ្ញាត និងអ្នកបើកបររថយន្តដឹកទំនិញដែលទទួលបានការអនុញ្ញាត ព្រមទាំងបានការឆ្លងកាត់ត្រួតពិនិត្យ ដោយសមត្ថកិច្ចទាំងភាគី កម្ពុជា-ថៃ បានត្រឹមត្រូវ និងពលរដ្ឋខ្មែរ ឬពលរដ្ឋថៃ ដែលត្រូវវិលត្រឡប់ចូលប្រទេសរៀងៗខ្លួន។ ចំណែកឯពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ១០៦នាក់ ស្រី ៤៥នាក់ និង

ពលរដ្ឋថៃដែលបានចាកចេញមានចំនួន ០៤នាក់ ស្រី ០២នាក់ ដោយមានឯកសារចេញពីស្ថានទូតថៃ និងលិខិតបញ្ជាក់សុខភាព៕

## ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិចាំយាម បានទទួលពលករខ្មែរចំនួន ០៦នាក់ ពីសមត្ថកិច្ចថៃ ពាក់ព័ន្ធនឹងករណីឆ្លងដែនខុសច្បាប់

https://www.facebook.com/GDIOfficial 29-10-2020

នៅថ្ងៃទី២៩ ខែតុលា ឆ្នាំ២០២០ ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិចាំយាម បានទទួលពលករខ្មែរចំនួន ០៦នាក់ ពីសមត្ថកិច្ចថៃ ពាក់ព័ន្ធនឹងករណីឆ្លងដែនខុសច្បាប់។ នគរបាលប៉ុស្តិ៍បានឲ្យដឹងថា ពលករខ្មែរទាំង ០៦នាក់នេះ មាន ១-ឈ្មោះ ធន បេះ ភេទស្រី អាយុ ៥២ឆ្នាំ, ២-ឈ្មោះ សេង ម៉ាប់ ភេទប្រុស អាយុ ៥៧ឆ្នាំ ភូមិចាំយាម ឃុំប៉ាក់ខ្លង ស្រុកមណ្ឌលសីម៉ា ខេត្តកោះកុង, ៣-ឈ្មោះ ផាន លំដួន ភេទប្រុស អាយុ ៣២ឆ្នាំ ភូមិព្រៃស្រឡៅ ឃុំអំពិលតាពក ស្រុកអូរាំងឪ ខេត្តកំពង់ចាម, ៤-ឈ្មោះ លី ឆយ ភេទប្រុស អាយុ ២៦ឆ្នាំ, ៥-ឈ្មោះ កៅ ភាព ភេទស្រី អាយុ ៣៨ឆ្នាំ, ៦-ឈ្មោះ ជ័រ ស្រីតេង ភេទស្រី អាយុ ២៤ឆ្នាំ ភូមិពន្លៃ ឃុំពន្លៃ ស្រុកអង្គរបូរី ខេត្តតាកែវ និងបានធ្វើការសាកសួរ អប់រំណែនាំ ដោយមានការចូលរួមត្រួតពិនិត្យសុខភាព ពីមន្ត្រីចត្តាឡីស័កប្រចាំមាត់ច្រក នូវវិធានការរបស់ក្រសួងសុខាភិបាលផងដែរ។

ដោយឡែកខាងភាគីថៃ នៅតែបន្តបិទច្រកមិនឲ្យអ្នកដំណើរ ចេញ-ចូល ចំណែកទំនិញទទួលបានការអនុញ្ញាត និងអ្នកបើកបររថយន្តចំនួន ០២នាក់ ដែលទទួលបានការអនុញ្ញាត និងបានការឆ្លងកាត់ត្រួតពិនិត្យដោយសមត្ថកិច្ចទាំងភាគី កម្ពុជា-ថៃ បានយ៉ាងត្រឹមត្រូវ៕

## ពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ១២២នាក់

https://www.facebook.com/GDIOfficial 28-10-2020

នៅថ្ងៃទី២៨ ខែតុលា ឆ្នាំ២០២០ វេលាម៉ោង ១៥និង០០នាទី ភាគីថៃនៅតែបន្តបិទច្រកទ្វារព្រំដែនអន្តរជាតិ ឆង ចម ខេត្តសុរិន្ទ ទល់មុខច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ ជាបណ្តោះអាសន្ន មិនអនុញ្ញាតឲ្យអ្នកដំណើរ គ្រប់សញ្ជាតិចេញ-ចូល ឆ្លងកាត់ ដើម្បីបង្ការនិងទប់ស្កាត់ការរាតត្បាតនៃជំងឺឆ្លងកូវីដ-១៩។ ក្នុងការបិទច្រកនេះ ភាគីថៃបានលើកលែង ទំនិញដែលទទួលបានការអនុញ្ញាត និងអ្នកបើកបររថយន្តដឹកទំនិញដែលទទួលបានការអនុញ្ញាត ព្រមទាំងបានការឆ្លងកាត់ត្រួតពិនិត្យ ដោយសមត្ថកិច្ចទាំងភាគី កម្ពុជា-ថៃ បានត្រឹមត្រូវ និងពលរដ្ឋខ្មែរ ឬពលរដ្ឋថៃ ដែលត្រូវវិលត្រឡប់ចូលប្រទេសរៀងៗខ្លួន។ ចំណែកឯពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ១២២នាក់ ស្រី ៥៥នាក់ និងពលរដ្ឋថៃដែលបានចាកចេញមានចំនួន ០៣នាក់ ស្រី ០១នាក់ ដោយមានឯកសារចេញពីស្ថានទូតថៃ និងលិខិតបញ្ជាក់សុខភាព៕

## ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិចាំយាម បានទទួលពលករខ្មែរចំនួន ០២នាក់ ពីសមត្ថកិច្ចថៃ ពាក់ព័ន្ធនឹងករណីឆ្លងដែនខុសច្បាប់

https://www.facebook.com/GDIOfficial 28-10-2020

នៅថ្ងៃទី២៨ ខែតុលា ឆ្នាំ២០២០ ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិចាំយាម បានទទួលពលករខ្មែរចំនួន ០២នាក់ ពីសមត្ថកិច្ចថៃ ពាក់ព័ន្ធនឹងករណីឆ្លងដែនខុសច្បាប់។ នគរបាលប៉ុស្តិ៍បានឲ្យដឹងថា ពលករខ្មែរទាំង ០២នាក់នេះ មាន ១-ឈ្មោះ វ៉ាង ជិន ភេទស្រី អាយុ ៣៦ឆ្នាំ ភូមិស្វាយប៉ាក ឃុំស្វាយប៉ាក ខ័ណ្ឌឫស្សីកែវ រាជធានីភ្នំពេញ, ២-ឈ្មោះ រឹម អយ ភេទស្រី អាយុ ១៦ឆ្នាំ ភូមិចាំយាម ឃុំប៉ាក់ខ្លង ស្រុកមណ្ឌលសីម៉ា ខេត្តកោះកុង និងបានធ្វើការសាកសួរ អប់រំណែនាំ ដោយមានការចូលរួមត្រួតពិនិត្យសុខភាព ពីមន្ត្រីចត្តាឡីស័កប្រចាំមាត់ច្រក នូវវិធានការរបស់ក្រសួងសុខាភិបាលផងដែរ។ ដោយឡែកខាងភាគីថៃ នៅតែបន្តបិទច្រកមិនឲ្យអ្នកដំណើរ ចេញ-ចូល ចំណែកទំនិញទទួលបានការអនុញ្ញាត និងអ្នកបើកបររថយន្តចំនួន ០២នាក់ ដែលទទួលបានការអនុញ្ញាត និងបានការឆ្លងកាត់ត្រួតពិនិត្យ ដោយសមត្ថកិច្ចទាំងភាគី កម្ពុជា-ថៃ បានយ៉ាងត្រឹមត្រូវ៕

## ថ្ងៃទី០៤ ខែ វិច្ឆិកា ឆ្នាំ២០២០

## ពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ៣៥៣នាក់

https://www.facebook.com/GDIOfficial 02-11-2020

នៅថ្ងៃទី២ ខែវិច្ឆិកា ឆ្នាំ២០២០ វេលាម៉ោង ១៥និង០០នាទី ភាគីថៃនៅតែបន្តបិទច្រកទ្វារព្រំដែនអន្តរជាតិ ឆង ចម ខេត្តសុរិន្ទ ទល់មុខច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ ជាបណ្តោះអាសន្ន មិនអនុញ្ញាតឲ្យអ្នកដំណើរ គ្រប់សញ្ជាតិចេញ-ចូល ឆ្លងកាត់ ដើម្បីបង្ការ និងទប់ស្កាត់ការរាតត្បាតនៃជំងឺឆ្លង កូវីដ-១៩។ ក្នុងការបិទច្រកនេះ ភាគីថៃបានលើកលែង ទំនិញដែលទទួលបានការអនុញ្ញាត និងអ្នកបើកបររថយន្តដឹកទំនិញ ដែលទទួលបានការអនុញ្ញាត ព្រមទាំងបានការឆ្លងកាត់ត្រួតពិនិត្យ ដោយសមត្ថកិច្ចទាំងភាគី កម្ពុជា-ថៃ បានត្រឹមត្រូវ និងពលរដ្ឋខ្មែរ ឬពលរដ្ឋថៃ ដែលត្រូវវិលត្រឡប់ចូលប្រទេសរៀងៗខ្លួន។ ចំណែកឯពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ៣៥៣នាក់ ស្រី ១៥២នាក់ និងពលរដ្ឋខ្មែរចាកចេញពីប្រទេសចំនួន ៣១នាក់ ស្រី ១៧នាក់ ជានិស្សិត៕

## ការបង្ការទប់ស្កាត់អំពើជួញដូរមនុស្ស និងកិច្ចការពារកុមារពីការរំលោភបំពានផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញ នៅតាមសហគមន៍ ក្នុងវិទ្យាល័យស្វាយលើ ខេត្តសៀមរាប

https://www.facebook.com/deputygovernoryousophear/ 03-11-2020

ខេត្តសៀមរាប៖ នាថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០២០ លេខាធិការដ្ឋានគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ខ.ប.ជ) ខេត្តសៀមរាប មន្ទីរអប់រំ យុវជន និងកីឡា ខេត្តសៀមរាប និងអង្គការសកម្មភាពដើម្បីកុមារ (APLE) បានបន្តសហការរៀបចំវគ្គបណ្តុះបណ្តាលស្តីពី ការបង្ការទប់ស្កាត់អំពើជួញដូរមនុស្ស និងការរំលោភបំពានផ្លូវភេទលើកុមារនៅតាមសហគមន៍ ដល់ កុមារ និងយុវជនចំនួន៥០នាក់ នៅវិទ្យាល័យស្វាយលើ ស្រុកស្វាយលើ។ នៅក្នុងវគ្គបណ្តុះបណ្តាលនេះ ក្រុមការងារផ្តោតលើខ្លឹមសារប្រធានបទ ៖

១,អំពើជួញដូរមនុស្សនិងអំពើកេងប្រវ័ញ្ច

២, ការរំលោភបំពានផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញ

និង៣, ការធ្វើចំណាក ស្រុកប្រកបដោយសុវត្ថិភាព ដោយបានផ្តល់ និងចែករំលែកព័ត៌មានអំពីវិធីសាស្រ្តនៃការបង្ការទប់ស្កាត់អំពើជួញដូរមនុស្ស និងការរំលោភបំពានផ្សេងៗទៅដល់សិស្សានុសិស្ស ដើម្បីឲ្យពួកគេបានយល់ដឹងពីការការពារខ្លួនពីការជួញដូរមនុស្ស និងការពារពីហានិភ័យនៃការប្រើប្រាស់ប្រព័ន្ធព័ត៌មានវិទ្យា។ ក៏ដូចជាការផ្សព្វផ្សាយបន្តទៅមិត្តភក្តិ បងប្អូនសាច់ញាតិ និងសហគមន៍របស់គេឱ្យបានយល់ដឹងផងដែរ។

## ការបង្ការទប់ស្កាត់អំពើជួញដូរមនុស្ស និងកិច្ចការពារកុមារពីការរំលោភបំពានផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញ នៅតាមសហគមន៍ ក្នុងខេត្តសៀមរាប

https://www.facebook.com/deputygovernoryousophear/ 03-11-2020

ខេត្តសៀមរាប៖ នាថ្ងៃទី២ ខែវិច្ឆិកា ឆ្នាំ២០២០ លេខាធិការដ្ឋានគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ខ.ប.ជ) ខេត្តសៀមរាប មន្ទីរអប់រំ យុវជន និងកីឡា ខេត្តសៀមរាប និងអង្គការសកម្មភាពដើម្បីកុមារ (APLE) បានសហការរៀបចំវគ្គបណ្តុះបណ្តាលស្តីពី៖ "ការបង្ការទប់ស្កាត់អំពើជួញដូរមនុស្ស និងការរំលោភបំពានផ្លូវភេទលើកុមារនៅតាមសហគមន៍" ដល់ កុមារ និងយុវជននៅវិទ្យាល័យសម្តេចតេជោ ហ៊ុន សែន សម្ព័ន្ធភាព ស្រុកជីក្រែង។ នៅក្នុងវគ្គបណ្តុះបណ្តាលនេះ ក្រុមការងារបានផ្តល់ និងចែករំលែកព័ត៌មានអំពីវិធីសាស្រ្តនៃការបង្ការទប់ស្កាត់អំពើជួញដូរមនុស្ស និងការរំលោភបំពានផ្សេងៗទៅដល់សិស្សានុសិស្ស ដើម្បីឲ្យពួកគេបានយល់ដឹងពីការការពារខ្លួនពីការជួញដូរមនុស្ស និងការពារពីហានិភ័យនៃការប្រើប្រាស់ប្រព័ន្ធព័ត៌មានវិទ្យា។

## អង្គការសង់ត្រាល់បានរៀបចំវេទិកាសហគមន៍ស្តីពីការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព

https://www.facebook.com/CentralCambodiaOrg/ 03-11-2020

នៅថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០២០នេះ អង្គការសង់ត្រាល់បានរៀបចំវេទិកាសហគមន៍ស្តីពីការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាពស្ថិតនៅភូមិម្នាស់កាល និងភូមិតាំងយូ ឃុំអូរដា ស្រុកកំរៀង ខេត្តបាត់ដំបង ក្នុងនោះមានអ្នកចូលរួមសរុប ១៦៨នាក់ ស្ត្រី ១០៨ នាក់ បុរស ៦០ នាក់ ក្រោមកិច្ចសហការ ជាមួយអាជ្ញាធរឃុំអូរដា ស្រុកកំរៀង ខេត្តបាត់ដំបង ។

#កម្មវិធីនេះរៀបចំឡើងក្នុងគោលបំណងដើម្បី៖

• លើកកម្ពស់ការយល់ដឹងដល់ប្រជាពលរដ្ឋស្តីពីការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព ជៀសវាងចាញ់បោកមេខ្យល់ដែលជាកម្មវត្ថុក្នុងការជួញដូរមនុស្សនិងការរំលោភបំពានសិទ្ធការងារគ្រប់រូបភាព។

•កាត់បន្ថយការធ្វើចំណាកស្រុក ដោយគ្មានឯកសារជាហេតុប្រឈមនិងគ្រោះថ្នាក់នៃអំពើជួញដូរ និងរំលោភបំពានសិទ្ធមនុស្សផ្សេងៗ។

•លើកកម្ពស់ការចូលរួមពីប្រជាពលរដ្ឋ និងពង្រឹងពង្រីកសហការណ៍ជាមួយអាជ្ញាធរមូលដ្ឋានក្នុងការទប់ស្កាត់ការជួញដូរមនុស្សគ្រប់ប្រភេទ។

## អង្គការសង់ត្រាល់បានរៀបចំវេទិកាសហគមន៍ស្តីពីការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព

https://www.facebook.com/CentralCambodiaOrg/ 02-11-2020

នៅថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០២០នេះ អង្គការសង់ត្រាល់បានរៀបចំវេទិកាសហគមន៍ស្តីពីការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាពស្ថិតនៅភូមិកំពង់ឡី និងភូមិសំរោង ឃុំអូរដា ស្រុកកំរៀង ខេត្តបាត់ដំបង ក្នុងនោះមានអ្នកចូលរួមសរុប ១៩១ នាក់ ស្ត្រី ១៤០នាក់ បុរស ៥១ នាក់ ក្រោមកិច្ចសហការ ជាមួយអាជ្ញាធរឃុំអូរដា ស្រុកកំរៀង ខេត្តបាត់ដំបង ។

#កម្មវិធីនេះរៀបចំឡើងក្នុងគោលបំណងដើម្បីៈ

- លើកកម្ពស់ការយល់ដឹងដល់ប្រជាពលរដ្ឋស្តីពីការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព ជៀសវាងចាញ់បោកមេខ្យល់ដែលជាកម្មវត្ថុក្នុងការជួញដូរមនុស្សនិងការរំលោភបំពានសិទ្ធការងារគ្រប់រូបភាព។
- កាត់បន្ថយការធ្វើចំណាកស្រុកដោយគ្មានឯកសារជាហេតុប្រឈមនិងគ្រោះថ្នាក់នៃអំពើជួញដូរ និងរំលោភបំពានសិទ្ធមនុស្សផ្សេងៗ។
- លើកកម្ពស់ការចូលរួមពីប្រជាពលរដ្ឋ និងពង្រឹងពង្រីកសហការណ៍ជាមួយអាជ្ញាធរមូលដ្ឋានក្នុងការទប់ស្កាត់ការជួញដូរមនុស្សគ្រប់ប្រភេទ។

## ពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ១៣៤នាក់

https://www.facebook.com/GDIOfficial 03-11-2020

នៅថ្ងៃទី៣ ខែវិច្ឆិកា ឆ្នាំ២០២០ វេលាម៉ោង ១៥និង០០នាទី ភាគីថៃនៅតែបន្តបិទច្រកទ្វារព្រំដែនអន្តរជាតិ ឆង ចម ខេត្តសុរិន្ទ ទល់មុខច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ ជាបណ្តោះអាសន្ន មិនអនុញ្ញាតឲ្យអ្នកដំណើរ គ្រប់សញ្ជាតិចេញ-ចូល ឆ្លងកាត់ ដើម្បីបង្ការ និងទប់ស្កាត់ការរាតត្បាតនៃជំងឺឆ្លង កូវីដ-១៩។ ក្នុងការបិទច្រកនេះ ភាគីថៃបានលើកលែង ទំនិញដែលទទួលបានការអនុញ្ញាត និងអ្នកបើកបរថយន្តដឹកទំនិញ ដែលទទួលបានការអនុញ្ញាត ព្រមទាំងបានការឆ្លងកាត់ត្រួតពិនិត្យ ដោយសមត្ថកិច្ចទាំងភាគី កម្ពុជា-ថៃ បានត្រឹមត្រូវ និងពលរដ្ឋខ្មែរ ឬពលរដ្ឋថៃ ដែលត្រូវវិលត្រឡប់ចូលប្រទេសរៀងៗខ្លួន។ ចំណែកឯពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ១៣៤នាក់ ស្រី ៥១នាក់ និងពលរដ្ឋថៃដែលបានចាកចេញមានចំនួន ១១នាក់ ស្រី ០១នាក់៕

## កម្លាំងប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិចាំយាម បានចុះល្បាតក្នុងភូមិសាស្ត្រស្លាបស្តាំ ពិនិត្យឃើញពលរដ្ឋខ្មែរ ឆ្លងដែនខុសច្បាប់ចំនួន ០៣នាក់

https://www.facebook.com/GDIOfficial 02-11-2020

នៅថ្ងៃទី២ ខែវិច្ឆិកា ឆ្នាំ២០២០ វេលាម៉ោង ០៦និង១៥នាទី កម្លាំងប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិចាំយាម បានចុះល្បាតក្នុងភូមិសាស្ត្រស្លាបស្តាំ ពិនិត្យឃើញពលរដ្ឋខ្មែរ ឆ្លងដែនខុសច្បាប់ចំនួន ០៣នាក់។ នគរបាលប៉ុស្តិ៍បានឲ្យដឹងថា ពលរដ្ឋខ្មែរទាំង ០៣នាក់នេះ មាន ១-ឈ្មោះ គឹម រ៉ា ភេទប្រុស អាយុ ៣១ឆ្នាំ, ២-ឈ្មោះ ស្រះ យ៉ា ភេទស្រី អាយុ ៤២ឆ្នាំ ភូមិស្រង៉ែ ឃុំបឹងនិមល ស្រុកឈូក ខេត្តកំពត, ៣-ឈ្មោះ ចិន ស្រីនាង ភេទស្រី អាយុ ២៦ឆ្នាំ ភូមិស្រែក្នុង ឃុំព្រៃយ៉ាវ ស្រុកជុំគិរី ខេត្តកំពត និងបានធ្វើការសាកសួរ អប់រំណែនាំ រួច

ប្រគល់ជូនមន្ត្រីចត្តាឡីស័ក ប្រចាំមាត់ច្រក ដើម្បីអនុវត្តនិតិវិធីបន្ត នូវវិធានការរបស់ក្រសួងសុខាភិបាលផងដែរ។ ដោយឡែកខាងភាគីថៃ នៅតែបន្តបិទច្រកមិនឲ្យអ្នកដំណើរ ចេញ-ចូល ចំណែកទំនិញទទួលបានការអនុញ្ញាត និងអ្នកបើកបររថយន្តចំនួន ០២នាក់ ដែលទទួលបានការអនុញ្ញាត និងបានការឆ្លងកាត់ត្រួតពិនិត្យ ដោយសមត្ថកិច្ចទាំងភាគី កម្ពុជា-ថៃ បានយ៉ាងត្រឹមត្រូវគ្មានកូវីដ-១៩៕

## ថ្ងៃទី០៦ ខែ វិច្ឆិកា ឆ្នាំ២០២០

## ឯកឧត្តម ឡាំ ជា រដ្ឋលេខាធិការក្រសួងមហាផ្ទៃ បានដឹកនាំកិច្ចប្រជុំលើសេចក្តីព្រាងអនុស្សារណៈ នៃការយោគយល់គ្នា រវាងគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអង្គការមូលនិធិអេ ២១ កម្ពុជា

https://www.facebook.com/krongtepnews/ ចេញផ្សាយថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ២០២០

ឯកឧត្តម ឡាំ ជា រដ្ឋលេខាធិការក្រសួងមហាផ្ទៃ បានដឹកនាំកិច្ចប្រជុំលើសេចក្តីព្រាងអនុស្សារណៈនៃការយោគយល់គ្នារវាងគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអង្គការមូលនិធិអេ២១កម្ពុជាស្តីអំពីកិច្ចសហប្រតិបត្តិការលើការងារបង្ការទប់ស្កាត់ ការការពារ និងការកំណត់អត្តសញ្ញាណបឋមជនរងគ្រោះដោយអំពើជួញដូរមនុស្ស (ការិយាល័យឯកឧត្តម ឡាំ ជា ): នារសៀលថ្ងៃព្រហស្បតិ៍ ទី៥ ខែវិច្ឆិកា ឆ្នាំ២០២០ ឯកឧត្តម ឡាំ ជា រដ្ឋលេខាធិការក្រសួងមហាផ្ទៃ បានដឹកនាំកិច្ចប្រជុំលើសេចក្តីព្រាងអនុស្សារណៈនៃការយោគយល់គ្នារវាងគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអង្គការមូលនិធិអេ២១កម្ពុជាស្តីអំពី កិច្ចសហប្រតិបត្តិការលើការងារបង្ការទប់ស្កាត់ ការការពារ និងការកំណត់អត្តសញ្ញាណបឋមជនរងគ្រោះដោយអំពើជួញដូរមនុស្ស។ ក្នុងនោះដែរឯកឧត្តមរដ្ឋលេខាធិការបានណែនាំធ្វើយ៉ាងណាអោយអនុស្សារណៈនៃការយោគយល់នេះ មានលក្ខណៈត្រឹមត្រូវទាំងទំរង់ ខ្លឹមសារ និងបច្ចេកទេសគោរពតាមគោការណ៍ច្បាប់។

## ក្រសួងការងារ ចេញប្រកាសព័ត៌មានពីលទ្ធផលកិច្ចប្រជុំជាមួយក្រសួងការងារថៃ ពាក់ព័ន្ធនឹងពលករកម្ពុជាដែលកំពុងស្នាក់នៅ និងធ្វើការនៅប្រទេសថៃ

https://www.cen.com.kh/ November 6, 2020

ភ្នំពេញ៖ សេចក្តីប្រកាសព័ត៌មាននៃលទ្ធផលកិច្ចប្រជុំរវាងឯកឧត្តមបណ្ឌិត អ៊ិត សំហេង រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងជាប្រធានគណៈកម្មការផ្តល់ភាពស្របច្បាប់ដល់ពលករកម្ពុជាដែលកំពុងស្នាក់នៅ និងធ្វើការនៅប្រទេសថៃ និងឯកឧត្តម Surachai Chaitrakulthong អនុរដ្ឋមន្ត្រីក្រសួងការងារ ដែលត្រូវបានផ្ទេរសិទ្ធិដោយឯកឧត្តម Suchart Chomklin រដ្ឋមន្ត្រីក្រសួងការងារនៃព្រះរាជាណាចក្រថៃឡង់ដ៍ រួមទាំងតំណាងអាជ្ញាធរពាក់ព័ន្ធនៃប្រទេសទាំងពីរ តាមប្រព័ន្ធវីដេអូ។

បើតាម សេចក្តីប្រកាសព័ត៌មានរបស់ក្រសួងការងារៈជំនួបនេះ ដើម្បីពិភាក្សាការងារ ពាក់ព័ន្ធនឹងការអនុវត្តអនុស្សរណៈនៃការយោគយល់គ្នាលើកិច្ចសហប្រតិបត្តិការនៃវិស័យការងារ, កិច្ចព្រម ព្រៀងស្តីពីការប្រើប្រាស់កម្លាំងពលកម្ម, ការការពារពលករកម្ពុជា និងការផ្តល់ភាពស្របច្បាប់ដល់ពលករកម្ពុជា ដែលកំពុងស្នាក់នៅ និងធ្វើការនៅប្រទេសថៃក្នុងអំឡុងពេលការរីករាលដាលនៃជំងឺកូវីដ-១៩, ការជ្រើសរើស និងបញ្ជូនពលករតាមរដូវកាល សម្រាប់ការងារនៅបណ្តាខេត្តជាប់ព្រំដែន , និងការជ្រើសរើសនិងបញ្ជូនពលករតាមរយៈអនុស្សរណៈ នៃការយោគយល់គ្នាឡើងវិញ។ ក្នុងឱកាសកិច្ចប្រជុំខាងលើ ភាគីទាំងពីរ បានសំដែងនូវការពេញចិត្ត និងវាយតម្លៃខ្ពស់ ចំពោះកិច្ចសហការ ដ៏ល្អនាពេលកន្លងមកលើការគ្រប់គ្រង ការពារ និងអនុគ្រោះដល់ពលករកម្ពុជាដែលកំពុងស្នាក់នៅ និងធ្វើការ

នៅប្រទេសថៃក្នុងអំឡុងពេលការរីករាលដាលនៃជំងឺកូវីដ-១៩នេះ។ ជាលទ្ធផល ភាគីទាំងពីរបានឯកភាពគ្នាដូចខាងក្រោម៖

១. បន្តកិច្ចសន្យាការងាររយៈពេល ២ឆ្នាំបន្ថែមទៀត ចំពោះពលករ ដែលបានបញ្ជូនតាមរយៈអនុស្សរណៈនៃការយោគយល់គ្នា ហើយត្រូវបញ្ចប់កិច្ចសន្យាការងាររយៈពេល ៤ឆ្នាំ ចាប់ពីនៅថ្ងៃទី១ ខែវិច្ឆិកា ឆ្នាំ២០២០ រហូតដល់ការរីករាលនៃជំងឺកូវីដ-១៩ អាចគ្រប់គ្រងបាន ដោយពុំចាំបាច់ធ្វើមាតុភូមិនិវត្តន៍មកកម្ពុជាវិញ។ បន្ទាប់ពីបញ្ចប់កិច្ចសន្យាការងារបន្តរយៈពេល ២ឆ្នាំរួចហើយ ពលករទាំងនោះនឹងត្រូវត្រឡប់មកកម្ពុជាវិញ ដោយមិនអនុញ្ញាតឱ្យបន្តកិច្ចសន្យាទៀតឡើយ។

២.បញ្ជូន និងទទួលពលករកម្ពុជាទៅធ្វើការតាមរដូវកាលនៅតាមបណ្តាខេត្តជាប់ព្រំដែនកម្ពុជា-ថៃ ដោយភាគីទាំងពីររៀបចំស្នើសុំគោលការណ៍ពីរាជរដ្ឋាភិបាលរបស់ខ្លួន ដើម្បីបើកច្រកព្រំដែន សម្រាប់បញ្ជូន និងទទួលពលករកម្ពុជាដោយត្រូវអនុវត្តតាមវិធានសុខាភិបាលនៃប្រទេសទាំងពីរ។

៣.ផ្តល់ការបន្តសុពលភាពលិខិតធ្វើដំណើរពលករកម្ពុជាធ្វើការនៅបរទេស (TD) ជូនពលករកម្ពុជា ដែលកំពុងស្នាក់នៅ និងធ្វើការនៅប្រទេសថៃ តាមប្រព័ន្ធស្វ័យប្រវត្តិកម្មនៅពេលដ៏ខ្លីខាងមុខនេះ។

ភាគីថៃស្នើសុំ និងបានត្រៀមសម្របសម្រួលជាមួយស្ថាប័នពាក់ព័ន្ធរបស់ខ្លួនដើម្បីទទួលមន្ត្រី បច្ចេកទេសនៃគណៈកម្មការផ្តល់ភាពស្របច្បាប់ដល់ពលករកម្ពុជាដែលកំពុងស្នាក់នៅ និងធ្វើការនៅ ប្រទេសថៃ ដើម្បីជួយបង្កើនល្បឿនក្នុងការផ្តល់សុពលភាពឯកសារ និងគ្រប់គ្រងទិន្នន័យពលករ ដើម្បីទទួលបានការគាំពារសង្គម និងអត្ថប្រយោជន៍សន្តិសុខសង្គមនៅពេលបញ្ចប់កិច្ចសន្យាការងារ។ ភាគីកម្ពុជានឹងស្នើសុំគោលការណ៍រាជរដ្ឋាភិបាលដើម្បីបញ្ជូនក្រុមការងារបច្ចេកទេស នៃគណៈកម្មការ ផ្តល់ភាពស្របច្បាប់ដល់ពលករកម្ពុជាដែលកំពុងស្នាក់នៅនិងធ្វើការនៅប្រទេសថៃ ដែលរួមមាន ក្រសួងការងារនិងបណ្តុះបណ្តាល វិជ្ជាជីវៈ ក្រសួងមហាផ្ទៃ និងស្ថានឯកអគ្គរាជទូតព្រះរាជាណាចក្រ កម្ពុជាប្រចាំនៅប្រទេសថៃ ដើម្បីធ្វើការបន្តសុពលភាពលិខិតធ្វើដំណើរពលករកម្ពុជាធ្វើការនៅបរទេស (TD) តាមរយៈប្រព័ន្ធស្វ័យប្រវត្តិកម្ម និងសម្របសម្រួលជាមួយភាគីថៃក្នុងការផ្តល់ភាពស្របច្បាប់ដល់ ពលករកម្ពុជា។

៤. ពិភាក្សាបច្ចេកទេស និងនីតិវិធីនៃការជ្រើសរើស និងបញ្ជូនពលករកម្ពុជាទៅធ្វើការនៅប្រទេសថៃ តាមរយៈអនុស្សរណៈនៃការយោគយល់គ្នា ក្នុងអំឡុងពេលការរីករាលដាលនៃជំងឺកូវីដ-១៩ ដោយ អនុលោមតាមវិធានសុខាភិបាលនៃប្រទេសទាំងពីរ។

៥. នឹងរួមគ្នាបង្ការ និងទប់ស្កាត់ភាពមិនប្រក្រតីនៃការផ្តល់ភាពស្របច្បាប់ជូនពលករ និងរួមគ្នាទប់ស្កាត់ការឆ្លងដែនទៅធ្វើការខុសច្បាប់។

កិច្ចប្រជុំនេះបានប្រព្រឹត្តទៅដោយរលូន ក្នុងលក្ខណៈមិត្តភាព សហប្រតិបត្តិការ និងយោគយល់គ្នាទៅ វិញទៅមក ដោយឈរលើអត្ថប្រយោជន៍នៃប្រទេសទាំងពីរ៕ ដោយៈបញ្ញាស័ក្តិ

## អង្គការសង់ត្រាល់បានរៀបចំវេទិកាសហគមន៍ស្តីពីការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព

https://www.facebook.com/CentralCambodiaOrg/ 06-11-2020

នៅថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ២០២០នេះ អង្គការសង់ត្រាល់បានរៀបចំវេទិកាសហគមន៍ស្តីពីការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាពស្ថិតនៅភូមិ អូរគគីរ និងភូមិអូត្រាវជ្រ ឃុំ សិរីមានជ័យ ស្រុក សំពៅលូន ខេត្ត បាត់ដំបង ក្នុងនោះមានអ្នកចូលរួមសរុប ២៥៧នាក់ ស្ត្រី ១៩៣ នាក់ បុរស ៦៤ នាក់ក្រោមកិច្ចសហការ ជាមួយអាជ្ញាធរឃុំសន្តិភាព ស្រុកសំពៅលូន ខេត្តបាត់ដំបង ។ #កម្មវិធីនេះរៀបចំឡើងក្នុងគោលបំណងដើម្បី៖

• លើកកម្ពស់ការយល់ដឹងដល់ប្រជាពលរដ្ឋស្តីពីការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព ជៀសវាងចាញ់បោកមេខ្យល់ដែលជាកម្មវត្ថុក្នុងការជួញដូរមនុស្សនិងការរំលោភបំពានសិទ្ធការងារគ្រប់រូបភាព។

•កាត់បន្ថយការធ្វើចំណាកស្រុកដោយគ្មានឯកសារជាហេតុប្រឈម និងគ្រោះថ្នាក់នៃអំពើជួញដូរ និងរំលោភបំពានសិទ្ធមនុស្សផ្សេងៗ។

• លើកកម្ពស់ការចូលរួមពីប្រជាពលរដ្ឋ និងពង្រឹងពង្រីកសហការណ៍ជាមួយអាជ្ញាធរមូលដ្ឋានក្នុងការទប់ស្កាត់ការជួញដូរមនុស្សគ្រប់ប្រភេទ។

## អង្គការសង់ត្រាល់បានរៀបចំវេទិកាសហគមន៍ស្តីពីការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព

https://www.facebook.com/CentralCambodiaOrg/ 06-11-2020

នៅថ្ងៃទី០៤ ខែវិច្ឆិកា ឆ្នាំ២០២០នេះ អង្គការសង់ត្រាល់បានរៀបចំវេទិកាសហគមន៍ស្តីពីការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាពស្ថិតនៅភូមិស្រះចកនិងភូមិអូថ្ម ឃុំ សន្តិភាព ស្រុក សំពៅលូន ខេត្តបាត់ដំបង ក្នុងនោះមានអ្នកចូលរួមសរុប៧៥ នាក់ ស្ត្រី ៤៩ នាក់ ប្រុស ២៦ នាក់ ក្រោមកិច្ចសហការ ជាមួយអាជ្ញាធរឃុំសន្តិភាព ស្រុកសំពៅលូន ខេត្តបាត់ដំបង ។ #កម្មវិធីនេះរៀបចំឡើងក្នុងគោលបំណងដើម្បីៈ

• លើកកម្ពស់ការយល់ដឹងដល់ប្រជាពលរដ្ឋស្តីពីការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព ជៀសវាងចាញ់បោកមេខ្យល់ដែលជាកម្មវត្ថុក្នុងការជួញដូរមនុស្សនិងការរំលោភបំពានសិទ្ធការងារគ្រប់រូបភាព។

•កាត់បន្ថយការធ្វើចំណាកស្រុកដោយគ្មានឯកសារជាហេតុប្រឈម និងគ្រោះថ្នាក់នៃអំពើជួញដូរ និងរំលោភបំពានសិទ្ធមនុស្សផ្សេងៗ។

• លើកកម្ពស់ការចូលរួមពីប្រជាពលរដ្ឋ និងពង្រឹងពង្រីកសហការណ៍ជាមួយអាជ្ញាធរមូលដ្ឋានក្នុងការទប់ស្កាត់ការជួញដូរមនុស្សគ្រប់ប្រភេទ។

## ពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ១៧១នាក់

https://www.facebook.com/GDIOfficial 05-11-2020

នៅថ្ងៃទី៥ ខែវិច្ឆិកា ឆ្នាំ២០២០ វេលាម៉ោង ១៥និង០០នាទី ភាគីថៃនៅតែបន្តបិទច្រកទ្វារព្រំដែនអន្តរជាតិ ឆង ចម ខេត្តសុរិន្ទ ទល់មុខច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ ជាបណ្តោះអាសន្ន មិនអនុញ្ញាតឲ្យអ្នកដំណើរ គ្រប់សញ្ជាតិចេញ-ចូល ឆ្លងកាត់ ដើម្បីបង្ការ និងទប់ស្កាត់ការរាតត្បាតនៃជំងឺឆ្លង កូវីដ-១៩។ ក្នុងការបិទច្រកនេះ ភាគីថៃបានលើកលែង ទំនិញដែលទទួលបានការអនុញ្ញាត និងអ្នកបើកបររថយន្តដឹកទំនិញ ដែលទទួលបានការអនុញ្ញាត ព្រមទាំងបានការឆ្លងកាត់ត្រួតពិនិត្យ ដោយសមត្ថកិច្ចទាំងភាគី កម្ពុជា-ថៃ បានត្រឹមត្រូវ និងពលរដ្ឋខ្មែរ ឬពលរដ្ឋថៃ ដែលត្រូវវិលត្រឡប់ចូលប្រទេសរៀងៗខ្លួន។ ចំណែកឯពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ១៧១នាក់ ស្រី ៦៩នាក់៕

## ពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ១៤៨នាក់

https://www.facebook.com/GDIOfficial 04-11-2020

នៅថ្ងៃទី៤ ខែវិច្ឆិកា ឆ្នាំ២០២០ វេលាម៉ោង ១៥និង០០នាទី ភាគីថៃនៅតែបន្តបិទច្រកទ្វារព្រំដែនអន្តរជាតិ ឆង ចម ខេត្តសុរិន្ទ ទល់មុខច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ ជាបណ្ដោះអាសន្ន មិនអនុញ្ញាតឲ្យអ្នកដំណើរ គ្រប់សញ្ជាតិចេញ-ចូល ឆ្លងកាត់ ដើម្បីបង្ការ និងទប់ស្កាត់ការរាតត្បាតនៃជំងឺឆ្លង កូវីដ-១៩។ ក្នុងការបិទច្រកនេះ ភាគីថៃបានលើកលែង ទំនិញដែលទទួលបានការអនុញ្ញាត និងអ្នកបើកបររថយន្តដឹកទំនិញ ដែលទទួលបានការអនុញ្ញាត ព្រមទាំងបានការឆ្លងកាត់ត្រួតពិនិត្យ ដោយសមត្ថកិច្ចទាំងភាគី កម្ពុជា-ថៃ បានត្រឹមត្រូវ និងពលរដ្ឋខ្មែរ ឬពលរដ្ឋថៃ ដែលត្រូវវិលត្រឡប់ចូលប្រទេសរៀងៗខ្លួន។ ចំណែកឯពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ១៤៨នាក់ ស្រី ៦៥នាក់ និងពលរដ្ឋថៃដែលបានចាកចេញមានចំនួន ០១នាក់៕

## ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិចាំយាម បានទទួលពលករខ្មែរចំនួន ០៤នាក់ ពីសមត្ថកិច្ចថៃ ពាក់ព័ន្ធនឹងករណីឆ្លងដែនខុសច្បាប់

https://www.facebook.com/GDIOfficial 04-11-2020

នៅថ្ងៃទី៤ ខែវិច្ឆិកា ឆ្នាំ២០២០ ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិចាំយាម បានទទួលពលករខ្មែរចំនួន ០៤នាក់ ពីសមត្ថកិច្ចថៃ ពាក់ព័ន្ធនឹងករណីឆ្លងដែនខុសច្បាប់។ នគរបាលប៉ុស្តិ៍បានឲ្យដឹងថា ពលករខ្មែរទាំង ០៤នាក់នេះ មាន ១-ឈ្មោះ សាន្ត ភន ភេទប្រុស អាយុ ៣៣ឆ្នាំ ភូមិពោធិ៍ព្រីង ឃុំខ្វាវ ស្រុកជីក្រែង ខេត្ត សៀមរាប, ២-ឈ្មោះវណ្ណ ឌីចាន់ ភេទប្រុស អាយុ ៣៧ឆ្នាំ, ៣-ឈ្មោះ គឹម ដានី ភេទស្រី អាយុ ៣៨ឆ្នាំ, ភូមិព្រៃសង្ហា ឃុំខ្នាចរមាស ស្រុកបវេល ខេត្តបាត់ដំបង, ៤-ឈ្មោះ មុំ ឈួន ភេទស្រី អាយុ ៤៣ឆ្នាំ ភូមិវាលមាស ឃុំវាលមាស ស្រុកវាលរិញ ខេត្តព្រះសីហនុ និងបានធ្វើការសាកសួរ អប់រំណែនាំ ដោយមានការចូលរួមត្រួតពិនិត្យសុខភាព ពីមន្ត្រីចត្តាឡីស័កប្រចាំមាត់ច្រក នូវវិធានការរបស់ក្រសួងសុខាភិបាលផងដែរ។ ដោយឡែកខាងភាគីថៃ នៅតែបន្តបិទច្រកមិនឲ្យអ្នកដំណើរ ចេញ-ចូល ចំណែកទំនិញទទួលបានការអនុញ្ញាត និងអ្នកបើកបររថយន្តចំនួន ០២នាក់ ដែលទទួលបានការអនុញ្ញាត និងបានការឆ្លងកាត់ត្រួតពិនិត្យ ដោយសមត្ថកិច្ចទាំងភាគី កម្ពុជា-ថៃ បានយ៉ាងត្រឹមត្រូវ៕

## ពលរដ្ឋខ្មែរចំនួន៣នាក់ ទទួលរងការចោទប្រកាន់ថា បានចូលទឹកដីថៃ បំណងកាប់ឈើ ត្រូវបានចាប់ខ្លួន

https://www.cen.com.kh/ November 5, 2020

បាត់ដំបង ៖ ការឃាត់ខ្លួនពលរដ្ឋខ្មែរចំនួន៣នាក់ ធ្វើឡើងដោយមន្ត្រីអភិរក្សព្រៃឈើថៃ ដោយចោទប្រកាន់ថា ចូលទៅថៃគ្រោងកាប់ឈើ កាលពីវេលាថ្ងៃត្រង់ថ្ងៃទី៣ ខែវិច្ឆកា ឆ្នាំ២០២០ ត្រង់ចំណុចទឹកដីថៃក្នុងភូមិសាស្រ្ត ភូមិបានមួង ឃុំនីនស៊ី ស្រុកបរ៉ៃ ខេត្តត្រាត ឈមគ្នានឹងតំបន់ស្រុកសំឡូត ខេត្តបាត់ដំបង ។ ពលរដ្ឋខ្មែរទាំងបីនាក់ មានឈ្មោះ សែម រដ្ឋ ភេទប្រុស អាយុ១៧ឆ្នាំ. ឈ្មោះអៀត សុខឃឿនភេទប្រុសអាយុ២៦ឆ្នាំ និងម្នាក់ទៀតឈ្មោះ ចាន់ សុខខា ភេទប្រុស អាយុ៣១ឆ្នាំ ទាំង៣នាក់រស់នៅក្នុងភូមិស្រែអណ្តូង ឃុំសំឡូត ស្រុកសំឡូត ខេត្តបាត់ដំបង ។

លោក ម៉ី ណាន់ នាយប៉ុស្តិ៍នគរបាលព្រំដែន ស្រុកសំឡូតបានបញ្ជាក់ នៅថ្ងៃទី ៤ ខែវិច្ឆកា ឆ្នាំ២០២០នេះ ថា ក្រុមការងារកំពុង សម្របសម្រួលនាំយកប្រជាពលរដ្ឋដែលប្រព្រឹត្តខុសច្បាប់នេះដើម្បីយកទៅអប់រំ ណែនាំនៅ

មូលដ្ឋានទឹកដីប្រទេសកម្ពុជាវិញ ។ ប៉ុន្តែខាងភាគីកងកម្លាំង ក៏ដូចជាមន្ត្រីជំនាញរបស់ថៃ បានបដិសេធចំពោះការស្នើសុំនេះដោយរក្សាទុក ដើម្បីអនុវត្តទោសតាមច្បាប់របស់ថៃសិន ៕ **ដោយ៖CEN**

## ការបង្ការទប់ស្កាត់អំពើជួញដូរមនុស្ស និងកិច្ចការពារកុមារពីការរំលោភបំពានផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញ នៅតាមសហគមន៍ ក្នុងវិទ្យាល័យស្វាយលើ ខេត្តសៀមរាប

https://www.facebook.com/deputygovernoryousophear/ 04-11-2020

ខេត្តសៀមរាប៖ នាថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០២០ លេខាធិការដ្ឋានគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ខ.ប.ជ) ខេត្តសៀមរាប មន្ទីរអប់រំ យុវជន និងកីឡា ខេត្តសៀមរាប និងអង្គការសកម្មភាពដើម្បីកុមារ (APLE) បានបន្តសហការរៀបចំវគ្គបណ្តុះបណ្តាលស្តីពី ការបង្ការទប់ស្កាត់អំពើជួញដូរមនុស្ស និងការរំលោភបំពានផ្លូវភេទលើកុមារនៅតាមសហគមន៍ ដល់ កុមារ និងយុវជនចំនួន៥០នាក់ នៅវិទ្យាល័យស្វាយលើ ស្រុកស្វាយលើ។ នៅក្នុងវគ្គបណ្តុះបណ្តាលនេះ ក្រុមការងារផ្តោតលើខ្លឹមសារប្រធានបទ ៖ ១,អំពើជួញដូរមនុស្សនិងអំពើកេងប្រវ័ញ្ច ២, ការរំលោភបំពានផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញ និង៣, ការធ្វើចំណាក ស្រុកប្រកបដោយសុវត្ថិភាព ដោយបានផ្តល់ និងចែករំលែកព័ត៌មានអំពីវិធីសាស្រ្តនៃការបង្ការទប់ស្កាត់អំពើជួញដូរមនុស្ស និងការរំលោភបំពានផ្សេងៗទៅដល់សិស្សានុសិស្ស ដើម្បីឲ្យពួកគេបានយល់ដឹងពីការការពារខ្លួនពីការជួញដូរមនុស្ស និងការពារពីហានិភ័យនៃការប្រើប្រាស់ប្រព័ន្ធព័ត៌មានវិទ្យា។ ក៏ដូចជាការផ្សព្វផ្សាយបន្តទៅមិត្តភក្តិ បងប្អូនសាច់ញាតិ និងសហគមន៍របស់គេឱ្យបានយល់ដឹងផងដែរ។

## គណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ខេត្តសៀមរាប និងអង្គការសកម្មភាពដើម្បីកុមារ សហការរៀបចំវគ្គបណ្តុះបណ្តាលស្តីពី ការបង្ការទប់ស្កាត់អំពើជួញដូរមនុស្ស

https://www.facebook.com/deputygovernoryousophear/ 04-11-2020

ខេត្តសៀមរាប៖ នាថ្ងៃទី០៤ ខែវិច្ឆិកា ឆ្នាំ២០២០ លេខាធិការដ្ឋានគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ខ.ប.ជ) ខេត្តសៀមរាប មន្ទីរអប់រំ យុវជន និងកីឡា ខេត្តសៀមរាប និងអង្គការសកម្មភាពដើម្បីកុមារ (APLE)បានបន្តសហការរៀបចំវគ្គបណ្តុះបណ្តាលស្តីពីការបង្ការទប់ស្កាត់អំពើជួញដូរមនុស្ស និងការរំលោភបំពានផ្លូវភេទលើកុមារនៅតាមសហគមន៍ ដល់កុមារ និងយុវជនចំនួន៥២នាក់ នៅវិទ្យាល័យដំដែក ស្រុកសូទ្រនិគម។

## មន្ត្រីកម្ពុជា-ថៃ រៀបចំស្នើរដ្ឋាភិបាលខ្លួនបើកច្រកព្រំដែនសម្រាប់បញ្ជូន និងទទួលពលករខ្មែរ

https://vodkhmer.news/ លោកស្រី ពេជ្រ សុធារី ០៦ វិច្ឆិកា ២០២០ ម៉ោង ១០:៤៩

ភាគីកម្ពុជា-ថៃ គ្រោងស្នើសុំគោលការណ៍ពីរាជរដ្ឋាភិបាលរបស់ខ្លួន ដើម្បីបើកច្រកព្រំដែនសម្រាប់បញ្ជូន និងទទួលពលករកម្ពុជា និងប្រកាសរួមគ្នាទប់ស្កាត់ការឆ្លងដែនទៅធ្វើការដោយខុសច្បាប់ក្នុងអំឡុងពេលរីករាលដាលនៃជំងឺកូវីដ១៩។ កាលពីរសៀលថ្ងៃម្សិលមិញ រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈកម្ពុជា លោក អ៊ិត សំហេង បានជួបប្រជុំជាមួយលោក Surachai Chattrakulthong អនុរដ្ឋមន្ត្រីក្រសួងការងារថៃ តាមប្រព័ន្ធវីដេអូ ដើម្បីពិភាក្សាការងារពាក់ព័ន្ធនឹងការអនុវត្តអនុស្សរណៈនៃការយោគយល់គ្នា លើកិច្ចសហប្រតិបត្តិការនៃវិស័យការងារ និងការងារមួយចំនួនទៀតពាក់ព័ន្ធនឹងការជ្រើសរើសនិងបញ្ជូនពលករ។ សេចក្តីប្រកាសព័ត៌មានរបស់ក្រសួងការងារ ចេញផ្សាយកាលពីល្ងាចថ្ងៃព្រហស្បតិ៍ បានឱ្យដឹងថា ជាលទ្ធផល ភាគីទាំងពីរបានឯកភាពគ្នាបន្តកិច្ច

សន្យារយៈពេល២ឆ្នាំទៀត សម្រាប់ពលករដែលបានបញ្ជូនតាមរយៈអនុស្សរណៈនៃការយោគយល់គ្នា ហើយត្រូវបញ្ចប់កិច្ចសន្យាការងាររយៈពេល៤ឆ្នាំ ចាប់ពីថ្ងៃទី១ ខែវិច្ឆិកា ឆ្នាំ២០២០ រហូតដល់ការរីករាលដាលនៃជំងឺកូវីដ១៩ អាចគ្រប់គ្រងបាន ដោយពុំចាំបាច់ធ្វើមាតុភូមិនិវត្តន៍មកកម្ពុជាវិញ។

ពាក់ព័ន្ធនឹងការបញ្ជូននិងទទួលពលករកម្ពុជាទៅធ្វើការតាមរដូវកាលនៅតាមបណ្ដាខេត្តជាប់ព្រំដែនកម្ពុជា-ថៃ ក្រសួងការងារបញ្ជាក់ថា ភាគីទាំងពីរបានរៀបចំស្នើសុំគោលការណ៍ពីរដ្ឋាភិបាលរបស់ខ្លួន ដើម្បីបើកច្រកព្រំដែន សម្រាប់បញ្ជូននិងទទួលពលករកម្ពុជា ដោយត្រូវអនុវត្តតាមវិធានសុខាភិបាលនៃប្រទេសទាំងពីរ។ ក្រសួងបានបន្តថា៖ **«នឹងរួមគ្នាបង្ការនិងទប់ស្កាត់ភាពមិនប្រក្រតីនៃការផ្តល់ភាពស្របច្បាប់ជូនពលករ និងរួមគ្នាទប់ស្កាត់ការឆ្លងដែនទៅធ្វើការខុសច្បាប់»**។ ក្រៅពីនោះ ក្រសួងការងារបញ្ជាក់ថា ភាគីទាំងពីរក៏បានឯកភាពគ្នាផ្តល់ការបន្តសុពលភាពលិខិតធ្វើដំណើរពលករកម្ពុជាធ្វើការនៅបរទេស (TD) ជូនពលករកម្ពុជាដែលកំពុងស្នាក់នៅនិងធ្វើការនៅប្រទេសថៃ តាមប្រព័ន្ធស្វ័យប្រវត្តិកម្មនៅពេលខាងមុខ និងពិភាក្សាបច្ចេកទេស និងនីតិវិធីនៃការជ្រើសរើសនិងបញ្ជូនពលករកម្ពុជាទៅធ្វើការនៅប្រទេសថៃ តាមអនុស្សរណៈនៃការយោគយល់គ្នា ក្នុងអំឡុងពេលនៃការរីករាលដាលនៃជំងឺកូវីដ១៩ផងដែរ៕

## ថ្ងៃទី១០ ខែ វិច្ឆិកា ឆ្នាំ២០២០

### ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិប៉ោយប៉ែត បានទទួលពលករខ្មែរ ឆ្លងដែនខុសច្បាប់ ដែលអាជ្ញាធរថៃបញ្ជូនមក មានចំនួន ៣៨នាក់

https://www.facebook.com/GDIOfficial 09-11-2020

ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិប៉ោយប៉ែត នាថ្ងៃទី៩ ខែវិច្ឆិកា ឆ្នាំ២០២០ បានទទួលពលករខ្មែរឆ្លងដែនខុសច្បាប់ ដែលអាជ្ញាធរថៃបញ្ជូនមក មានចំនួន ៣៨នាក់ ស្រី ១៣នាក់ និងកុមារ ០៥នាក់។ ចំពោះពលករខាងលើ ត្រូវបានកម្លាំងនគរបាលប៉ុស្តិ៍ ធ្វើការអប់រំណែនាំ បន្ទាប់មកប្រគល់ជូនក្រុមការងារ ទទួលពលករមជ្ឈមណ្ឌលសំចតប៉ោយប៉ែត ដើម្បីធ្វើការបន្ត។ ជាមួយគ្នានេះដែរ អាជ្ញាធរថៃនៅតែបន្តបិទច្រកទ្វារព្រំដែន មិនទាន់បើកឱ្យអ្នកដំណើរចេញ-ចូលឆ្លងកាត់នៅឡើយ ចំពោះអ្នកជំងឺសង្គ្រោះបន្ទាន់ និងរថយន្តដឹកទំនិញធន់ធំដំណើរការជាធម្មតា៕

### ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិចាំយាម បានទទួលពលករខ្មែរចំនួន ០១នាក់ ពីសមត្ថកិច្ចថៃ ពាក់ព័ន្ធនឹងករណីឆ្លងដែនខុសច្បាប់

https://www.facebook.com/GDIOfficial 09-11-2020

នៅថ្ងៃទី៩ ខែវិច្ឆិកា ឆ្នាំ២០២០ វេលាម៉ោង ១៦និង១០នាទី ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិចាំយាម បានទទួលពលករខ្មែរចំនួន ០១នាក់ ពីសមត្ថកិច្ចថៃ ពាក់ព័ន្ធនឹងករណីឆ្លងដែនខុសច្បាប់។ នគរបាលប៉ុស្តិ៍បានឲ្យដឹងថា ពលករខ្មែរនេះ មាន ឈ្មោះ យុន ហេង ភេទប្រុស អាយុ ៣២ឆ្នាំ ភូមិពានា ឃុំគ្លៀងរាយ ស្រុកក្រជ្រាច ខេត្តព្រៃវែង និងបានធ្វើការសាកសួរ អប់រំណែនាំ ដោយមានការចូលរួមត្រួតពិនិត្យសុខភាព ពីមន្រ្តីចត្តាឡីស័កប្រចាំមាត់ច្រក នូវវិធានការរបស់ក្រសួងសុខាភិបាលផងដែរ។ ដោយឡែកខាងភាគីថៃ នៅតែបន្តបិទច្រកមិនឲ្យអ្នកដំណើរ ចេញ-ចូល ចំណែកទំនិញទទួលបានការអនុញ្ញាត និងអ្នកបើកបររថយន្តចំនួន ០២នាក់ ដែលទទួលបានការអនុញ្ញាត និងបានការឆ្លងកាត់ត្រួតពិនិត្យ ដោយសមត្ថកិច្ចទាំងភាគី កម្ពុជា-ថៃ បានយ៉ាងត្រឹមត្រូវ៕

## ពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ២១០នាក់

https://www.facebook.com/GDIOfficial 08-11-2020

នៅថ្ងៃទី៨ ខែវិច្ឆិកា ឆ្នាំ២០២០ វេលាម៉ោង ១៥និង០០នាទី ភាគីថៃនៅតែបន្តបិទច្រកទ្វារព្រំដែនអន្តរជាតិ ឆង ចម ខេត្តសុរិន្ទ ទល់មុខច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ ជាបណ្ដោះអាសន្ន មិនអនុញ្ញាតឲ្យអ្នកដំណើរ គ្រប់សញ្ជាតិចេញ-ចូល ឆ្លងកាត់ ដើម្បីបង្ការ និងទប់ស្កាត់ការរាតត្បាតនៃជំងឺឆ្លង កូវីដ-១៩។ ក្នុងការបិទច្រកនេះ ភាគីថៃបានលើកលែង ទំនិញដែលទទួលបានការអនុញ្ញាត និងអ្នកបើកបររថយន្តដឹកទំនិញ ដែលទទួលបានការអនុញ្ញាត ព្រមទាំងបានការឆ្លងកាត់ត្រួតពិនិត្យ ដោយសមត្ថកិច្ចទាំងភាគី កម្ពុជា-ថៃ បានត្រឹមត្រូវ និងពលរដ្ឋខ្មែរ ឬពលរដ្ឋថៃ ដែលត្រូវវិលត្រឡប់ចូលប្រទេសរៀងៗខ្លួន។ ចំណែកឯពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ២១០នាក់ ស្រី ១០៤នាក់ និងពលរដ្ឋថៃដែលបានចាកចេញមានចំនួន ០៤នាក់៕

## ភាគីថៃបានបញ្ជូនបុរសជនជាតិខ្មែរចំនួន ០២នាក់ ដែលក្លែងខ្លួនធ្វើជាសង្ឃ ដើម្បីឆ្លងដែនចូលទៅធ្វើការនៅប្រទេសថៃ

https://www.facebook.com/GDIOfficial 08-11-2020

នៅថ្ងៃទី៨ ខែវិច្ឆិកា ឆ្នាំ២០២០ វេលាម៉ោង ១១និង៤០នាទី ភាគីថៃបានបញ្ជូនបុរសជនជាតិខ្មែរចំនួន ០២នាក់ ដែលក្លែងខ្លួនធ្វើជាសង្ឃ ដើម្បីឆ្លងដែនចូលទៅធ្វើការនៅប្រទេសថៃ ហើយត្រូវសមត្ថកិច្ចថៃឃាត់ខ្លួន និងបញ្ជូនមកវិញតាមច្រកទ្វារព្រំដែនអន្តរជាតិភ្នំដី ខេត្តបាត់ដំបង។ ដោយយោងតាមបទបញ្ជារបស់ លោកឧត្តមសេនីយ៍ទោ ប្រធាននាយកដ្ឋានច្រកទ្វារទី១ ប៉ុស្តិ៍បានសហការជាមួយមន្ត្រីចត្តាឡីស័ក ធ្វើការពិនិត្យកំដៅ រួចណែនាំបុគ្គលទាំង ០២នាក់ខាងលើ ធ្វើកិច្ចសន្យា និងបានប្រគល់ជូន ទៅអធិការដ្ឋាននគរបាលស្រុកសំពៅលូន ដើម្បីអនុវត្តតាមនីតិវិធីច្បាប់បន្ត៕

## ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិប៉ោយប៉ែត បានទទួលពលករខ្មែរ ឆ្លងដែនខុសច្បាប់ ដែលអាជ្ញាធរថៃបញ្ជូនមក មានចំនួន ០៧នាក់

https://www.facebook.com/GDIOfficial 07-11-2020

ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិប៉ោយប៉ែត នាថ្ងៃទី៧ ខែវិច្ឆិកា ឆ្នាំ២០២០ បានទទួលពលករខ្មែរ ឆ្លងដែនខុសច្បាប់ ដែលអាជ្ញាធរថៃបញ្ជូនមក មានចំនួន ០៧នាក់ ស្រី ០១នាក់។ ចំពោះពលករខាងលើ ត្រូវបានកម្លាំងនគរបាលប៉ុស្តិ៍ ធ្វើការអប់រំណែនាំ បន្ទាប់មកប្រគល់ជូនក្រុមការងារ ទទួលពលករមជ្ឈមណ្ឌលសំចតប៉ោយប៉ែត ដើម្បីធ្វើការបន្ត។ ជាមួយគ្នានេះដែរ អាជ្ញាធរថៃនៅតែបន្តបិទច្រកទ្វារព្រំដែន មិនទាន់បើកឱ្យអ្នកដំណើរចេញ-ចូលឆ្លងកាត់នៅឡើយ ចំពោះអ្នកជំងឺសង្គ្រោះបន្ទាន់ និងរថយន្តដឹកទំនិញធន់ធំ ដំណើរការជាធម្មតា៕

## ពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ១៤៥នាក់

https://www.facebook.com/GDIOfficial 07-11-2020

នៅថ្ងៃទី៧ ខែវិច្ឆិកា ឆ្នាំ២០២០ វេលាម៉ោង ១៥និង០០នាទី ភាគីថៃនៅតែបន្តបិទច្រកទ្វារព្រំដែនអន្តរជាតិ ឆង ចម ខេត្តសុរិន្ទ ទល់មុខច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ ជាបណ្តោះអាសន្ន មិនអនុញ្ញាតឲ្យអ្នកដំណើរ គ្រប់សញ្ជាតិចេញ-ចូល ឆ្លងកាត់ ដើម្បីបង្ការ និងទប់ស្កាត់ការរាតត្បាតនៃជំងឺឆ្លង កូវីដ-១៩។ ក្នុងការបិទច្រកនេះ ភាគីថៃបានលើកលែង ទំនិញដែលទទួលបានការអនុញ្ញាត និងអ្នកបើកបរយានយន្តដឹកទំនិញ ដែលទទួលបានការអនុញ្ញាត ព្រមទាំងបានការឆ្លងកាត់ត្រួតពិនិត្យ ដោយសមត្ថកិច្ចទាំងភាគី កម្ពុជា-ថៃ បានត្រឹមត្រូវ និងពលរដ្ឋខ្មែរ ឬពលរដ្ឋថៃ ដែលត្រូវវិលត្រឡប់ចូលប្រទេសរៀងៗខ្លួន។ ចំណែកឯពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ១៤៥នាក់ ស្រី ៦៣នាក់៕

## ពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ៤២៤នាក់

https://www.facebook.com/GDIOfficial 06-11-2020

នៅថ្ងៃទី៦ ខែវិច្ឆិកា ឆ្នាំ២០២០ វេលាម៉ោង ១៥និង០០នាទី ភាគីថៃនៅតែបន្តបិទច្រកទ្វារព្រំដែនអន្តរជាតិ ឆង ចម ខេត្តសុរិន្ទ ទល់មុខច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ ជាបណ្តោះអាសន្ន មិនអនុញ្ញាតឲ្យអ្នកដំណើរ គ្រប់សញ្ជាតិចេញ-ចូល ឆ្លងកាត់ ដើម្បីបង្ការ និងទប់ស្កាត់ការរាតត្បាតនៃជំងឺឆ្លង កូវីដ-១៩។ ក្នុងការបិទច្រកនេះ ភាគីថៃបានលើកលែង ទំនិញដែលទទួលបានការអនុញ្ញាត និងអ្នកបើកបរយានយន្តដឹកទំនិញ ដែលទទួលបានការអនុញ្ញាត ព្រមទាំងបានការឆ្លងកាត់ត្រួតពិនិត្យ ដោយសមត្ថកិច្ចទាំងភាគី កម្ពុជា-ថៃ បានត្រឹមត្រូវ និងពលរដ្ឋខ្មែរ ឬពលរដ្ឋថៃ ដែលត្រូវវិលត្រឡប់ចូលប្រទេសរៀងៗខ្លួន។ ចំណែកឯពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ៤២៤នាក់ ស្រី ១៨៦នាក់៕

## ការពង្រឹងសមត្ថភាពក្រុមការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នៅស្រុកពួក

https://www.facebook.com/deputygovernoryousophear/ 06-11-2020

លេខាធិការដ្ឋាន៖ ថ្ងៃសុក្រ ៦រោច ខែកត្តិក ឆ្នាំជូត ទោស័ក ព.ស.២៥៦៤ ត្រូវនឹងថ្ងៃទី០៦ ខែវិច្ឆិកា ឆ្នាំ២០២០ លោកស្រី យូ សុភា អភិបាលរងខេត្តជាប្រធានលេខាធិការដ្ឋាន នៃគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនិស្ស បានអញ្ជើញជាអធិបតីព្រមទាំងមានការអញ្ជើញចូលរួមសម្របសម្រួលពីវាយគ្មិន ពីតំណាងមន្ទីរការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត មន្ទីរសង្គមកិច្ចអតីតយុទ្ធជន និងយុវនីតិសម្បទាខេត្ត មន្ទីរកិច្ចការនារីខេត្ត និងអង្គការមូលនិធិអេ២១ បានចុះបើកវគ្គបណ្តុះបណ្តាលពង្រឹងសមត្ថភាពស្តីពី ការអនុវត្តតួនាទីភារកិច្ច គណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ការបង្ការ ទប់ស្កាត់ អំពើជួញដូរមនុស្ស ការធ្វើចំណាកស្រុកដោយសុវត្ថិភាព និងកិច្ចការពារកុមារពីការរំលោភបំពានផ្សេងៗ ដល់ក្រុមការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សនៅថ្នាក់ស្រុក និងថ្នាក់ឃុំដែលមានសមាសភាពអញ្ជើញចញលរួមពីលោកស្រី អភិបាលរង ស្រុកទទួលបន្ទុក អធិការស្រុក កងរាជអាវុធហត្ថស្រុក មេឃុំ អ.ក.ន.ក នាយករដ្ឋបាលស្រុក ប្រធានស្រុកប្រតិបត្តិ/មណ្ឌលសុខភាពប្រធានការិ.ជុំវិញស្រុក នាយប៉ុស្តិ៍ មេភូមិ អនុភូមិ និងជំនួយការភូមិ សរុប ៥៧នាក់ ស្រី២០នាក់ នៅរដ្ឋបាលសាលាស្រុកពួក។

វគ្គបណ្តុះបណ្តាលនេះប្រព្រឹត្តទៅរយៈពេលពេញមួយថ្ងៃ ដោយមានកិច្ចសហការពីរដ្ឋបាលសាលាស្រុកពួក ដោយមានការគាំទ្រពីរដ្ឋបាលសាលាខេត្ត សៀមរាប និងអង្គការមូលនិធិអេ២១ផងដែរ។

វគ្គបណ្តុះបណ្តាលនេះក្រុមការងារបានធ្វើបទបង្ហាញរួមមានៈ

១.តួនាទីភារកិច្ច យន្តការនិងរចនាសម្ព័ន្ធនៃគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សនិងការរៀបចំរបាយការណ៍

២. វិធីទាំង៧ក្នុងការបង្ការទប់ស្កាត់អំពើជួញដូរមនុស្ស

៣. ការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព

៤. ច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្សនិងអំពើធ្វើអាជីវកម្មផ្លូវភេទ

៥.រូបភាពនៃអំពើជួញដូរមនុស្សនិងការកេងប្រវ័ញ្ចលើកុមារ

៦.ការផ្តល់សេវាជូនជនរងគ្រោះដោយអំពើជួញដូរមនុស្ស និងកិច្ចការពារកុមារ និងការផ្តល់សេវាដល់កុមាររងគ្រោះនៃអង្គការមូលនិធិអេ២១។

## **ការបណ្តុះបណ្តាលពង្រឹងសមត្ថភាពក្រុមការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សនៅស្រុកអង្គរធំ ខេត្តសៀមរាប**

https://www.facebook.com/deputygovernoryousophear/ 06-11-2020

ខេត្តសៀមរាប៖ នៅថ្ងៃព្រហស្បតិ៍ ៥រោច ខែកត្តិក ឆ្នាំជូត ទោស័ក ព.ស.២៥៦៤ ត្រូវនឹងថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ២០២០ ក្រុមការងារលេខាធិការដ្ឋាន ដឹកនាំដោយលោក អ៊ុម ចំរើន អនុប្រធានមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត និងជាប្រធានក្រុមការងារកិច្ចការទេសន្តរប្រវេសន៍ និងជាតំណាងលោកជំទាវប្រធានលេខាធិការដ្ឋាន គ.ខ.ប.ជ និងមានការអញ្ជើញចូលរួមសម្របសម្រួលពីវាយគ្មិន ពីតំណាងមន្ទីរការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត មន្ទីរសង្គមកិច្ចអតីតយុទ្ធជន និងយុវនីតិសម្បទាខេត្ត មន្ទីរកិច្ចការនារីខេត្ត និងអង្គការមូលនិធិអេ២១ បានចុះក្នុងបើកវគ្គបណ្តុះបណ្តាលពង្រឹងសមត្ថភាពស្តីពី ការអនុវត្តតួនាទីភារកិច្ច គណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ការបង្ការ ទប់ស្កាត់ អំពើជួញដូរមនុស្ស ការធ្វើចំណាកស្រុកដោយសុវត្ថិភាព និងកិច្ចការពារកុមារពីការរំលោភបំពានផ្សេងៗ ដល់ក្រុមការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សនៅថ្នាក់ស្រុក និងថ្នាក់ឃុំដែលមានសមាសភាពអញ្ជើញចូលរួមពីលោកស្រី អភិបាលរង ស្រុកទទួលបន្ទុក អធិការស្រុក កងរាជអាវុធហត្ថស្រុក មេឃុំ អ.ក.ន.ក នាយករដ្ឋបាលស្រុក ប្រធានស្រុកប្រតិបត្តិ/មណ្ឌលសុខភាពប្រធានការិ.ជុំវិញស្រុក នាយប៉ុស្តិ៍ មេភូមិ អនុភូមិ និងជំនួយការភូមិ សរុប ៤៥នាក់ ស្រី២១នាក់ នៅរដ្ឋបាលសាលាស្រុកអង្គរធំ។

វគ្គបណ្តុះបណ្តាលនេះក្រុមការងារបានធ្វើបទបង្ហាញរួមមានៈ

១.តួនាទីភារកិច្ច យន្តការនិងរចនាសម្ព័ន្ធនៃគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សនិងការរៀបចំរបាយការណ៍

២. វិធីទាំង៧ក្នុងការបង្ការទប់ស្កាត់អំពើជួញដូរមនុស្ស

៣. ការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព

៤. ច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្សនិងអំពើធ្វើអាជីវកម្មផ្លូវភេទ

៥.រូបភាពនៃអំពើជួញដូរមនុស្សនិងការកេងប្រវ័ញ្ចលើកុមារ

៦.ការផ្តល់សេវាជូនជនរងគ្រោះដោយអំពើជួញដូរមនុស្ស និងកិច្ចការពារកុមារ និងការផ្តល់សេវាដល់កុមាររងគ្រោះនៃអង្គការមូលនិធិអេ២១។

## វគ្គបណ្តុះបណ្តាលស្តីពី ការបង្ការទប់ស្កាត់អំពើជួញដូរមនុស្ស និងការរំលោភបំពានផ្លូវភេទលើកុមារនៅតាមសហគមន៍

https://www.facebook.com/deputygovernoryousophear/ 05-11-2020

ខេត្តសៀមរាប៖ នាថ្ងៃទី០៤ ខែវិច្ឆិកា ឆ្នាំ២០២០ លេខាធិការដ្ឋានគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ខ.ប.ជ) ខេត្តសៀមរាប មន្ទីរអប់រំ យុវជន និងកីឡា ខេត្តសៀមរាប និងអង្គការសកម្មភាពដើម្បីកុមារ (APLE)បានបន្តសហការរៀបចំវគ្គបណ្តុះបណ្តាលស្តីពី ការបង្ការទប់ស្កាត់អំពើជួញដូរមនុស្សនិងការរំលោភបំពានផ្លូវភេទលើកុមារនៅតាមសហគមន៍ ដល់ កុមារ និងយុវជនចំនួន៥២នាក់ នៅវិទ្យាល័យដំដែក ស្រុកសូទ្រនិគម។

## ថ្ងៃទី១១ ខែ វិច្ឆិកា ឆ្នាំ២០២០

## ឧត្តមសេនីយ៍ត្រី សិទ្ធិ ឡោះ កោតសរសើរនគរបាលការពារព្រំដែនគោកទាំង០៤ រក្សាសន្តិសុខ សុវត្ថិភាពជូនប្រជាពលរដ្ឋរស់នៅតាមព្រំដែន និងទប់ស្កាត់បទល្មើសឆ្លងដែនខុសច្បាប់

http://cambodiapolice.com/policekh/ 6:06 pm 10 វិច្ឆិកា 2020

បន្ទាយមានជ័យ ៖ ដើម្បីសន្តិសុខ សណ្តាប់ធ្នាប់ សុវត្ថិភាព នៅតាមបន្ទាត់ព្រំដែនថ្ងៃទី០៩ ខែវិច្ឆិកា ឆ្នាំ ២០២០ នៅស្នងការដ្ឋាននគរបាលខេត្តបន្ទាយមានជ័យ បានរៀបចំពិធីប្រជុំពង្រឹងភារកិច្ចដល់នគរបាលវរសេនាតូចការពារព្រំដែនគោកទាំង០៤ ក្រោមអធិបតីភាព លោកឧត្តមសេនីយ៍ត្រី សិទ្ធិ ឡោះ ស្នងការនគរបាលខេត្តបន្ទាយមានជ័យ និងមានការចូលរួមពីលោកឧត្តមសេនីយ៍ត្រី រ៉ែម វីរៈ ស្នងការរង ផែនការងារសេនាធិការដ្ឋានលោកឧត្តមសេនីយ៍ត្រី វង្ស វិត ស្នងការរង ផែនការងារធនធានមនុស្សនិងលោកឧត្តមសេនីយ៍ត្រី អ៊ុំ សុផល ស្នងការរងផែនការងារព្រំដែនគោក ។

លោកវរសេនីយ៍ត្រី អ៊ុំ សុផល ស្នងការរងផែនការងារ ព្រំដែនគោកបានឲ្យធ្វើសេចក្តីរាយការណ៍ថា៖ ក្នុងខែតុលាឆ្នាំ២០២០កន្លងមកនេះ នគរបាលនគរបាលវរសេនាតូចការពារព្រំដែនគោកលេខ៨១៥ និង ៩១១ បានធ្វើការទប់ស្កាត់ប្រជាពលរដ្ឋបំរុងឆ្លងដែនដោយខុសច្បាប់ទៅធ្វើការនៅប្រទេសថៃ ចំនួន០៤លើក មានមនុស្សចំនួន៤៥នាក់ ស្រី១៧នាក់ កុមារចំនួន០៦នាក់។ ពលករដែលចូលមកប្រទេសកម្ពុជា តាមខ្សែបន្ទាត់ព្រំដែនរយៈពេល០១ខែ មានចំនួន៧៤លើក សរុបចំនួន៨,២៨៨នាក់ ស្រី៣.៨០១នាក់ កុមារចំនួន៧២៩នាក់ ។ ជាមួយគ្នានោះដែរ កម្លាំងនគរបាលវរសេនាតូចការពារព្រំដែនគោកលេខ៨៩១ បានបង្ក្រាបមុខសញ្ញាចែកចាយគ្រឿងញៀនម្នាក់ប្រគល់ឲ្យអធិការដ្ឋាននគរបាលក្រុងប៉ោយប៉ែត និងកម្លាំងវរសេនាតូចការពារព្រំដែនគោកលេខ៩១១ សហការជាមួយកម្លាំងអធិការដ្ឋាននគរបាលក្រុងប៉ោយប៉ែត ចាប់ឃាត់ខ្លួនជនសង្ស័យម្នាក់ពីបទទទួលផលចោរកម្ម ។

ថ្លែងនាឱកាសនោះ លោកឧត្តមសេនីយ៍ត្រី សិទ្ធិ ឡោះ ស្នងការនគរបាលខេត្តបន្ទាយមានជ័យ បានថ្លែងនូវការកោតសរសើរដល់កងកម្លាំងនគរបាលវរសេនាតូចការពារព្រំដែនគោកទាំង០៤ ដែលបានយកចិត្តទុកដាក់កក្នុងការងាររក្សាបាននូវសន្តិសុខ សណ្តាប់ធ្នាប់ជូនប្រជាពលរដ្ឋនៅតាមបន្ទាត់ព្រំដែន និងការពារបូរណភាពទឹកដី។ ជាមួយគ្នានោះដែរទន្ទឹមនឹងតួនាទីការពារបូរណភាពទឹកដី និងប្រជាពលរដ្ឋរស់នៅតាមបន្ទាត់ព្រំដែនកម្លាំងនរបាលវរសេនាតូចទាំង០៤បានចូលរួមកិច្ចការងារសង្គមជាច្រើន។ ជាក់ស្តែងថ្មីៗនេះបានសហការជាមួយបណ្តាកងកម្លាំងប្រដាប់អាវុធ អាជ្ញាធរមូលដ្ឋាន ជួយជន្លៀសប្រជាពលរដ្ឋរងគ្រោះដោយសារទឹកជំនន់មករកទីទួលសុវត្ថិភាព។

លោកឧត្តមសេនីយ៍ស្នងការបានបញ្ជាក់ថា ជាមួយនឹងស្ថានភាពទឹកជំនន់បានស្រក់ចុះនេះ សូមលោកនាយប៉ុស្តិ៍ការពារព្រំដែនក៏ដូចជាបញ្ជាការដ្ឋាន ដែលទទួលរងនូវការលិចលង់កន្លងមក ត្រូវរៀបចំជួសជុលសម្អាត់ទីធ្លាឡើងវិញ ពិសេសគឺត្រូវស្តារលេណដ្ឋានឡើងវិញ និងគ្រប់គ្រងអាវុធយុទ្ធភ័ណ្ឌឲ្យបានល្អ នឹងត្រូវមានវិធានការទប់ស្កាត់ពលករលួចឆ្លងដែនដោយខុសច្បាប់ ដោយធ្វើការអប់រំដល់ពួកគាត់អំពីការធ្វើចំណាកស្រុកដោយប្រខុសច្បាប់និងប្រថុយប្រថាននាំឲ្យមានគ្រោះថ្នាក់។ លោកឧត្តមសេនីយ៍ស្នងការបានផ្ដាំផ្ញើដល់នគរបាលាការពារព្រំដែនទាំងអស់ត្រូវមានសាមគ្គីភាពផ្ទៃក្នុងឲ្យបានរឹងមាំ សហការឲ្យបានជិតស្និតជាមួយប្រជាពលរដ្ឋ អាជ្ញាធរមូលដ្ឋាន និងសមត្ថកិច្ចពាក់ព័ន្ធ និងត្រូវមានកិច្ចសហការល្អជាមួយសមត្ថកិច្ចនៃប្រទេសជិតខាង ដើម្បីរក្សាឲ្យបាននូវព្រំដែនសន្តិភាព ស្ថិរភាព កិច្ចប្រតិបត្តិការ និងការអភិវឌ្ឍន៍ ជាងនេះទៀតគឺត្រូវរួមគ្នាទប់ស្កាត់នូវជំងឺកូវីដ-១៩ កុំមានការឆ្លងរាលដាលដល់សហគមន៍ ៕

## ពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ២៤៣នាក់

https://www.facebook.com/GDIOfficial 10-11-2020

នៅថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០២០ វេលាម៉ោង ១៥និង០០នាទី ភាគីថៃនៅតែបន្តបិទច្រកទ្វារព្រំដែនអន្តរជាតិ ឆងចម ខេត្តសុរិន្ទ ទល់មុខច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ ជាបណ្ដោះអាសន្ន មិនអនុញ្ញាតឲ្យអ្នកដំណើរ គ្រប់សញ្ជាតិចេញ-ចូល ឆ្លងកាត់ ដើម្បីបង្ការនិងទប់ស្កាត់ការរាតត្បាតនៃជំងឺឆ្លងកូវីដ-១៩។ ក្នុងការបិទច្រកនេះ ភាគីថៃបានលើកលែង ទំនិញដែលទទួលបានការអនុញ្ញាត និងអ្នកបើកបររថយន្តដឹកទំនិញ ដែលទទួលបានការអនុញ្ញាត ព្រមទាំងបានការឆ្លងកាត់ត្រួតពិនិត្យ ដោយសមត្ថកិច្ចទាំងភាគី កម្ពុជា-ថៃ បានត្រឹមត្រូវ និងពលរដ្ឋខ្មែរ ឬពលរដ្ឋថៃ ដែលត្រូវវិលត្រឡប់ចូលប្រទេសរៀងៗខ្លួន។ ចំណែកឯពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ២៤៣នាក់ ស្រី១១៥នាក់ និងបានទទួលពលរដ្ឋខ្មែរចំនួន០២នាក់ពីភាគីថៃពាក់ព័ន្ធនឹងបទលួចចូលកាប់ឈើខុសច្បាប់ក្នុងទឹកដីប្រទេសថៃ៕

## ថ្ងៃទី១២ ខែ វិច្ឆិកា ឆ្នាំ២០២០

## ផ្សព្វផ្សាយច្បាប់ ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ផលប៉ះពាល់ នៃការធ្វើចំណាកស្រុក ដោយប្រថុយប្រថាន

https://www.rasmeinews.com/ 10 November, 2020 បញ្ចូលអត្ថបទដោយ Houputh Visal

**ដោយៈ ទេព មង្គល / កណ្ដាលៈ** *លោកស្រី ហ៊ុន កុសនី អភិបាលរង ខេត្តកណ្តាល និងជាអនុប្រធាន អចិន្ត្រៃយ៍ គណៈកម្មាធិការខេត្ត ប្រយុទ្ធប្រឆាំងអំពើ ជួញដូរមនុស្ស បានអំពាវនាវដល់ប្រជាពលរដ្ឋទាំងអស់ ត្រូវអប់រំកូនចៅ ក្រុមគ្រួសារ បងប្អូន ញាតិមិត្ត កុំឲ្យចាញ់បោកកលល្បិច ជនខិលខូចមួយចំនួន ក្នុងការចំណាកស្រុក ដោយប្រថុយប្រថាន និងខុសច្បាប់ ដែលជាមូលហេតុ ធ្វើឲ្យពួកគាត់ងាយធ្លាក់ ទៅក្នុងស្ថានភាព នៃការជួញដូរមនុស្ស និងការកេងប្រវ័ញ្ចផ្លូវភេទ និងកម្លាំងពលកម្ម ជាពិសេស ត្រូវប្រុងប្រយ័ត្ន ចំពោះឆ្លងរាលដាលនៃ ជំងឺលោកផ្តាវដង្ហើម កូវីដ ១៩។* លោកស្រី បានថ្លែងដូច្នេះ នៅក្នុងវេទិកាផ្សព្វផ្សាយច្បាប់ ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ផលប៉ះពាល់ នៃការធ្វើចំណាកស្រុក ដោយប្រថុយប្រថាន និងការបង្ការទប់ស្កាត់ ការឆ្លងរីករាលដាល នៃជំងឺកូវីដ១៩ នៅក្នុងឃុំឈើខ្មៅ ស្រុកកោះធំ កាលពីព្រឹកថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០២០ ដោយមានការចូលរួមពី លោកស្រី ឧត្តមសេនីយ៍ត្រី ឈឹម វណ្ណនី ស្នងការរង ខេត្តកណ្ដាល លោកស្រី អភិបាលរងស្រុក មន្ទីរពាក់ព័ន្ធ ប្រជាពលរដ្ឋ និងពលករ ពលការិនី ជាង ៦០ នាក់។ លោកស្រី ហ៊ុន កុសនី បានបញ្ជាក់ថាៈ បច្ចុប្បន្ន

នេះ ជនល្មើស កាន់តែមានល្បិចកលខ្ពស់ ហើយរូបភាព នៃអំពើជួញដូរមនុស្ស មិនត្រឹមតែជាការជួញដូរ កេងប្រវ័ញ្ច កម្លាំងពលកម្ម និងផ្លូវភេទតែប៉ុណ្ណោះទេ គឺថែមទាំងមានជួញដូរសិរីរាង្គ បទល្មើសរត់ពន្ធ ជួញដូរទារកឆ្លងដែន ជាពិសេស គឺការពរពោះជំនួស ដែលអំពើនេះ គឺជារឿងដែលអមនុស្សធម៌បំផុត ដែលបញ្ហាទាំងនេះ គឺតម្រូវឲ្យ គណៈកម្មាធិការប្រយុទ្ធ ប្រឆាំងអំពើជួញដូរមនុស្ស និងអាជ្ញាធរគ្រប់លំដាប់ថ្នាក់ ត្រូវតែដាក់វិធានការ ស៊ើបអង្កេត ស្រាវជ្រាវ និងបង្ក្រាប ឲ្យបានទាន់ពេលវេលា។

ក្នុងឱកាសនោះដែរ លោកស្រីអភិបាលរងខេត្ត ក៏បានពន្យល់ណែនាំ ដល់ប្រជាពលរដ្ឋ និងកម្មករ កម្មការិនីទាំងអស់ថា ការធ្វើចំណាកស្រុក ឆ្លងដែន ដោយគ្មានឯកសារ ផ្លូវច្បាប់ត្រឹមត្រូវ បានធ្វើឲ្យពលករទាំងនោះ ត្រូវបានទទួលរង ការកេងប្រវ័ញ្ចគ្រប់រូបភាព ដូចជាទទួលរងគ្រោះ ដោយការចាប់ឃាត់ខ្លួន ដាក់ពន្ធនាគារ ការផាកពិន័យ ការចាប់បញ្ជូនត្រឡប់ ការមិនផ្តល់ប្រាក់កម្រៃ ពលកម្មពេញលេញ ការបញ្ជូនបន្ត ទៅធ្វើការ ពីកន្លែងមួយ ទៅកន្លែងមួយ ឬនៅឆ្ងាយ ដែលមិនអាចទំនាក់ទំនង ទៅគ្រួសារបាន មានការដកហូត អត្តសញ្ញាណប័ណ្ណ លិខិតឆ្លងដែន ការធ្វើទារុណកម្ម រហូតបាត់បង់ជីវិត ក៏មាន។ លោកស្រី បានបន្តថាៈ ដើម្បីធ្វើការនៅក្រៅប្រទេស ដោយស្របច្បាប់ គឺពលករ ពលការនី ត្រូវមានអាយុចាប់ពី១៨ ឆ្នាំឡើងទៅ ហើយត្រូវទៅជួប ជាមួយមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងក្រសួងពាក់ព័ន្ធ ពីព្រោះកន្លែងនោះ អាចជួយអ្នករកការងារ និងអាចជួយចុះឈ្មោះអ្នក ជាមួយក្រុមហ៊ុន ជ្រើសរើសពលករ ដែលស្របច្បាប់ ដែលទទួលស្គាល់ ដោយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈនិងមន្ទីរការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ត្រូវមានលិខិតឆ្លងដែន និងមានឯកសារពាក់ព័ន្ធនានា។ នៅក្នុងឱកាសនោះដែរ លោកស្រី ទេស សុភាព អភិបាលរង ស្រុកកោះធំ បានឲ្យដឹងថា ស្រុកកោះធំ មានអ្នកចំណាកស្រុក ទៅក្រៅប្រទេស ចំនួន ៩៧១ នាក់ ស្រី ៤៩២ នាក់ និងត្រឡប់ចូលស្រុកវិញ ២៧ នាក់ មកពីប្រទេសចិន កូរ៉េ ថៃ ម៉ាឡេស៊ី ឥណ្ឌូណេស៊ី និងប្រទេសហ្វីលីពីន ដោយបានឆ្លងកាត់ ការដាក់តាមមណ្ឌលចត្តាឡីស័ក ចំនួន ១៤ ថ្ងៃ មុននឹងអនុញ្ញាតអោយទៅជួបជុំ ជាមួយក្រុមគ្រួសារវិញ៕/V

## វគ្គបណ្តុះបណ្តាលពង្រឹងសមត្ថភាពក្រុមការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នៅស្រុកក្រឡាញ់ ខេត្តសៀមរាប

https://www.facebook.com/deputygovernoryousophear/ 11-11-2020

ថ្ងៃពុធ ១១រោច ខែកត្តិក ឆ្នាំជូត ទោស័ក ព.ស.២៥៦៤ ត្រូវនឹងថ្ងៃទី១១ ខែ វិច្ឆិកា ឆ្នាំ២០២០ ក្រុមការងារលេខាធិការដ្ឋាន ដឹកនាំដោយឧត្តមសេនីយ៍ត្រី ដួង ថាវរី ស្នងការរងនគរបាលខេត្ត និងជាតំណាងលោកជំទាវប្រធានលេខាធិការដ្ឋាន គ.ខ.ប.ជ និងមានការអញ្ជើញចូលរួមសម្របសម្រួលពីវាយគ្មិន ពីតំណាងមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត មន្ទីរសង្គមកិច្ចអតីតយុទ្ធជន និងយុវនីតិសម្បទាខេត្ត មន្ទីរកិច្ចការនារីខេត្ត និងអង្គការមូលនិធិអេ២១ ក្នុងវគ្គបណ្តុះបណ្តាលពង្រឹងសមត្ថភាពស្តីពី ការអនុវត្តតួនាទីភារកិច្ច គណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ការបង្ការ ទប់ស្កាត់ អំពើជួញដូរមនុស្ស ការធ្វើចំណាកស្រុកដោយសុវត្ថិភាព និងកិច្ចការពារកុមារពីការរំលោភបំពានផ្សេងៗ ដល់ក្រុមការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សនៅថ្នាក់ស្រុក និងថ្នាក់ឃុំ ដែលមានសមាសភាពអញ្ជើញចញូលរួមពីលោកស្រី អភិបាលរង ស្រុកទទួលបន្ទុក អធិការស្រុក កងរាជអាវុធហត្ថស្រុក មេឃុំ អ.ក.ន.ក នាយករដ្ឋបាលស្រុក ប្រធានស្រុកប្រតិបត្តិ/មណ្ឌលសុខភាពប្រធានការិ.ជុំវិញស្រុក នាយប៉ុស្តិ៍ មេភូមិ អនុភូមិ និងជំនួយការភូមិ សរុប ៤៥នាក់ ស្រី១៤នាក់ នៅរដ្ឋបាលសាលាស្រុកពួក។

វគ្គបណ្តុះបណ្តាលនេះប្រព្រឹត្តទៅរយៈពេលពេញមួយថ្ងៃ ដោយមានកិច្ចសហការពីរដ្ឋបាលស្រុកស្រីស្នំ និងមានការគាំទ្រពីរដ្ឋបាលសាលាខេត្ត និងអង្គការមូលនិធិអេ២១ផងដែរ។ វគ្គបណ្តុះបណ្តាលនេះក្រុមការងារបានធ្វើបទបង្ហាញរួមមាន:

១.តួនាទីភារកិច្ច យន្តការនិងរចនាសម្ព័ន្ធនៃគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សនិងការរៀបចំរបាយការណ៍

២. វិធីទាំង៧ក្នុងការបង្ការទប់ស្កាត់អំពើជួញដូរមនុស្ស

៣. ការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព

៤. ច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្សនិងអំពើធ្វើអាជីវកម្មផ្លូវភេទ

៥.រូបភាពនៃអំពើជួញដូរមនុស្សនិងការកេងប្រវ័ញ្ចលើកុមារ

៦.ការផ្តល់សេវាជូនជនរងគ្រោះដោយអំពើជួញដូរមនុស្ស និងកិច្ចការពារកុមារ និងការផ្តល់សេវាដល់កុមាររងគ្រោះនៃអង្គការមូលនិធិអេ២១។

## ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិប៉ោយប៉ែត បានទទួលពលករខ្មែរឆ្លងដែនខុសច្បាប់ ដែលអាជ្ញាធរថៃបញ្ជូនមក មានចំនួន២៧នាក់

https://www.facebook.com/GDIOfficial 11-11-2020

ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិប៉ោយប៉ែត នាយប់ថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០២០ បានទទួលពលករខ្មែរ ឆ្លងដែនខុសច្បាប់ ដែលអាជ្ញាធរថៃបញ្ជូនមក មានចំនួន ២៧នាក់ ស្រី ១៤នាក់ និងកុមារ ០៣នាក់។ ចំពោះពលករខាងលើ ត្រូវបានកម្លាំងនគរបាលប៉ុស្តិ៍ ធ្វើការអប់រំណែនាំ បន្ទាប់មកប្រគល់ជូនក្រុមការងារ ទទួលពលករមជ្ឈមណ្ឌលសំចតប៉ោយប៉ែត ដើម្បីធ្វើការបន្ត។ ជាមួយគ្នានេះដែរ អាជ្ញាធរថៃនៅតែបន្តបិទច្រកទ្វារព្រំដែន មិនទាន់បើកឱ្យអ្នកដំណើរចេញ-ចូលឆ្លងកាត់នៅឡើយ ចំពោះអ្នកជំងឺសង្គ្រោះបន្ទាន់ និងរថយន្តដឹកទំនិញធន់ធំដំណើរការជាធម្មតា៕

## ពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ១៨២នាក់

https://www.facebook.com/GDIOfficial 11-11-2020

នៅថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០២០ វេលាម៉ោង ១៥និង០០នាទី ភាគីថៃនៅតែបន្តបិទច្រកទ្វារព្រំដែនអន្តរជាតិ ឆង ចម ខេត្តសុរិន្ទ ទល់មុខច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ ជាបណ្តោះអាសន្ន មិនអនុញ្ញាតឲ្យអ្នកដំណើរ គ្រប់សញ្ជាតិចេញ-ចូល ឆ្លងកាត់ដើម្បីបង្ការ និងទប់ស្កាត់ការរាតត្បាតនៃជំងឺឆ្លងកូវីដ-១៩។ ក្នុងការបិទច្រកនេះ ភាគីថៃបានលើកលែង ទំនិញដែលទទួលបានការអនុញ្ញាត និងអ្នកបើកបររថយន្តដឹកទំនិញដែលទទួលបានការអនុញ្ញាត ព្រមទាំងបានការឆ្លងកាត់ត្រួតពិនិត្យ ដោយសមត្ថកិច្ចទាំងភាគី កម្ពុជា-ថៃ បានត្រឹមត្រូវ និងពលរដ្ឋខ្មែរ ឬពលរដ្ឋថៃ ដែលត្រូវវិលត្រឡប់ចូលប្រទេសរៀងៗខ្លួន។ ចំណែកឯពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ១៨២នាក់ ស្រី ៧៩នាក់ និងបានពលរដ្ឋខ្មែរចំនួន ០១នាក់ ពីភាគីថៃ ពាក់ព័ន្ធនឹងបទលួចចូលកាប់ឈើខុសច្បាប់ ក្នុងទឹកដីប្រទេសថៃ៕

## ពលរដ្ឋខ្មែរចំនួន៨នាក់បានឆ្លងដែនចូលប្រទេសថៃដោយខុសច្បាប់ ដើម្បីរកការងារធ្វើនៅប្រទេសថៃ ត្រូវទាហានឆុតខ្មៅថៃចាប់ខ្លួន

https://www.facebook.com/ 11-11-2020 ទឹកចិត្ត ពលករ ឆ្លងដែន

ឃើញហើយអាណិតពលរដ្ឋខ្មែរណាស់ កាលថ្ងៃមិញ 10-11-2020 នេះពលរដ្ឋខ្មែរចំនួន8នាក់ បានឆ្លងដែនចូលប្រទេសថៃដោយខុសច្បាប់ ដើម្បីរកការងារធ្វើនៅប្រទេសថៃ ត្រូវទាហានឆុតខ្មៅថៃចាប់បាន នៅស្រុកអារាញ់ ខេត្តស្រះកែវ ប្រទេសថៃ។ (អំពីខ្ញុំ ទឹកចិត្ត ពលករ ឆ្លងដែន) 11-11-2020

## ពលករខ្មែរ ជាង៣,០០០នាក់ ធ្វើការនៅក្រុមហ៊ុន GFN នៅតំបន់ណងយ៉ៃ ខេត្តឈុនបុរី ប្រទេសថៃ បានរួមគ្នាធ្វើបាតុកម្មទាមទារនូវអត្ថប្រយោជន៍មួយចំនួន

https://www.facebook.com/CentralCambodiaOrg/ 11/11/2020

Breaking News ព័ត៌មានពីប្រទេសថៃ៖ នៅល្ងាចថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០២០នេះ ពលករខ្មែរ ជាង ៣,០០០នាក់ធ្វើការ នៅក្រុមហ៊ុន GFN (រោងចក្រកែច្នៃអាហារ) នៅតំបន់ ណងយ៉ៃ ខេត្តឈុនបុរី ប្រទេសថៃ បានរួមគ្នាធ្វើបាតុកម្មទាមទារនូវអត្ថប្រយោជន៍មួយចំនួន។ ករណីដែលឈានដល់ការបាតុកម្មនេះគឺដោយសារមូលហេតុចម្បងៗ៣ដូចខាងក្រោមនេះ

១. ពលករតម្រូវចេញថ្លៃបន្ទប់ ថ្លៃទឹក និងថ្លៃភ្លើង

២. តម្លៃសេវាកម្មនិងប្រាក់ចំណូលរបស់ពលករធ្លាក់ចុះ

៣. រោងចក្រតម្រូវឲ្យពលករទាំងអស់ទិញអីវ៉ាន់តែក្នុងរោងចក្រ ព្រោះខ្លាចកូវីដ១៩ មិនអោយចេញក្រៅ៕

សរុបសេចក្តីមកវិញគឺថាពលករខ្មែរធ្វើការច្រើន ប៉ុន្តែចំណូលតិចជាងកម្លាំងពលកម្មឆ្ងាយខុសពីកាលមុន៕ សូមបញ្ជាក់បន្ថែមផងដែរថា យោងតាមការឲ្យដឹងពីពលករនៅឈុនបុរីថា«ករណីនេះកើតឡើងជាង៣ខែមកហើយ ប៉ុន្តែនៅមិនទាន់មានដំណោះស្រាយដល់ពលករខ្មែរនៅឡើយរហូតឈានដល់តំណាក់កាលបាតុកម្មនេះ»៕

# ថ្ងៃទី១៣ ខែ វិច្ឆិកា ឆ្នាំ២០២០

## ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិចាំយាម បានទទួលពលករខ្មែរចំនួន ០២នាក់ ពីសមត្ថកិច្ចថៃ ពាក់ព័ន្ធនឹងករណីឆ្លងដែនខុសច្បាប់

https://www.facebook.com/GDIOfficial 12-11-2020

នៅថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០២០ ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិចាំយាម បានទទួលពលករខ្មែរចំនួន ០២នាក់ ពីសមត្ថកិច្ចថៃ ពាក់ព័ន្ធនឹងករណីឆ្លងដែនខុសច្បាប់។ នគរបាលប៉ុស្តិ៍បានឲ្យដឹងថា ពលករខ្មែរទាំង ០២នាក់នេះ មាន ១-ឈ្មោះ ធឿន ផង ភេទប្រុស អាយុ ២០ឆ្នាំ ភូមិសំរោង ឃុំមេទឹក ស្រុកបាកាន ខេត្តពោធិ៍សាត់ , ២-ឈ្មោះ ឈឹម ឡឿន ភេទប្រុស អាយុ ៣៩ឆ្នាំ ភូមិគូស ឃុំគូស ស្រុកត្រាំកក់ ខេត្តតាកែវ និងបានធ្វើការសាកសួរ អប់រំណែនាំ ដោយមានការចូលរួមត្រួតពិនិត្យសុខភាព ពីមន្ត្រីចត្តាឡីស័កប្រចាំមាត់ច្រក នូវវិធានការរបស់ក្រសួងសុខាភិបាលផងដែរ។ ដោយឡែកខាងភាគីថៃ នៅតែបន្តបិទច្រកមិនឲ្យអ្នកដំណើរ ចេញ-ចូល ចំណែកទំនិញទទួលបានការអនុញ្ញាត និងអ្នកបើកបររថយន្តចំនួន ០២នាក់ ដែលទទួលបានការអនុញ្ញាត និងបានការឆ្លងកាត់ត្រួតពិនិត្យ ដោយសមត្ថកិច្ចទាំងភាគី កម្ពុជា-ថៃ បានយ៉ាងត្រឹមត្រូវ៕

## ពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ២០១នាក់

https://www.facebook.com/GDIOfficial 12-11-2020

នៅថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០២០ វេលាម៉ោង ១៥និង០០នាទី ភាគីថៃនៅតែបន្តបិទច្រកទ្វារព្រំដែនអន្តរជាតិ ឆង ចម ខេត្តសុរិន្ទ ទល់មុខច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ ជាបណ្តោះអាសន្ន មិនអនុញ្ញាតឲ្យអ្នកដំណើរ គ្រប់សញ្ញាតិចេញ-ចូល ឆ្លងកាត់ ដើម្បីបង្ការនិងទប់ស្កាត់ការរាតត្បាតនៃជំងឺឆ្លងកូវីដ-១៩។ ក្នុងការបិទច្រកនេះ ភាគីថៃបានលើកលែង ទំនិញដែលទទួលបានការអនុញ្ញាត និងអ្នកបើកបររថយន្តដឹកទំនិញដែលទទួលបានការអនុញ្ញាត ព្រមទាំងបានការឆ្លងកាត់ត្រួតពិនិត្យ ដោយសមត្ថកិច្ចទាំងភាគី កម្ពុជា-ថៃ បានត្រឹមត្រូវ និងពលរដ្ឋខ្មែរ ឬពលរដ្ឋថៃ ដែលត្រូវវិលត្រឡប់ចូលប្រទេសរៀងៗខ្លួន។ ចំណែកឯពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ២០១នាក់ ស្រី ១០២នាក់ និងបានពលរដ្ឋខ្មែរចំនួន ០២នាក់ ពីភាគីថៃ ពាក់ព័ន្ធនឹងបទលួចចូលកាប់ឈើខុសច្បាប់ ក្នុងទឹកដីប្រទេសថៃ៕

## ពលករខ្មែរ ប្រុស ស្រី១៩នាក់ និងមេខ្យល់ថៃ២នាក់ត្រូវតម្រួតថៃចាប់ឃុំខ្លួន

http://nokorwatnews.com/archives/ 12-11-2020

ខេត្តបន្ទាយមានជ័យ៖ សមត្ថកិច្ចនគរបាលអន្តោប្រវេសន៍ខេត្តស្រះកែវកាលពីថ្ងៃទី១១ វិច្ឆិកា ២០២០ បានបញ្ជាឲ្យក្រុមស៊ើបអង្កេត សហការជាមួយសមត្ថកិច្ចពាក់ព័ន្ធ សមត្ថកិច្ចទាហានកងរយទី១២០៥ នគរបាលទេសចរណ៍ រួមគ្នាចាប់ឃុំឈ្មោះ ថៈរ៉ាច់ផៃ សុវិរ៉ាល អាយុ២៧ឆ្នាំ ជាមេខ្យល់ជនជាតិថៃ និងឈ្មោះ បូត រឿន អាយុ១៩ឆ្នាំ សញ្ជាតិខ្មែរ ព្រមទាំងបក្ខពួកជនជាតិខ្មែរ៨នាក់ សរុប៩នាក់ ព្រមទាំងវត្ថុតាង រថយន្តដឹកអ្នកដំណើរ ទូរ៉ើសម៉ាកតូយ៉ូតា ពាក់ស្លាកលេខ ខ-3805 ឈុន បុរី ចំនួនមួយគ្រឿង នៅបរិវេណថ្នល់ចូលវត្ត បានទុន ឃុំ បានដានស្រុកអារញ្ញ ខេត្តស្រះកែវ។

បន្ទាប់មក ក្រុមសមត្ថកិច្ចខាងលើ បានរួមគ្នាចាប់ឃុំឈ្មោះ ម៉ាណប ទ្រង់ទ្រព្យ ភេទប្រុសអាយុ៤២ឆ្នាំ មេខ្យល់ ជនជាតិថៃ នៅឃុំ ណង វ៉ា ស្រុក ផៅ ធះកន ខេត្តស្រះកែវ ,នាង សាកួន ផន អាយុ២០ឆ្នាំ ជនជាតិខ្មែរ ព្រមទាំងបក្ខពួកជនជាតិខ្មែរ៩នាក់ទៀត សរុប១០នាក់ រួមទាំងវត្ថុតាង រថយន្តដឹកអ្នកដឹកអ្នកដំណើរម៉ាក (ទូរ៉ើស) ពាក់ស្លាកលេខ 34-19 68 ក្រុងថេប ចំនួនមួយគ្រឿង នៅបរិវេណលើដងផ្លូវមុខផ្លូវចូលវត្ត បាន ទុន ឃុំ បាន ដានស្រុកអារញ្ញ ខេត្តស្រះកែវ ដូចគ្នា ដោយសមត្ថកិច្ចនគរបាលអន្តោប្រវេសន៍ បាននាំរថយន្តម៉ាក BMW(SMART PATROL CAR:SPC)គាំទ្រក្នុងភារកិច្ចត្រួតពិនិត្យទិន្នន័យការធ្វើដំណើរបុគ្គលបរទេស ប្រវត្តិនៃការធ្វើដំណើរ ការសុំស្នាក់នៅ និងរបបបញ្ជាឃ្លាំមើល(Pibics)ទៀតផង។យ៉ាងណាក៏ដោយ អ្នកសារព័ត៌មានថៃរាយការណ៍ថាសមត្ថកិច្ចបានចាប់ឃុំខ្លួន ជនសង្ស័យខាងលើនិងបានចោទប្រកាន់មេខ្យល់ជនជាតិថៃ២នាក់ និងពលករខ្មែរទាំង១៩នាក់ ពីបទ លាក់បំពួន ជួយសង្គ្រោះ ដោយប្រការណាមួយ ដើម្បីឲ្យបុគ្គលបរទេស ដែលចូលប្រទេសដោយខុសច្បាប់ រួចផុតពីការចាប់ឃុំខ្លួន។

ទង្វើនេះគឺល្មើសបទបញ្ជាអាជ្ញាធរខេត្តស្រះកែវ លេខ៩៤៤/២៥៦៣ ដែលហាមដឹកជញ្ជូនពលករបរទេសឆ្លងចូលមកក្នុងទឹកដីខេត្តស្រះកែវ និងហាមរថយន្តទូរ៉ើសដឹកអ្នកដំណើររបស់បុគ្គល ឬរថយន្តផ្ទាល់ខ្លួនដឹកបុគ្គលបរទេសគ្រប់ករណីធ្វើដំណើរចូលមកទឹកដីខេត្តស្រះកែវ ។ទាំងនេះវាមានលក្ខណៈងាយដល់ការឆ្លងរោគ តាមការកំណត់នៃមាត្រា៩ ច្បាប់១ ៤៥ នៃច្បាប់គ្រាអាសន្ន និងជាបុគ្គលបរទេសជនជាតិខ្មែរ ចូលមកនិងស្នាក់នៅក្នុងព្រះរាជាណាចក្រថៃ ដោយមិនមានការអនុញ្ញាត។ ជនសង្ស័យទាំងនេះត្រូវបានបញ្ជូនទៅឲ្យសមត្ថកិច្ចជំនាញស្រុកអារញ្ញ ដើម្បីចាត់ការតាមផ្លូវច្បាប់បន្ត៕ **ដោយ៖វណ្ណា**

## ពលករខ្មែរជាង៣ពាន់នាក់ នៅក្នុងប្រទេសថៃ ដែលបាត់បង់ផលប្រយោជន៍ បាតុកម្មប្រឆាំងនឹងការរឹតត្បិតរបស់ថៅកែថៃ

https://www.rfi.fr/km/ ចុះផ្សាយនៅថ្ងៃ៖ 12/11/2020 - 07:38 ដោយ៖ញឹម សុផល

ពលករខ្មែរប្រមាណជាង៣ពាន់នាក់ ដែលធ្វើការនៅរោងចក្រ GFN ជារោងចក្រកែច្នៃអាហារសាច់មាន់ នៅតំបន់ណងយ៉ៃ ខេត្តឈុនបុរី ប្រទេសថៃ បានធ្វើការតវ៉ាទៅនឹងវិធានការរបស់ថៅកែរោងចក្រ ដែលធ្វើឲ្យពួកគេបាត់បង់ផលប្រយោជន៍ជាច្រើន អំឡុងពេលនៃការរាតត្បាតនៃវីរុសកូវីដ១៩នេះ។ ពីខេត្តឈុនបុរី ប្រទេសថៃ លោក លឹង សុផុន មន្ត្រីផ្នែកអន្តោប្រវេសន៍ នៃអង្គការសម្ព័ន្ធភាពការងារ និងសិទ្ធិមនុស្ស (សង់ត្រាល់) បានថ្លែងប្រាប់វិទ្យុបារាំង RFI ថា ក្រុមពលករខ្មែរបានតវ៉ាទៅនឹងការតម្រូវឲ្យពួកគេ ចេញថ្លៃបន្ទប់ ថ្លៃទឹក ថ្លៃភ្លើង ខណៈតម្លៃសេវាកម្ម និងប្រាក់ចំណូលរបស់ពលករទាំងនោះមានការធ្លាក់ចុះ។ ហេតុការណ៍នេះ បានកើតឡើងប្រមាណជា៣ខែមកហើយ ហើយទើបតែផ្ទុះការតវ៉ាទ្រង់ទ្រាយធំនៅពេលនេះ។ មួយវិញទៀត រោងចក្រតម្រូវឲ្យពលករទាំងអស់ ទិញអីវ៉ាន់ និងម្ហូបអាហារ តែនៅក្នុងរោងចក្រ ព្រោះខ្លាច ការឆ្លងកូវីដ១៩ មិនអោយចេញក្រៅ ផ្ទុយពីពលករថៃ ដែលអាចចេញចូលទៅខាងក្រៅបាន។ មន្ត្រីអង្គការសង់ត្រាល់រូបនេះ បញ្ជាក់ថាលោកកំពុងតែសហការជាមួយស្ថានទូតកម្ពុជាប្រចាំប្រទេសថៃ ដើម្បីចូលរួមដោះស្រាយបញ្ចប់វិវាទមួយនេះជាមួយនឹងក្រុមហ៊ុន និងអាជ្ញាធរថៃ។

## តំណាងស្ថានទូតកម្ពុជាប្រចាំប្រទេសថៃ បានសហការជាមួយមន្ទីរការងារខេត្តឈុនបុរីចុះសម្របសម្រួលករណីពលករខ្មែរ៣០០០នាក់ បាតុកម្មរោងចក្រ

https://www.facebook.com/MigrantCambodia/ 12-11-2020

តំណាងស្ថានទូតកម្ពុជាប្រចាំប្រទេសថៃ បានសហការជាមួយមន្ទីរការងារខេត្តឈុនបុរី ចុះមកក្រុមហ៊ុន GFN ស្ថិតក្នុងស្រុកណងយ៉ៃ ខេត្តឈុនបុរី ដើម្បីដោះស្រាយបញ្ហាដូចជា៖

-ថ្លៃដំណើរការឯកសារ

-ថ្លៃបន្ទប់ស្នាក់នៅ

-ថ្លៃម្ហូបអាហារនៅក្នុងក្រុមហ៊ុន

-ការរឹតបន្តឹងក្នុងការចេញចូលក្រុមហ៊ុនដើម្បីគ្រប់គ្រងពលករ ដែលមានព័ត៌មានថា ពលករខ្មែរចំនួន ៣,០០០នាក់ បានប្រមូលផ្តុំគ្នាធ្វើបាតុកម្មកាលពីល្ងាចថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០២០ កន្លងទៅ។ បន្ទាប់ពីមានការបញ្ជាក់លំអិតពីក្រុមហ៊ុន តំណាងពលករបានយល់ស្របនិងទទួលយកដំណោះស្រាយនេះ។

# ថ្ងៃទី១៦ ខែ វិច្ឆិកា ឆ្នាំ២០២០

## ការពង្រឹងសមត្ថភាពក្រុមការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នៅស្រុកបន្ទាយស្រី

https://www.facebook.com/deputygovernoryousophear 14-11-2020

លេខាធិការដ្ឋាននៃគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ខេត្តសៀមរាប (គ.ខ.ប.ជ) សហការជាមួយរដ្ឋបាលស្រុកបន្ទាយស្រី និងអង្គការមូលនិធិ អេ២១ បានចុះបណ្តុះបណ្តាលពង្រឹងសមត្ថភាពដល់ក្រុមការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សនៅថ្នាក់ស្រុក និងថ្នាក់ឃុំ ដើម្បីលើកកម្ពស់ការយល់ដឹងអំពីការទប់ស្កាត់អំពើជួញដូរមនុស្ស និងអំពើកេងប្រវ័ញ្ចផ្សេងៗ និងការផ្តល់សេវាឱ្យបានសមស្របដល់ជនរងគ្រោះ និងងាយរងគ្រោះឱ្យកាន់តែមានប្រសិទ្ធភាពខ្ពស់។

# ការពង្រឹងសមត្ថភាពក្រុមការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នៅក្រុងសៀមរាប

https://www.facebook.com/deputygovernoryousophear 13-11-2020

ថ្ងៃសុក្រ ១៣រោច ខែកត្តិក ឆ្នាំជូត ទោស័ក ព.ស. ២៥៦៤ ត្រូវនឹងថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០២០ លេខាធិការដ្ឋាននៃគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ខេត្តសៀមរាប (គ.ខ.ប.ជ) សហការជាមួយរដ្ឋបាលក្រុងសៀមរាប និងអង្គការមូលនិធិ អេ២១ បានចុះបណ្តុះបណ្តាលពង្រឹងសមត្ថភាពដល់ក្រុមការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សនៅថ្នាក់ក្រុង និងថ្នាក់សង្កាត់ ដើម្បីលើកកម្ពស់ការយល់ដឹងអំពីការទប់ស្កាត់អំពើជួញដូរមនុស្ស និងអំពើកេងប្រវ័ញ្ចផ្សេងៗ និងការផ្តល់សេវាឱ្យបានសមស្របដល់ជនរងគ្រោះ និងងាយរងគ្រោះឱ្យកាន់តែមានប្រសិទ្ធភាពខ្ពស់។

កញ្ញា Kristen Scharf នាយិកាប្រចាំប្រទេសកម្ពុជានៃអង្គការមូលនិA21 បានលើកឡើងថាបញ្ហាអំពើជួញដូរមនុស្ស គឺជាបទឧក្រិដ្ឋ ដែលមានលក្ខណៈពិបាកក្នុងការកំណត់ថាជាអំពើជួញដូរមនុស្ស។ ទោះបីស្ថិតក្នុងស្ថានភាពនៃការរីករាលដាលនៃជំងឺកូវីដ១៩យ៉ាងក៏ដោយក៏បញ្ហាអំពើជួញដូរមនុស្សនៅតែបន្តកើតមានជាបន្តបន្ទាប់នៅតាមគ្រប់រូបភាព។ បន្ថែមពីនោះ កញ្ញា Kristen Scharf នាយិកាប្រចាំប្រទេសកម្ពុជារបស់អង្គការមូលនិធិA21 បានថ្លែងអំណរគុណដល់គណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ខេត្តសៀមរាប ដែលបានសហការជាមួយអង្គការ និងការចូលរួមរបស់មន្ទីរ អង្គភាព ព្រមទាំងអាជ្ញាធរគ្រប់ថ្នាក់ ក្នុងការទប់ស្កាត់ ការបង្រ្កាប ការផ្តន្ទាទោស និងការជួយជនរងគ្រោះដោយអំពើជួញដូរមនុស្ស និងអំពើកេងប្រវ័ញ្ចផ្សេងៗ ពិសេសកុមារ។ អង្គការមូលនិធិA21 រីករាយនឹងសហការជាមួយគ្រប់អ្នកពាក់ព័ន្ធក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សនៅកម្ពុជាផងដែរ។

មានប្រសាសន៍នៅក្នុងពិធីបើកវគ្គបណ្តុះបណ្តាល លោកស្រី យូ សុភា អភិបាលរងខេត្ត ជាប្រធានលេខាធិការដ្ឋាននៃគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ខ.ប.ជ) បានលើកឡើង អំពីការអភិវឌ្ឍលើគ្រប់វិស័យ តាមកម្មវិធីនយោបាយយុទ្ធសាស្រ្តចតុកោណរបស់រាជរដ្ឋាភិបាល ដោយបានផ្តោតខ្ពស់លើការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ការកេងកម្លាំងពលកម្ម ការធ្វើអាជីវកម្មផ្លូវភេទលើស្ត្រី កុមារនិងជនងាយរងគ្រោះ ព្រមទាំងបានដាក់ចេញនូវអនុសាសន៍គន្លឹះសំខាន់ៗ សំដៅពង្រឹងកិច្ចសហប្រតិបត្តិការជាតិ និងអន្តរជាតិ និងជំរុញឲ្យក្រុមការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សគ្រប់ថ្នាក់ ខិតខំអនុវត្តច្បាប់ និងសហការកាន់តែខ្លាំងក្លាជាមួយគ្រប់ស្ថាប័នពាក់ព័ន្ធ អង្គការដៃគូជាតិ ងនននតរជាតិ និងជំរុញឲ្យមានការចូលរួមពីប្រជាពលរដ្ឋ ដើម្បីរួមចំណែកលុបបំបាត់អំពើជួញដូរមនុស្សឲ្យបានជាស្ថាពរ។ លោកស្រី ក៏បានបន្ថែមទៀតថា អំពើជួញដូរមនុស្ស គឺជាឧក្រិដ្ឋកម្មដ៏រាំរ៉ៃ មួយដែលកើតមាននៅគ្រប់បណ្តាប្រទេសនៅលើពិភពលោក ក្នុងចំណោមឧក្រិដ្ឋកម្មដទៃទៀតដែលកំពុងតែធ្វើឲ្យប៉ះពាល់ដល់សន្តិសុខមនុស្ស និងប្រទេសជាតិ។

ម្យ៉ាងទៀតប្រជាពលរដ្ឋមួយចំនួនធំ បាននិងកំពុង ទទួលរងគ្រោះយ៉ាងធ្ងន់ធ្ងរ នូវអំពើជួញដូរមនុស្ស តាមរយៈការកេងប្រវ័ញ្ចគ្រប់រូបភាព លើការរំលោភបំពានលើសិទ្ធិសេរីភាព កិត្តិយស សេចក្តីថ្លៃថ្នូររបស់មនុស្ស និងដោយបានបំផ្លាញដល់រាងកាយ និងបញ្ញាស្មារតីជនរងគ្រោះ ដែលបញ្ហាទាំងនេះ ធ្វើឲ្យមានវិបត្តិក្នុងសង្គមកាន់តែធ្ងន់ធ្ងរ ប្រសិនបើមិនមានការទប់ស្កាត់ និងលុបបំបាត់ទាន់ពេលវេលានោះ។ លោកស្រី ក៏បានបញ្ជាក់ផងដែរថា កិច្ចការទាំងនេះចាំបាច់ទាមទារឲ្យយើងគ្រប់គ្នាត្រូវតែចូលរួម ពីគ្រប់ផ្នែកពាក់ព័ន្ធទាំងអស់ ដោយមិនអាចខ្វះមួយណាបានឡើយ។ ម្យ៉ាងទៀតគ្រប់បណ្តាក្រុង ស្រុក ណាមួយក៏មិនអាចលុបបំបាត់នូវបទឧក្រិដ្ឋជួញដូរមនុស្សតែឯងបានឡើយ។ ដើម្បីធ្វើកិច្ចការទាំងនេះបាន គឺទាំមទារឲ្យមាននូវការបណ្តុះបណ្តាលនូវចំណេះដឹងដូចគ្នា ដោយមានឆន្ទៈ និងការប្តេជ្ញាចិត្តខ្ពស់ ក្នុងការអនុវត្តតួនាទី ភារកិច្ច ប្រកបទៅដោយការទទួលខុសត្រូវខ្ពស់ និងកិច្ចសហការល្អ ក្នុងការឆ្ពោះទៅកាន់គោលដៅរួមតែមួយ ដើម្បីសេចក្តីសុខសាន្តរបស់មនុស្សជាតិ។

## ចំណែកឯពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ១១៧នាក់

https://www.facebook.com/GDIOfficial 13-11-2020

នៅថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០២០ វេលាម៉ោង ១៥និង០០នាទី ភាគីថៃនៅតែបន្តបិទច្រកទ្វារព្រំដែនអន្តរជាតិ ឆង ចម ខេត្តសុរិន្ទ ទល់មុខច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ ជាបណ្ដោះអាសន្ន មិនអនុញ្ញាតឲ្យអ្នកដំណើរ គ្រប់សញ្ជាតិចេញ-ចូល ឆ្លងកាត់ ដើម្បីបង្ការនិងទប់ស្កាត់ការរាតត្បាតនៃជំងឺឆ្លងកូវីដ-១៩។ ក្នុងការបិទច្រកនេះ ភាគីថៃបានលើកលែង ទំនិញដែលទទួលបានការអនុញ្ញាត និងអ្នកបើកបររថយន្តដឹកទំនិញដែលទទួលបានការអនុញ្ញាត ព្រមទាំងបានការឆ្លងកាត់ត្រួតពិនិត្យ ដោយសមត្ថកិច្ចទាំងភាគី កម្ពុជា-ថៃ បានត្រឹមត្រូវ និងពលរដ្ឋខ្មែរ ឬពលរដ្ឋថៃ ដែលត្រូវវិលត្រឡប់ចូលប្រទេសរៀងៗខ្លួន។ ចំណែកឯពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ១១៧នាក់ ស្រី ៥១នាក់៕

## ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិប៉ោយប៉ែត បានទទួលពលករខ្មែរឆ្លងដែនខុសច្បាប់ ដែលអាជ្ញាធរថៃបញ្ជូនមក មានចំនួន ៤៩នាក់

https://www.facebook.com/GDIOfficial 14-11-2020

ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិប៉ោយប៉ែត នាថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០២០ បានទទួលពលករខ្មែរឆ្លងដែនខុសច្បាប់ ដែលអាជ្ញាធរថៃបញ្ជូនមក មានចំនួន ៤៩នាក់ ស្រី ១៣នាក់ និងកុមារ ០៣នាក់។ ចំពោះពលករខាងលើ ត្រូវបានកម្លាំងនគរបាលប៉ុស្តិ៍ ធ្វើការអប់រំណែនាំ បន្ទាប់មកប្រគល់ជូនក្រុមការងារ ទទួលពលករមជ្ឈមណ្ឌលសំចតប៉ោយប៉ែត ដើម្បីធ្វើការបន្ត។ ជាមួយគ្នានេះដែរ អាជ្ញាធរថៃនៅតែបន្តបិទច្រកទ្វារព្រំដែន មិនទាន់បើកឱ្យអ្នកដំណើរចេញ-ចូលឆ្លងកាត់នៅឡើយ ចំពោះអ្នកជំងឺសង្គ្រោះបន្ទាន់ និងរថយន្តដឹកទំនិញធន់ធំដំណើរការជាធម្មតា៕

## ពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ១៧៤នាក់

https://www.facebook.com/GDIOfficial 14-11-2020

នៅថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០២០ វេលាម៉ោង ១៥និង០០នាទី ភាគីថៃនៅតែបន្តបិទច្រកទ្វារព្រំដែនអន្តរជាតិ ឆង ចម ខេត្តសុរិន្ទ ទល់មុខច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ ជាបណ្ដោះអាសន្ន មិនអនុញ្ញាតឲ្យអ្នកដំណើរ គ្រប់សញ្ជាតិចេញ-ចូល ឆ្លងកាត់ ដើម្បីបង្ការនិងទប់ស្កាត់ការរាតត្បាតនៃជំងឺឆ្លងកូវីដ-១៩។ ក្នុងការបិទច្រកនេះ ភាគីថៃបានលើកលែង ទំនិញដែលទទួលបានការអនុញ្ញាត និងអ្នកបើកបររថយន្តដឹកទំនិញដែលទទួលបានការអនុញ្ញាត ព្រមទាំងបានការឆ្លងកាត់ត្រួតពិនិត្យ ដោយសមត្ថកិច្ចទាំងភាគី កម្ពុជា-ថៃ បានត្រឹមត្រូវ និងពលរដ្ឋខ្មែរ ឬពលរដ្ឋថៃ ដែលត្រូវវិលត្រឡប់ចូលប្រទេសរៀងៗខ្លួន។ ចំណែកឯពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ១៧៤នាក់ ស្រី ៦៦នាក់ និងបានពលរដ្ឋខ្មែរចំនួន ០១នាក់ ពីភាគីថៃ ពាក់ព័ន្ធនឹងបទលួចចូលកាប់ឈើខុសច្បាប់ ក្នុងទឹកដីប្រទេសថៃ៕

## ពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ១៥៦នាក់

https://www.facebook.com/GDIOfficial 13-11-2020

នៅថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០២០ វេលាម៉ោង ១៥និង០០នាទី ភាគីថៃនៅតែបន្តបិទច្រកទ្វារព្រំដែនអន្តរជាតិ ឆង ចម ខេត្តសុរិន្ទ ទល់មុខច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ ជាបណ្ដោះអាសន្ន មិនអនុញ្ញាតឲ្យអ្នកដំណើរ គ្រប់សញ្ជាតិចេញ-ចូល ឆ្លងកាត់ ដើម្បីបង្ការនិងទប់ស្កាត់ការរាតត្បាតនៃជំងឺឆ្លងកូវីដ-១៩។ ក្នុងការបិទច្រកនេះ ភាគីថៃបានលើកលែង ទំនិញដែលទទួលបានការអនុញ្ញាត និងអ្នកបើកបររថយន្តដឹកទំនិញដែលទទួលបានការអនុញ្ញាត ព្រមទាំងបានការឆ្លងកាត់ត្រួតពិនិត្យ ដោយសមត្ថកិច្ចទាំងភាគី កម្ពុជា-ថៃ បានត្រឹមត្រូវ និងពលរដ្ឋខ្មែរ ឬពលរដ្ឋថៃ ដែលត្រូវវិលត្រឡប់ចូលប្រទេសរៀងៗខ្លួន។ ចំណែកឯពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ១៥៦នាក់ ស្រី ៧៦នាក់ និងពលរដ្ឋថៃដែលបានចាកចេញមានចំនួន ០២នាក់៕

## ថៃអនុញ្ញាតឱ្យពលករចំណាកស្រុករាប់ពាន់នាក់ពន្យារអាជ្ញាប័ណ្ណការងារ

https://khmer.voanews.com/ 14 វិច្ឆិកា 2020

ពលករចំណាកស្រុករាប់ពាន់នាក់នៅប្រទេសថៃ ដែលលិខិតអនុញ្ញាតឱ្យធ្វើការរបស់ពួកគេត្រូវផុតកំណត់នោះ ត្រូវបានអនុញ្ញាតឱ្យស្នាក់នៅក្នុងប្រទេសនេះ រយៈពេលពីរឆ្នាំទៀត ប៉ុន្តែក្រុមអ្នកធ្វើយុទ្ធនាការបាននិយាយថា ការចំណាយលើការពន្យារពេលនេះ អាចជំរុញឱ្យមានបំណុល និងការកេងប្រវ័ញ្ចកម្មករ។ នេះបើតាមសេចក្តីរាយការណ៍របស់ទីភ្នាក់ងារ Reuters។ ក្រសួងការងារថៃនៅសប្តាហ៍នេះ បាននិយាយថា ជនចំណាកស្រុកសរុបប្រមាណ ១៣០.០០០ នាក់ មកពីប្រទេសមីយ៉ាន់ម៉ា កម្ពុជា និងឡាវ ដែលបានចូលប្រទេសនេះ ក្រោមកិច្ចព្រមព្រៀងការងារទ្វេភាគី ហើយដែលលិខិតអនុញ្ញាតរបស់ពួកគេ ត្រូវផុតកំណត់ចាប់ពីខែនេះរហូតដល់ខែធ្នូ ឆ្នាំ២០២១នោះ នឹងមានសិទ្ធិពន្យារ។

រដ្ឋមន្ត្រីក្រសួងការងារថៃ លោក Suchat Chomklin បាននិយាយនៅក្នុងសេចក្តីថ្លែងការណ៍មួយថា៖ «ធ្វើដូច្នេះគឺ ដើម្បីកាត់បន្ថយការរាលដាលនៃវីរុសកូរ៉ូណា និងដោះស្រាយកង្វះខាតពលកម្ម និងការពារសិទ្ធិពលករចំណាកស្រុក ដែលមកប្រទេសថៃដោយស្របច្បាប់»។ ប្រទេសថៃមានពលករចំណាកស្រុក ដែលបានចុះឈ្មោះប្រហែល ២,៨ លាននាក់ ដែលភាគច្រើនមកពីប្រទេសមីយ៉ាន់ម៉ា កម្ពុជា និងឡាវ។ ប៉ុន្តែអង្គការសហប្រជាជាតិបានប៉ាន់ប្រមាណថា មានពលករចំនួន ២ លានបន្ថែមទៀត ធ្វើការដោយគ្មានការចុះបញ្ជីផ្លូវការនៅទូទាំងប្រទេសថៃ ក្នុងវិស័យជាច្រើនដូចជានេសាទ សំណង់និងកសិកម្ម។

កាលពីខែមីនា យ៉ាងហោចណាស់មានពលករចំណាកស្រុកចំនួន ៩០.០០០ នាក់ បានសម្រុកចេញពីប្រទេសថៃ នៅពេលព្រំដែនគោកត្រូវបានបិទនៅពេលនោះ ដើម្បីទប់ស្កាត់រាតត្បាតនៃជំងឺកូវីដ១៩។ រហូតមកដល់ពេលនេះ ប្រទេសអាស៊ីអាគ្នេយ៍មួយនេះ មានអ្នកស្លាប់ដោយជំងឺកូវីដ១៩ ចំនួន ៦០ នាក់ក្នុងចំណោមអ្នកឆ្លងយ៉ាងហោចណាស់ ៣.៨៥០ នាក់។ ជនចំណាកស្រុកដែលចង់ពន្យារការអនុញ្ញាតឱ្យធ្វើការបន្តនេះ នឹងត្រូវឆ្លងកាត់ការត្រួតពិនិត្យសុខភាព និងបង់ថ្លៃសេវាចំនួន ១.៩០០ បាត គឺប្រមាណ ៦៣ ដុល្លារដែលបង្កឱ្យមានការព្រួយបារម្ភក្នុងចំណោមអ្នកធ្វើយុទ្ធនាការ ដែលថា ការចំណាយនេះអាចត្រូវបានបំប៉ោង ដោយនិយោជកនិងមេខ្យល់ការងារ និងជំរុញឱ្យកម្មករជំពាក់បំណុលកាន់តែច្រើន៕

## រដ្ឋាភិបាលនិងអ្នកពាក់ព័ន្ធគិតគូរពីបញ្ហាចំណាយច្រើនរបស់ពលករចំណាកស្រុក"

https://www.rfa.org/khmer/ ដោយ ម៉ៅ សុជានី 2020-11-14

មន្ត្រីសង្គមស៊ីវិលផ្នែកទេសន្តរប្រវេសក៍ ស្នើដល់រដ្ឋាភិបាលកម្ពុជា និងក្រុមហ៊ុននាំពលករចេញ ទៅធ្វើការនៅក្រៅប្រទេស គិតគូរពីការជំពាក់បំណុល និងការកេងប្រវ័ញ្ចកម្លាំងពលកម្មលើពលករចំណាកស្រុក។ មន្ត្រីកម្មវិធីផ្នែកទេសន្តរប្រវេសក៍ នៃមជ្ឈមណ្ឌលសម្ពន្ធភាពការងារ និងសិទ្ធិមនុស្ស ហៅកាត់ថា អង្គការសង់ត្រាល់ លោក ឌី ថេហូយ៉ា ប្រាប់អាស៊ីសេរី កាលពីយប់ថ្ងៃសុក្រថា ភាគច្រើនពលករចំណាកស្រុក ជំពាក់បំណុលវណ្ឌក ដោយសារតម្រូវការចំណាយបង់ប្រាក់ច្រើន ដើម្បីអាចទៅធ្វើការនៅក្រៅប្រទេសបាន។ លោកចង់ឲ្យរដ្ឋាភិបាល និងស្ថាប័នពាក់ព័ន្ធ ជួយសម្រួលការចំណាយនានា រួមមានកំណត់តម្លៃថោកសម្រាប់ការធ្វើប័ណ្ណការងារ ដើម្បីកាត់បន្ថយបំណុលរបស់ពលករចំណាកស្រុក៖ «កាលណាទៅដោយសារចំណាយច្រើន ពួកគាត់គ្មានលុយផ្ទាល់ខ្លួនទេ គឺគាត់ត្រូវខ្ចីគេ ឬក្រុមហ៊ុនបង់មុន ដូចនេះត្រូវបង់គិតការប្រាក់ ម្ល៉ោះហើយត្រូវបង់សងវិញនៅប្រទេសទៅធ្វើការ។ ដូចនេះវាក្លាយជាការចំណាកស្រុកជំពាក់បំណុល ដែលនេះមានន័យថា ទាសករនៅសម័យទំនើប គាត់អត់មានសិទ្ធិសេរីភាពក្នុងការឲ្យគេគោរពសិទ្ធិមនុស្ស និងសិទ្ធិការងារ»។ ការលើកឡើងរបស់មន្ត្រីកម្មវិធីផ្នែកទេសន្តរប្រវេសក៍នេះ បន្ទាប់ពីអាជ្ញាធរថៃអនុញ្ញាតឲ្យពលករចំណាកស្រុកជាង ១៣ម៉ឺននាក់ រួមមានខ្មែរ ភូមា និងឡាវ ដែលកំពុងធ្វើការក្នុងប្រទេសថៃ អាចបន្តប័ណ្ណការងារបាន ២ឆ្នាំបន្ថែមទៀត ដែលនឹងផុតកំណត់នៅចុងខែវិច្ឆិកាខាងមុខ។

រដ្ឋមន្ត្រីក្រសួងការងារថៃ លោក ស៊ូឆាត ជុំលីន (Suchat Chomklin) បញ្ជាក់ក្នុងសេចក្ដីថ្លែងការណ៍កាលពីថ្ងៃទី១៣ ខែវិច្ឆិកា ថា ការពន្យារប័ណ្ណការងារ ២ឆ្នាំបន្ថែមទៀតនេះ គឺដើម្បីកាត់បន្ថយការឆ្លងរាលដាលនៃជំងឺកូវីដ ១៩ ដោះស្រាយបញ្ហាកង្វះកម្លាំងពលកម្ម និងសម្រួលការងារដល់ពលករចំណាកស្រុកជាង ១៣ម៉ឺននាក់នោះ មកធ្វើការក្នុងប្រទេសថៃ ក្រោមកិច្ចព្រមព្រៀងទ្វេភាគីនៃប្រទេសទាំងនោះ។ ប្រទេសថៃមានពលករបរទេសចុះឈ្មោះស្របច្បាប់ ជាង ២លាន៨សែននាក់ មកពីប្រទេសកម្ពុជា ភូមា និងឡាវ ដែលបម្រើការងារផ្នែកសំណង់ កសិកម្ម និងនេសាទ។

របាយការណ៍របស់ក្រសួងការងារបង្ហាញថា គិតត្រឹមឆ្នាំ២០១៩ មានពលករខ្មែរធ្វើការនៅប្រទេសថៃប្រមាណមួយលាននាក់។ លោក ឌី ថេហូយ៉ា ឲ្យដឹងថា ស្ថានភាពជាក់ស្ដែង ពលករខ្មែរធ្វើការទាំងមានច្បាប់ និងខុសច្បាប់ នៅប្រទេសថៃ មានខ្ទង់ពីរលាននាក់។ លោកបន្តថា តាំងពីប្រទេសថៃ បិទព្រំដែន ចាប់ពីខែមីនាមក ពលករខ្មែរ ជាងមួយម៉ឺននាក់ បានលួចឆ្លងដែន ចូលទៅប្រទេសថៃ រកការងារធ្វើជាបន្តបន្ទាប់ តែភាគច្រើន ត្រូវថៃចាប់បានហើយបញ្ជូនត្រឡប់មកវិញ៕

## ពលករខ្មែរម្នាក់ ដេកស្លាប់ក្រោយផឹកស្រាថ្នាំ យីហោ «ឆ្អឹងខ្លា»

http://kampucheathmey.com/ November 15, 2020

ពលករខ្មែរម្នាក់ ដែលមានមុខនាទីជាជាងភ្លើង ក្នុងខេត្ត ឈុនបុរី ប្រទេសថៃបានស្លាប់នៅក្នុងបន្ទប់ស្នាក់នៅ ដោយមានចំណងជាប់នៅដៃផង ដែលបញ្ហានេះបានធ្វើឲ្យប៉ូលិសថៃ មានមន្ទិលយ៉ាងខ្លាំង និងបង្កការភ្ញាក់ផ្អើលកាលពីព្រឹក ថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ២០២០។ ពលករខ្មែររូបនេះ មានឈ្មោះ សង ត្រៀមចិត្រ ភេទប្រុស អាយុ ៣០ ឆ្នាំ មានមុខងារជា ជាងភ្លើង ក្នុងក្រុមហ៊ុនឯកជនមួយ នៅក្នុងខេត្តឈុនបុរី ។

តាមការអះអាងពីសាក្សីដែលស្នាក់នៅក្បែរបាននិយាយថា កាលពីវេលាម៉ោង ៧ និង ៣០ នាទី យប់ថ្ងៃទី ១៣ ខែ វិច្ឆិកា ជនរងគ្រោះរូបនេះបានជួបជុំគ្នាជាមួយមិត្តភ័ក្តិចំនួន ២ នាក់ ដោយពួកគេបាននាំគ្នាផឹកស្រាថ្នាំ យីហោ « ឆ្អឹងខ្លា » អស់ចំនួន ៤ ដបធំ រហូតដល់ម៉ោង ១០ យប់ទើបពួកគេបែកផ្លូវគ្នាចូលទៅសម្រាករៀងៗខ្លួន

លុះព្រឹកឡើងនៅពេលដែលមិត្តភ័ក្តិចូលទៅហៅដើម្បីចេញទៅធ្វើការ ទើបមានការភ្ញាក់ផ្អើលតែម្តង ដោយសារតែឃើញជនរងគ្រោះដេកស្លាប់នៅក្នុងសភាពដៃច្រង៉ាង ។

ដោយឡែកលោក រឿន ហ៊ាន អាយុ ៥០ ឆ្នាំ ត្រូវជា ឪពុកមា បង្កើតរបស់សព បានអះអាងប្រាប់សមត្ថកិច្ចថៃថា នៅព្រឹកថ្ងៃកើតហេតុ បន្ទាប់ពីមានការឆោឡោថា ក្មួយរបស់គាត់បានស្លាប់រួចមក គាត់ក៏បានចូលទៅមើល ហើយក៏បានហៅម្ចាស់ផ្ទះជួលឲ្យមកមើលដែរ ដោយសារតែក្មួយរបស់គាត់ដេកស្លាប់មានលក្ខណៈអាក្រក់មើលពេក គាត់ក៏បានទាញដៃទាំងពីរយកមកចងភ្ជាប់គ្នា រួចក៏បានហៅសមត្ថកិច្ចមកពិនិត្យ ។

ដំបូងឡើយ សមត្ថកិច្ចថៃមានការឈឺក្បាល ដោយគិតថា វាគឺជាករណីឃាតកម្ម ដោយសារតែសពមានការចងដៃជាប់គ្នា ប៉ុន្តែក្រោយពីបានស្តាប់សាក្សីបំភ្លឺ និងក្រោយពីបានពិនិត្យទៅលើរាងកាយសពមិនមានស្លាកស្នាមអ្វីមួយ ដែលអាចពាក់ព័ន្ធទៅនិងករណីឃាតកម្មនោះទេ ទើបប្រគល់សពទៅឲ្យក្រុមអង្គភាពជំនាញដើម្បីធ្វើការតាមនីតិវិធី៕ **អត្ថបទ ៖ សោ និយមរ័ត្ន**

## ថ្ងៃទី១៧ ខែ វិច្ឆិកា ឆ្នាំ២០២០

## ការពង្រឹងសមត្ថភាពក្រុមការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នៅស្រុកសូទ្រនិគម

https://www.facebook.com/deputygovernoryousophear 16-11-2020

ថ្ងៃចន្ទ ១កើត ខែមិគសិរ ឆ្នាំជូត ទោស័ក ព.ស. ២៥៦៤ ត្រូវនឹងថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០២០ លេខាធិការដ្ឋាននៃគណៈកម្មាធិការប្រយុទ្ធប្រឆាំង។អំពើជួញដូរមនុស្ស ខេត្តសៀមរាប (គ.ខ.ប.ជ) សហការជាមួយរដ្ឋបាលស្រុកសូទ្រនិគម និងអង្គការមូលនិធិ អេ២១ បានចុះបណ្តុះបណ្តាលពង្រឹងសមត្ថភាពដល់ក្រុមការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សនៅថ្នាក់ស្រុក និងថ្នាក់ឃុំ ដើម្បីលើកកម្ពស់ការយល់ដឹងអំពីការទប់ស្កាត់អំពើជួញដូរមនុស្ស និងអំពើកេងប្រវ័ញ្ចផ្សេងៗ និងការផ្តល់សេវាឱ្យបានសមស្របដល់ជនរងគ្រោះ និងងាយរងគ្រោះឱ្យកាន់តែមានប្រសិទ្ធភាពខ្ពស់។

ថ្លែងនៅក្នុងកិច្ចស្វាគមន៍ លោក ម៉ក់ ប្រុស អភិបាលនៃគណៈអភិបាលស្រុកសូទ្រនិគម និងជាប្រធានក្រុមការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សថ្នាក់ស្រុក បានលើកឡើងអំពីការយកចិត្តទុកដាក់របស់ក្រុមការងារទាំងគ្រប់កម្រិតបន្ថែមពីនោះស្របតាមយន្តការ និងការណែនាំពីគណៈកម្មាធិការខេត្តប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ ខ ប ជ) ស្រុកសូទ្រនិគម បានបង្កើត និងកែសម្រួលលើសេចក្តីសម្រេចការងារនៅថ្នាក់ស្រុក និងថ្នាក់ឃុំ ជាបន្តបន្ទាប់ ដើម្បីពង្រឹងលើការបង្ការទប់ស្កាត់អំពើជួញដូរមនុស្សនៅក្នុងសង្គម។ លោកអភិបាលស្រុកបានជម្រាបជូនផងដែរថា ក្រុមការងារថ្នាក់ស្រុកបានធ្វើការប្រជុំតាមដាននិងត្រួតពិនិត្យលើការងារនេះជាប្រចាំ និងបានជំរុញទៅដល់ថ្នាក់ឃុំឲ្យយកចិត្តទុកដាក់លើការងារបង្ការទប់ស្កាត់ និងការជួយជនរងគ្រោះដោយអំពើជួញដូរមនុស្ស និងអំពើហិង្សាទាក់ទងនឹងយេនឌ័រឲ្យបានសមស្រប និងមានប្រសិទ្ធភាព។ វគ្គបណ្តុះបណ្តាលនេះទទួលបានការឧបត្ថម្ភគាំទ្រពីរដ្ឋបាលខេត្តសៀមរាប និងអង្គការមូលនិធិA21។

មានប្រសាសន៍នៅក្នុងពិធីបើកវគ្គបណ្តុះបណ្តាល លោកស្រី យូ សុភា អភិបាលរងខេត្ត ជាប្រធានលេខាធិការដ្ឋាននៃគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ខ.ប.ជ) បានលើកឡើង អំពីការអភិវឌ្ឍលើគ្រប់វិស័យ តាមកម្មវិធីនយោបាយយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល ដោយបានផ្តោតខ្ពស់លើការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ការកេងកម្លាំងពលកម្ម ការធ្វើអាជីវកម្មផ្លូវភេទលើស្ត្រី កុមារនិងជនងាយរងគ្រោះ ព្រមទាំងបានដាក់ចេញនូវអនុសាសន៍គន្លឹះសំខាន់ៗ សំដៅពង្រឹងកិច្ចសហប្រតិបត្តិការជាតិ និងអន្តរជាតិ និងជំរុញឲ្យក្រុមការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សគ្រប់ថ្នាក់ ខិតខំអនុវត្តច្បាប់ និងសហការកាន់តែខ្លាំងក្លាជាមួយគ្រប់

ស្ថាប័នពាក់ព័ន្ធ អង្គការដៃគូជាតិ និងជំរុញឲ្យមានការចូលរួមពីប្រជាពលរដ្ឋ ដើម្បីរួមចំណែកលុបបំបាត់អំពើជួញដូរមនុស្សឲ្យបានជាស្ថាពរ រួមមាន៖

1,ជំរុញលើការពង្រឹងលើការរៀបចំកិច្ចប្រជុំ ត្រួតពិនិត្យ តាមដានលើបទល្មើសទាក់ទងនឹងអំពើជួញដូរមនុស្សនៅតាមមូលដ្ឋាន

2,ត្រូវពង្រឹងលើការកំណត់អត្តសញ្ញាណជនរងគ្រោះឲ្យបានត្រឹមត្រូវ ដោយមានកិច្ចសហការជាមួយគ្រប់អ្នកពាក់ព័ន្ធ និងការផ្តល់សេវាជូនជនរងគ្រោះឲ្យបានសមស្របប្រកបដោយតម្លាភាព និងមានប្រសិទ្ធភាពខ្ពស់ទៅតាមនីតិវិធី

3,ជំរុញលើការអនុវត្តច្បាប់ឱ្យបានម៉ឺងម៉ាត់សម្រាប់ជនល្មើសជួញដូរមនុស្ស និងជនប្រព្រឹត្តបទល្មើសរំលោភបំពានលើស្ត្រី និងកុមារ។

4, ជំរុញលើកិច្ចការពារកុមារពីការរំលោភបំពានផ្សេងៗ

5, ជំរុញឱ្យមានការគ្រប់គ្រងលើប្រព័ន្ធបញ្ជូនជនរងគ្រោះ តាមរយៈមន្ត្រីសង្គមកិច្ច

6, ជំរុញឲ្យមានការចូលរួមរាល់នីតិវិធីតុលាការ ពីមន្ត្រីសង្គមកិច្ច អាណាព្យាបាលឬ មន្ត្រីកិច្ចការនារី ឬអ្នកទទួលបន្ទុកកិច្ចការនារីឃុំ ក្នុងដំណើរការនីតិវិធីតុលាការរឿងក្តីរបស់កុមារ។

7, ជំរុញលើការរៀបចំរបាយការណ៍លទ្ធផលនៃការងារបង្ការទប់ស្កាត់អំពើជួញដូរមនុស្ស និងការគ្រប់គ្រងករណីដោយត្រូវបន្ស៊ីតួលេខជាមួយថ្នាក់ឃុំ ថ្នាក់ស្រុក និងអង្គការដៃគូ ឲ្យបានច្បាស់លាស់ មុននឹងបញ្ជូនទៅក្រុមការងារថ្នាក់ខេត្ត ជៀសវាងជាន់ករណីគ្នាដែលធ្វើឲ្យមានការកើនឡើងទិន្នន័យ (ករណីតែមួយតែរាយការណ៍ច្រើនលើក)។

## ពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ១៩៨នាក់

https://www.facebook.com/GDIOfficial 16-11-2020

នៅថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០២០ វេលាម៉ោង ១៥និង០០នាទី ភាគីថៃនៅតែបន្តបិទច្រកទ្វារព្រំដែនអន្តរជាតិ ផង ចម ខេត្តសុរិន្ទ ទល់មុខច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ ជាបណ្តោះអាសន្ន មិនអនុញ្ញាតឲ្យអ្នកដំណើរ គ្រប់សញ្ជាតិចេញ-ចូល ឆ្លងកាត់ ដើម្បីបង្ការនិងទប់ស្កាត់ការរាតត្បាតនៃជំងឺឆ្លងកូវីដ-១៩។ ក្នុងការបិទច្រកនេះ ភាគីថៃបានលើកលែង ទំនិញដែលទទួលបានការអនុញ្ញាត និងអ្នកបើកបររថយន្តដឹកទំនិញដែលទទួលបានការអនុញ្ញាត ព្រមទាំងបានការឆ្លងកាត់ត្រួតពិនិត្យ ដោយសមត្ថកិច្ចទាំងភាគី កម្ពុជា-ថៃ បានត្រឹមត្រូវ និងពលរដ្ឋខ្មែរ ឬពលរដ្ឋថៃ ដែលត្រូវវិលត្រឡប់ចូលប្រទេសរៀងៗខ្លួន។ ចំណែកឯពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ១៩៨នាក់ ស្រី ១០៩នាក់ និងពលរដ្ឋថៃដែលបានចាកចេញមានចំនួន ០២នាក់៕

# ក្រោយផ្ទុះការតវ៉ា រោងចក្រ GFN នៅថៃសន្យាដោះស្រាយតាមការទាមទារ របស់ពលករកម្ពុជា

https://vodkhmer.news/ លោក ត្រាន់ តិចសេង ១៦ វិច្ឆិកា ២០២០ ម៉ោង ១៨:២៣

ក្រោយផ្ទុះការតវ៉ាពីសំណាក់ពលករកម្ពុជារាប់ពាន់នាក់នៅថ្ងៃសុក្រសប្តាហ៍មុន ក្រុមហ៊ុនកែច្នៃសាច់មាន់ GFN នៅខេត្តឈុនបុរី ប្រទេសថៃ បានសម្រេចដោះស្រាយបញ្ហារបស់ពលរទាំងនោះតាមសំណើ ខណៈអ្នកឃ្លាំមើលសិទ្ធិជនអន្តោប្រវេសន៍រង់ចាំមើលការអនុវត្តជាក់ស្តែង។

ពលករចំណាកស្រុកកម្ពុជាផ្នែកពន្លះសាច់មាន់នៅរោងចក្រនេះ លោក សុខ នៅ លើកឡើងថា ខាងរោងចក្របានយល់ព្រមដោះស្រាយតាមសំណើរបស់ពួកគាត់ និងសន្យាសងត្រឡប់លុយដែលបានកាត់សម្រាប់ថ្លៃជួសជុលបន្ទប់និងលាបថ្នាំអាគារស្នាក់នៅរបស់ពលករ ហើយពិនិត្យមើលឡើងវិញលើថ្លៃពន្យារទិដ្ឋការធ្វើការ។ យ៉ាងណា លោកថា ការយល់ព្រមរបស់ភាគីថៅកែរោងចក្រ គឺធ្វើឡើងដោយសារថៅកែរោងចក្រគ្មានជម្រើស នៅក្រោមសម្ពាធនៃកម្លាំងសាមគ្គីរបស់ពលករខ្មែររាប់ពាន់នាក់ ខណៈការតវ៉ាពីពលករក្នុងចំនួនខ្ទង់រយនាក់នាពេលកន្លងមកគ្មានប្រសិទ្ធភាព។ លោក សុខ នៅ និយាយថា៖ «**ដោយសារតែគាត់ពិបាករកដង្ហើមហើយ បានគាត់រកដំណោះស្រាយឱ្យហ្នឹងនោះ។ បើសិនល្មមៗ គាត់មិនដោះស្រាយឱ្យទេ។ សូម្បីតែពលករតវ៉ាដល់ថ្នាក់ហ្នឹងហើយ គាត់នៅចង់រកលេសនិយាយអញ្ចេះនិយាយអញ្ចុះទៀត ប៉ុន្តែដោយសារពលករមិនព្រម**»។

ពលករចំណាកស្រុកមកពីខេត្តកំពង់ធំម្នាក់ ឈ្មោះ អ៊ុំ សុយ៉ុង លើកឡើងថា មូលហេតុនៃការផ្ទុះការតវ៉ាទ្រង់ទ្រាយធំនៅរោងចក្រ GFN គឺបណ្តាលមកពីពលករខ្មែរមិនអាចទ្រាំទ្រនឹងការកេងប្រវ័ញ្ចកម្លាំងពលកម្ម បន្ថែមពីលើសេរីភាពដើរហើរពីសំណាក់ថៅកែថៃបានតទៅទៀត ក្នុងរយៈពេល៣ខែចុងក្រោយនេះ។ កម្មករផ្នែកពន្លះសាច់មាន់រូបនេះ បន្តថា លោកនិងកម្មករដទៃទៀត មិនដែលប្តឹង មិនដែលស្នើទៅមេការដោះស្រាយបញ្ហាពួកគាត់ទេពីមុនមក ដោយសារតែពួកគេមិនហ៊ាន ខ្លាចបាត់បង់ការងារ រហូតដល់គ្រប់គ្នាទ្រាំលែងបានចំពោះការរឹតត្បិតសេរីភាពនិងសម្ពាធសេដ្ឋកិច្ច។ លោក សុយ៉ុង បន្ថែមថា ខាងរោងចក្របានកាត់លុយថ្លៃស្នាក់នៅកាន់តែច្រើនដោយឡើងពី៣០០បាតដល់៩០០បាត ហើយតម្រូវឱ្យលោកធ្វើការកាត់សាច់មាន់ឱ្យគ្រប់តាមចំនួនកំណត់ ដែលហួសពីសមត្ថភាពរបស់លោក និងបានធ្វើឱ្យលោកបាត់បង់ចំណូលពីការធ្វើការថែមម៉ោងដូចមុន។ លោក សុយ៉ុង ប្រាប់ថា៖ «**ពីមុនមក វាអត់សូវតឹងតែងទេ ឥលូវវាតឹងតែងដល់កម្រិត កាត់សាច់ខុសបន្តិចមិនបាន ឱ្យចូល១០០ភាគរយពេញហ្មង។ ឱ្យយើងធ្វើ១០០ភាគរយហើយ ឱ្យយើងម៉ៅ យើងម៉ៅ យើងធ្វើម៉េចបានបង។ ធម្មតាយើងម៉ៅ យើងមិនត្រូវធ្វើលឿន។ ដល់ពេលនេះ វាឱ្យយើងម៉ៅ ហើយឱ្យធ្វើ១០០ភាគរយ អញ្ចឹងយើងធ្វើម៉េចបានលឿន**»។

វីអូឌី មិនអាចសុំការបញ្ជាក់ពីអ្នកគ្រប់គ្រងកម្មករកម្ពុជានៅរោងចក្រ GFN លោក ស៊ីម ចាន់ថន បានទេនៅថ្ងៃចន្ទនេះ។

មន្ត្រីផ្នែកអន្តោប្រវេសន៍ប្រចាំប្រទេសថៃ នៃមជ្ឈមណ្ឌលសម័ន្ធភាពការងារ និងសិទ្ធិមនុស្ស ឬហៅកាត់សង់ត្រាល់ លោក លឹង សុផុន លើកឡើងថា តំណាងរោងចក្រ បានព្រមទទួលយកសំណើរបស់កម្មករទៅដោះស្រាយគ្រប់លក្ខខណ្ឌ ប៉ុន្តែយ៉ាងណា លោកនៅរង់ចាំមើលលទ្ធផលជាក់ស្តែងនៅពេលខាងមុខសិន។ លោក សុផុន ប្រាប់ថា៖ «**យើងឃើញថា ខាងរោងចក្រគេបានទទួលសន្យានូវអ្វីដែលពលករបានលើកឡើងនូវបញ្ហារបស់ពួកគាត់អញ្ចឹង។ តែអ្វីដែលយើងមិនទាន់ឃើញច្បាស់ថា តើរោងចក្រហ្នឹង គាត់បានគោរពតាមច្បាប់ តាមលក្ខន្តិកៈនៅឡើយឬយ៉ាងណា គឺខាងរោងចក្រមិនទាន់បង្ហាញទេ**»។

កាលពីថ្ងៃពុធ ទី១១ ខែវិច្ឆិកា ពលករចំណាកស្រុកកម្ពុជាប្រមាណ៥រយនាក់ ប្រមូលផ្តុំគ្នាលើកសំណើទៅតំណាងរោងចក្រ ស្នើឱ្យជួយដោះស្រាយបញ្ហារបស់ពួកគេ៣ចំណុច ដែលរួមមាន ការឡើងថ្លៃបន្ទប់ស្នាក់នៅ និង

ថ្លៃពន្យារទិដ្ឋការការងារ ការហាមឃាត់ពលករខ្មែរចេញក្រៅរោងចក្រ ដោយតម្រូវឱ្យពួកគេទិញម្ហូបដាក់លក់ខាងក្នុងរោងចក្រដែលមានតម្លៃខ្ពស់ និងការរឹតបន្តឹងលក្ខខណ្ឌការងារដែលធ្វើឱ្យប្រាក់ខែរបស់ពួកគេធ្លាក់ចុះទាប៕

## ថ្ងៃទី១៨ ខែ វិច្ឆិកា ឆ្នាំ២០២០

### អំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ គឺជាឧក្រិដ្ឋកម្មមួយ ដែល ត្រូវរួមគ្នាទប់ស្កាត់

https://www.pdikampongcham.info/ ១៧ ខែវិច្ឆិកា ២០២០ **អត្ថបទដោយៈ លោក ជឹម សារ៉ន**

ការបង្ក្រាបបទល្មើសជួញដូរមិនអាចមានតែសមត្ថកិច្ចទេ ត្រូវមានការសហការចូលរួមដៃគូរ សហការ អង្គការនានា និងស្ថាប័នដែលពាក់ព័ន្ធស្ថាប័នពាក់ព័ន្ធជាពិសេសប្រជាពរដ្ឋ ទើបធ្វើឲ្យបទល្មើសការជួញដូរមនុស្សមានការថយចុះនិងមានប្រសិទ្ធភាព។ នោះបើតាមការឲ្យដឹងពីលោកស្រី វរសេនីយ៍ឯក ហេង ដាឡែន ប្រធានការិយាល័យប្រឆាំងការជួញដូរមនុស្ស និងការពារអនិតិជន នៃស្នងការដ្ឋាននគរបាលខេត្តកំពង់ចាម។ លោកស្រី វរសេនីយ៍ឯក ហេង ដាឡែន លើកឡើងបែបនេះ ក្នុងឱកាស ចូលរួមនៅក្នុងកម្មវិធីសន្ទនាមិតវិទ្យុជាតិភ្នំប្រុសភ្នំស្រីខេត្តកំពង់ចាមនាថ្ងៃអង្គារទី១៧ខែឆ្នាំវិច្ឆិកា ឆ្នាំ០២០ ក្រោមប្រធានបទ(«ប្រសិទ្ធភាពនៃការទប់ស្កាត់ជួញដូរមនុស្សនៅតាមមូលដ្ឋាន»)បញ្ហាជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ មិនមែនជាបញ្ហា របស់ស្ថាប័ ស្នងការដ្ឋាន តែឯងនោះទេ ប៉ុន្តែវាជាបញ្ហារួមរបស់យើងទាំងអស់គ្នា ហើយវាទាមទារការចូលរួម ឱ្យកាន់តែសកម្មពីគ្រប់ភាគី និងតួអង្គដែលពាក់ព័ន្ធ ក្នុងគោលដៅការពារប្រជាពលរដ្ឋ នៅក្នុងខេត្តរបស់យើង ហើយជាពិសេសជាងនេះទៅទៀត គឺការពារស្ត្រី និងកុមារដែលពួក គេជាជនដែលងាយរងគ្រោះ និងងាយធ្លាក់ក្នុងអន្ទាក់របស់ពួកមេខ្យល់ និងជនល្មើសនៃអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ។

លោកស្រីបានប្រកាន់ជំហរ រឹងមាំ ដោយសហការជាមួយ ស្ថាប័នជំនាញ ដើម្បី ប្រយុទ្ធប្រឆាំងនឹងអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ដោយបង្កើនការទប់ស្កាត់ និងស្វែងរកបទល្មើស និងបង្ក្រាបកាន់តែម៉ឺងម៉ាត់ និងប្រុងប្រយ័ត្នជានិច្ច មិនអនុញ្ញាតឱ្យជនល្មើស អន្តរការី (មេខ្យល់)ទាំងឡាយណា មានឱកាសពង្រីកសកម្មភាពបង្កភាពរងគ្រោះដល់ប្រជាពលរដ្ឋយើង។ក្នុងនោះសម្រាប់ឆ្នាំ២០២០នេះធ្វើការបង្កាប់បានចំនួន០៤ករណី។ លោកស្រី ក៏បានអំពាវនាវឲ្យពលរដ្ឋខ្មែរទាំងអស់រាយការណ៍អំពីករណីជួញដូរមនុស្សតាមរយៈអាជ្ញាភូមិឃុំ ប៉ុស្តិ៍រដ្ឋបាលដែលនៅជិតលោក អ្នក និងតាមរយៈទូរស័ព្ទលោកស្រីផ្ទាស់០៨១៣៧៣៨៣៩ យើងនឹងរក្សាការណ៍សម្ងាត់ជូន។

### ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិប៉ោយប៉ែត បានទទួលពលករខ្មែរ ឆ្លងដែនខុសច្បាប់ ដែលអាជ្ញាធរថៃបញ្ជូនមក មានចំនួន ០៩នាក់

https://www.facebook.com/GDIOfficial 17-11-2020

ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិប៉ោយប៉ែត នាថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០២០ វេលាម៉ោង ១៦និង១៥នាទី បានទទួលពលករខ្មែរ ឆ្លងដែនខុសច្បាប់ ដែលអាជ្ញាធរថៃបញ្ជូនមក មានចំនួន ០៩នាក់។ ចំពោះពលករខាងលើ ត្រូវបានកម្លាំងនគរបាលប៉ុស្តិ៍ធ្វើការអប់រំណែនាំបន្ទាប់មកប្រគល់ជូនក្រុមការងារទទួលពលករមជ្ឈមណ្ឌលសំចតប៉ោយប៉ែត ដើម្បីធ្វើការបន្ត។ ជាមួយគ្នានេះដែរ អាជ្ញាធរថៃនៅតែបន្តបិទច្រកទ្វារព្រំដែន មិនទាន់បើកឱ្យអ្នកដំណើរចេញ-ចូលឆ្លងកាត់នៅឡើយចំពោះអ្នកជំងឺសង្គ្រោះបន្ទាន់និងរថយន្តដឹកទំនិញធុនធំ ដំណើរការជាធម្មតា៕

## ពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ១៩៧នាក់

https://www.facebook.com/GDIOfficial 17-11-2020

នៅថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០២០ វេលាម៉ោង ១៥និង០០នាទី ភាគីថៃនៅតែបន្តបិទច្រកទ្វារព្រំដែនអន្តរជាតិ ឆង ចម ខេត្តសុរិន្ទ ទល់មុខច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ ជាបណ្តោះអាសន្ន មិនអនុញ្ញាតឲ្យអ្នកដំណើរ គ្រប់សញ្ជាតិចេញ-ចូល ឆ្លងកាត់ដើម្បីបង្ការ និងទប់ស្កាត់ការរាតត្បាតនៃជំងឺឆ្លងកូវីដ-១៩។ ក្នុងការបិទច្រកនេះ ភាគីថៃបានលើកលែង ទំនិញដែលទទួលបានការអនុញ្ញាត និងអ្នកបើកបររថយន្តដឹកទំនិញដែលទទួលបានការអនុញ្ញាត ព្រមទាំងបានការឆ្លងកាត់ត្រួតពិនិត្យ ដោយសមត្ថកិច្ចទាំងភាគី កម្ពុជា-ថៃ បានត្រឹមត្រូវ និងពលរដ្ឋខ្មែរ ឬពលរដ្ឋថៃ ដែលត្រូវវិលត្រឡប់ចូលប្រទេសរៀងៗខ្លួន។ ចំណែកឯពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ១៩៧នាក់ ស្រី ៨៧នាក់ និងបានទទួលពលរដ្ឋខ្មែរចំនួន ០១នាក់ ពីភាគីថៃ ពាក់ព័ន្ធនឹងបទលួចចូលកាប់ឈើខុសច្បាប់ ក្នុងទឹកដីប្រទេសថៃ៕

## ថ្ងៃទី១៩ ខែ វិច្ឆិកា ឆ្នាំ២០២០

### សេចក្តីបំភ្លឺព័ត៌មានរបស់នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន

http://cambodiapolice.com/policekh/ 4:02 pm 18 វិច្ឆិកា 2020

រាជធានីភ្នំពេញ ៖ ក្រុមការងារប្រតិកម្មរហ័សនៃនាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជនពិនិត្យឃើញថា កាលពីថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០២០ គណនីហ្វេសប៊ុកឈ្មោះ Child Helpline Cambodia បានផ្ញើខ្លឹមសារ អមជាមួយរូបភាព បង្ហោះក្នុងបណ្តាញទំនាក់ទំនងសង្គមហ្វេសប៊ុកពាក់ព័ន្ធជាមួយនឹងអំពើហិង្សាលើអនីតិជន ។ អនុវត្តតាមបទបញ្ជារបស់ឯកឧត្តម នាយឧត្តមសេនីយ៍ សន្តិបណ្ឌិត នេត សាវឿន អគ្គស្នងការនគរបាលជាតិ និងលោកជំទាវ នាយឧត្តមសេនីយ៍ យក់ សុខា អគ្គស្នងការរងទទួលការងារជំនាញឯកឧត្តមឧត្តមសេនីយ៍ឯក ជីវ ផល្លី ប្រធាននាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជនបានចាត់តាំងមន្ត្រីជំនាញធ្វើការស្រាវជ្រាវស្វែងរកប្រភពពិតប្រាកដនៃករណី និងអនុវត្តជំនាញ ។ នាយកដ្ឋានជំនាញបានហការជាមួយស្នងការដ្ឋាននគរ បាលខេត្តក្រចេះស្រាវជ្រាវរកឃើញថា ករណីហិង្សានេះកើតហេតុនៅភូមិកសាង ឃុំចង្រង់ ស្រុកចិត្របុរី ខេត្តក្រចេះ និងបានចាត់តាំងកម្លាំងជំនាញចុះអន្តរាគមន៍ និងឈានដល់កោះអញ្ជើញជនសង្ស័យឈ្មោះ រិន ហ៊ា ភេទប្រុស អាយុ៣១ឆ្នាំ ជនជាតិខ្មែរមុខរបរកសិករ ស្នាក់នៅមូលដ្ឋានកើតហេតុខាងលើ មកសាកសួរបំភ្លឺនៅប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំចង្រង់ ។ នៅចំពោះមុខសមត្ថកិច្ច ជនសង្ស័យបានសារភាពថា ពិតជាបានប្រព្រឹត្តអំពើហិង្សាដោយវាយទៅលើកុមារាឈ្មោះ ម៉េង ហ៊ាង អាយុ ៣ឆ្នាំ ត្រូវជាក្មួយបង្កើត(កូនចិញ្ចឹម) មូលហេតុបណ្តាលមកពីក្មេងយំពុំដឹងមូលហេតុ និងនោមដាក់ចានបាយ ចានសម្លរទៀតផង។ ជនសង្ស័យរូបនេះបានបញ្ជាក់បន្ថែមថា ក្មេងប្រុសខាងលើ គាត់បានយកមកចិញ្ចឹមតាំងពីកើតមកម្ល៉េះ ដោយសារតែឪពុកម្តាយបង្កើតរបស់ក្មេងនេះបានលែងលះគ្នា និងបានធ្វើចំណាកស្រុកទៅធ្វើការងារតាមបណ្តាខេត្តផ្សេង។

ឯកឧត្តម ឧត្តមសេនីយ៍ឯក ជីវ ផល្លី ប្រធាននាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជនបញ្ជាក់ថាជនសង្ស័យឈ្មោះ រិន ហ៊ា ត្រូវបានកម្លាំងជំនាញឃាត់ខ្លួននៅអធិការដ្ឋាននគរបាលស្រុកចិត្របុរី ខេត្តក្រចេះ ដើម្បីកសាងសំណុំរឿងបញ្ជូនទៅសាលាដំបូងខេត្តក្រចេះតាមនីតិវិធី។ នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះសាធារណជន បណ្តាញទំនាក់ទំនង

សង្គម ពិសេសម្ចាស់គណនីហ្វេសប៊ុកខាងលើ ដែលបានសហការផ្តល់ព័ត៌មានក្នុងការចូលរួមចំណែករក្សាសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ និងសុវត្ថិភាពសង្គម ក៏ដូចជាការចូលរួមចំណែកគាំពារសិទ្ធិរបស់កុមារកម្ពុជា ៕

## ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិប៉ោយប៉ែត បានទទួលពលករខ្មែរ ឆ្លងដែនខុសច្បាប់ ដែលអាជ្ញាធរថៃបញ្ជូនមក មានចំនួន ៤៩នាក់

https://www.facebook.com/GDIOfficial 18-11-2020

ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិប៉ោយប៉ែត នាថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០២០ បានទទួលពលករខ្មែរ ឆ្លងដែនខុសច្បាប់ ដែលអាជ្ញាធរថៃបញ្ជូនមក មានចំនួន ៤៩នាក់ ស្រី ១៤នាក់ និងកុមារ០១នាក់។ ចំពោះពលករខាងលើ ត្រូវបានកម្លាំងនគរបាលប៉ុស្តិ៍ធ្វើការអប់រំណែនាំបន្ទាប់មកប្រគល់ជូនក្រុមការងារទទួលពលករមជ្ឈមណ្ឌលសំចតប៉ោយប៉ែត ដើម្បីធ្វើការបន្ត។ ជាមួយគ្នានេះដែរ អាជ្ញាធរថៃនៅតែបន្តបិទច្រកទ្វារព្រំដែន មិនទាន់បើកឱ្យអ្នកដំណើរចេញ-ចូលឆ្លងកាត់នៅឡើយចំពោះអ្នកជំងឺសង្គ្រោះបន្ទាន់និងរថយន្តដឹកទំនិញធន់ធំដំណើរការជាធម្មតា៕

## ពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ១៨១នាក់

https://www.facebook.com/GDIOfficial 18-11-2020

នៅថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០២០ វេលាម៉ោង ១៥និង០០នាទី ភាគីថៃនៅតែបន្តបិទច្រកទ្វារព្រំដែនអន្តរជាតិ ឆង ចម ខេត្តសុរិន្ទ ទល់មុខច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ ជាបណ្តោះអាសន្ន មិនអនុញ្ញាតឲ្យអ្នកដំណើរ គ្រប់សញ្ជាតិចេញ-ចូល ឆ្លងកាត់ ដើម្បីបង្ការ និងទប់ស្កាត់ការរាតត្បាតនៃជំងឺឆ្លង កូវីដ-១៩។ ក្នុងការបិទច្រកនេះ ភាគីថៃបានលើកលែង ទំនិញដែលទទួលបានការអនុញ្ញាត និងអ្នកបើកបររថយន្តដឹកទំនិញ ដែលទទួលបានការអនុញ្ញាត ព្រមទាំងបានការឆ្លងកាត់ត្រួតពិនិត្យ ដោយសមត្ថកិច្ចទាំងភាគី កម្ពុជា-ថៃ បានត្រឹមត្រូវ និងពលរដ្ឋខ្មែរ ឬពលរដ្ឋថៃ ដែលត្រូវវិលត្រឡប់ចូលប្រទេសរៀងៗខ្លួន។ ចំណែកឯពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ១៨១នាក់ ស្រី ៨៣នាក់ និងពលរដ្ឋថៃដែលបានចាកចេញមានចំនួន ០១នាក់៕

## ព្រឹត្តិការណ៍កូវីដដ៏ស្មុគ្រស្មាញធំៗ៤ ដែលកម្ពុជាឆ្លងផុត!

https://kleykley.sabay.com.kh/ 19-11-2020

ក្នុងបរិបទនៃការប្រយុទ្ធប្រឆាំងនឹងកូវីដ១៩ កម្ពុជាបានឆ្លងកាត់ និងគ្រប់គ្រងសភាពការណ៍បាននូវព្រឹត្តិការណ៍ធំៗដ៏ស្មុគ្រស្មាញចំនួន៤ គិតចាប់តាំងពីដើមឆ្នាំ២០២០មក រួមមាន៖

១. ព្រឹត្តិការណ៍នៃការវិលត្រឡប់របស់បងប្អូនពលករកម្ពុជា ចូលមកក្នុងប្រទេសនៅពេលដែលកំពុងតែមានការរាតត្បាតខ្លាំងនៅបណ្តាប្រទេសក្នុងតំបន់ និងនៅលើសកលលោក។

២. ព្រឹត្តិការណ៍នាវាខ្នាតយក្ស MS Westerdam ចូលចតនៅកំពង់ផែខេត្តព្រះសីហនុ។

៣. ការគ្រប់គ្រងអ្នកដំណើរមកពីក្រៅប្រទេស ក្នុងពេលដែលមានការគិតគូរដោយយកចិត្តទុកដាក់ក្នុងការសម្រួលឱ្យបងប្អូនខ្មែរដែលជាប់គាំងនៅក្រៅប្រទេស អាចបានវិលត្រឡប់មកកាន់ផ្ទះរបស់ខ្លួនវិញ និងតម្រូវការនៃអ្នកដំណើរផ្សេងៗទៀតចូលមកកាន់កម្ពុជា។

៤. ព្រឹត្តិការណ៍៣វិច្ឆិកា ដែលទើបតែបញ្ចប់។

## ពលករខ្មែរម្នាក់ត្រូវអាជ្ញាធរថៃ ឃាត់ខ្លួននៅទីក្រុងបាងកក

http://nokorwatnews.com/ 18-11-2020

អន្តរជាតិ៖ កាលពីថ្មីៗនេះក្នុងចំណោមពលករចំណាកស្រុកខុសច្បាប់ចំនួន៨នាក់ ក្នុងនោះមានពលករខ្មែរម្នាក់ផងដែរ ត្រូវបានឃាត់ខ្លួននៅក្នុងទីក្រុងបាងកក ប្រទេសថៃ គ្រាដែលអាជ្ញាធរថៃអនុវត្តវិធានការទប់ស្កាត់ពលករខុសច្បាប់ដើម្បីការពារការរីករាលដាលនៃជំងឺកូវីដ១៩ ។

យោងតាមអ្នកនាំពាក្យនៃការិយាល័យអន្តោប្រវេសន៍ប្រចាំទីក្រុងបាងកកលោក Pakkhapong Sai-ubon បានឲ្យដឹងថា ការចាប់ខ្លួនពលករខុសច្បាប់ទាំងនេះត្រូវបានធ្វើឡើងនៅទីតាំងផ្សេងៗគ្នា ចាប់តាំងពីថ្ងៃទី២ មកដល់ថ្ងៃទី១១ វិច្ឆិកានេះ ហើយនៅក្នុងប្រតិបត្តិការចុះត្រួតពិនិត្យនេះអាជ្ញាធរថៃក៏បានឃាត់ខ្លួនពលរដ្ឋថៃម្នាក់ផងដែរពីបទផ្តល់កន្លែងស្នាក់នៅដល់ពលករខុសច្បាប់ផងដែរ។ អ្នកនាំពាក្យរូបនេះបានបន្តថា ពលករចំណាកស្រុកខុសច្បាប់ទាំងអស់នោះមាន ៤ នាក់មកពីប្រទេសឡាវ ២ នាក់មកពីប្រទេសមីយ៉ាន់ម៉ា ១ មកពីប្រទេសនីហ្សេរីយ៉ា និង ១នាក់ទៀតមកពីប្រទេសកម្ពុជា។ អាជ្ញាធរថៃបានបញ្ជាក់បន្ថែមថា ពលករខុសច្បាប់ទាំង ៨ នាក់ត្រូវផ្តន្ទាទោសពីបទចូលមកក្នុងប្រទេសថៃដោយគ្មានអនុញ្ញាត និងស្នាក់នៅក្នុងប្រទេសថៃក្នុងរយៈពេលយូរ លើសការ កំណត់។ ដោយឡែកសម្រាប់ជនជាតិខ្មែរម្នាក់ត្រូវទទួលទោសមួយករណីបន្ថែមទៀត គឺការធ្វើការងារដោយគ្មាន ការអនុញ្ញាត៕ ដោយ៖ស តារា

## រោងចក្រកែច្នៃសាច់មាន់មួយកន្លែង ក្នុងប្រទេសថៃ យល់ព្រមតាមការទាមទារមួយចំនួនរបស់ក្រុមពលករខ្មែរ

https://www.rfa.org/khmer/ ដោយ សុជីវី 2020-11-18

រោងចក្រកែច្នៃសាច់មាន់មួយកន្លែងក្នុងប្រទេសថៃយល់ព្រមតាមការទាមទារមួយចំនួនរបស់ក្រុមពលករខ្មែរដែលបានតវ៉ាកាលពីសប្តាហ៍មុន។ អ្នកសម្របសម្រួលបណ្តាញពលករខ្មែរនៅប្រទេសថៃ លោក ប្រាក់ ភត្រា ប្រាប់អាស៊ីសេរីនៅយប់ថ្ងៃទី១៧ វិច្ឆិកាម្សិលមិញថា មានចំណុចមួយចំនួនដែលភាគីរោងចក្រយល់ព្រមផ្តល់ដំណោះស្រាយអោយពលករខ្មែរ ហើយក៏នៅសេសសល់ចំណុចមួយចំនួនទៀតមិនទាន់ដោះស្រាយដែរ៖ «អ្វីដែលពលករទាមទារដូចជាការចេញទៅក្រៅ រឿងថ្លៃបន្ទប់ ហើយនឹងរឿងថ្លៃឯកសារ នេះបើតាមពួកគាត់ប្រាប់មក។ ប៉ុន្តែនៅបញ្ហាមួយចំនួនទៀត ដែលគាត់រង់ចាំខាងក្រុមហ៊ុនគេពិភាក្សាគ្នា ហើយខ្ញុំអត់ទាន់ដឹងថា គេមានវិធានការយ៉ាងម៉េចទេ»។

ពលករខ្មែរប្រមាណប្រាំរយ(៥០០)នាក់ក្នុងចំណោមពលករខ្មែរជាងបីពាន់ (៣ ០០០)នាក់ ដែលធ្វើការនៅរោងចក្រផលិត និងកែច្នៃសាច់មាន់ ឈ្មោះជី.អេហ្វ.អិន (GFN) ក្នុងខេត្តឈុនបូរី (Chunburi) ប្រទេសថៃបាននាំគ្នាតវ៉ាតាំងពីថ្ងៃទី១១ វិច្ឆិកា ដើម្បីទាមទារដំណោះស្រាយ ៣ចំណុចរួមមាន ការទម្លាក់ប្រាក់ឈ្នួលប្រចាំខែចុះទាបជាងមុន ប៉ុន្តែបែរជាតម្លើងថ្លៃជួលបន្ទប់ស្នាក់នៅ និងការហាមពលករ មិនឱ្យចេញទៅក្រៅបរិវេណរោងចក្រ។ នៅក្នុងពេលតវ៉ានោះថៅកែបានសន្យាថានឹងលើកលែងថ្លៃឈ្នួលបន្ទប់ស្នាក់នៅដែលមានតម្លៃពីបីរយ(៣០០)បាត ទៅប្រាំមួយរយហាសិប(៦៥០)បាតឬប្រមាណពី១០ដុល្លារទៅ២៥ដុល្លារ ក្នុងមួយខែប៉ុន្តែមិនមានដំណោះស្រាយករណីប្រាក់ឈ្នួលប្រចាំខែ ដែលថៅកែកាត់បន្ថយ ដោយហេតុផល វិបត្តិជំងឺកូវីដ-១៩។

ព័ត៌មានពីហ្វេសប៊ុករបស់បណ្តាញពលករខ្មែរនៅប្រទេសថៃឱ្យដឹងថា នៅថ្ងៃទី១២ វិច្ឆិកា តំណាងស្ថានទូតខ្មែរប្រចាំនៅប្រទេសថៃ និងមន្ទីរការងារខេត្តឈុនបុរីបានចុះទៅដល់ក្រុមហ៊ុន ដើម្បីពិភាក្សារកដំណោះស្រាយបញ្ហា

ពលករតៅ គឺបញ្ហាថ្លៃដំណើរការឯកសារ ថ្លៃបន្ទប់ស្នាក់នៅថ្លៃម្ហូបអាហារនៅក្នុងក្រុមហ៊ុន និងការរឹតបន្តឹងក្នុងការចេញចូលក្រុមហ៊ុននេះ៕

## ថ្ងៃទី២០ ខែ វិច្ឆិកា ឆ្នាំ២០២០

### ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិប៉ោយប៉ែត បានទទួលពលករខ្មែរ ឆ្លងដែនខុសច្បាប់ ដែលអាជ្ញាធរថៃបញ្ជូនមក មានចំនួន ១៦នាក់

https://www.facebook.com/GDIOfficial 19-11-2020

ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិប៉ោយប៉ែត នាថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០២០ វេលាម៉ោង ១៧និង៥០នាទីបានទទួលពលករខ្មែរ ឆ្លងដែនខុសច្បាប់ ដែលអាជ្ញាធរថៃបញ្ជូនមក មានចំនួន ១៦នាក់ ស្រី ០៦នាក់ និងកុមារ ០២នាក់៕ ចំពោះពលករខាងលើ ត្រូវបានកម្លាំងនគរបាលប៉ុស្តិ៍ ធ្វើការអប់រំណែនាំ បន្ទាប់មកប្រគល់ជូនក្រុមការងារ ទទួលពលករមជ្ឈមណ្ឌលសំចតប៉ោយប៉ែត ដើម្បីធ្វើការបន្ត៕ ជាមួយគ្នានេះដែរ អាជ្ញាធរថៃនៅតែបន្តបិទច្រកទ្វារព្រំដែន មិនទាន់បើកឱ្យអ្នកដំណើរចេញ-ចូលឆ្លងកាត់នៅឡើយ ចំពោះអ្នកជំងឺសង្គ្រោះបន្ទាន់ និងរថយន្តដឹកទំនិញធន់ធំ ដំណើរការជាធម្មតា៕

### ភាគីថៃបានបញ្ជូនពលរដ្ឋខ្មែរចំនួន ០១នាក់ ឲ្យមកប៉ុស្តិ៍នគរបាល ច្រកទ្វារព្រំដែនអន្តរជាតិដាំ ពីបទឆ្លងដែនខុសច្បាប់

https://www.facebook.com/GDIOfficial 19-11-2020

នៅថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០២០ ខាងភាគីថៃបានបញ្ជូនពលរដ្ឋខ្មែរចំនួន ០១នាក់ ឲ្យមកប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិដាំ ពីបទឆ្លងដែនខុសច្បាប់ ទៅកាប់ឈើនៅប្រទេសថៃ ដែលចេញតាមច្រកចាក់ជ្រែងខេត្តព្រះវិហារ៕

### ពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ១០២នាក់

https://www.facebook.com/GDIOfficial 19-11-2020

នៅថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០២០ វេលាម៉ោង ១៥និង០០នាទី ភាគីថៃនៅតែបន្តបិទច្រកទ្វារព្រំដែនអន្តរជាតិ ឆង ចម ខេត្តសុរិន្ទ ទល់មុខច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ ជាបណ្ដោះអាសន្ន មិនអនុញ្ញាតឲ្យអ្នកដំណើរ គ្រប់សញ្ជាតិចេញ-ចូល ឆ្លងកាត់ ដើម្បីបង្ការនិងទប់ស្កាត់ការរាតត្បាតនៃជំងឺឆ្លងកូវីដ-១៩៕ ក្នុងការបិទច្រកនេះ ភាគីថៃបានលើកលែង ទំនិញដែលទទួលបានការអនុញ្ញាត និងអ្នកបើកបររថយន្តដឹកទំនិញដែលទទួលបានការអនុញ្ញាត ព្រមទាំងបានការឆ្លងកាត់ត្រួតពិនិត្យ ដោយសមត្ថកិច្ចទាំងភាគី កម្ពុជា-ថៃ បានត្រឹមត្រូវ និងពលរដ្ឋខ្មែរ ឬពលរដ្ឋថៃ ដែលត្រូវវិលត្រឡប់ចូលប្រទេសរៀងៗខ្លួន៕ ចំណែកឯពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ១០២នាក់ ស្រី ៤៤នាក់ និងអ្នកដំណើរជាពលរដ្ឋខ្មែរ ចាកចេញពីប្រទេសចំនួន ២០នាក់ ស្រី ១២នាក់ ជានិស្សិតដែលត្រូវទៅបន្តការសិក្សានៅប្រទេសថៃ៕

## កម្ពុជាចាប់ផ្តើមបញ្ជូនពលករ ទៅធ្វើការនៅប្រទេសជប៉ុនជាបណ្តើរៗហើយ

http://kampucheathmey.com/ November 20, 2020 By **Sorn Phanit**

កម្ពុជាបានចាប់ផ្តើមបញ្ជូនកម្មសិក្សាការី និងពលករជំនាញពី៥០០ ទៅ៦០០នាក់ ក្នុង១ខែៗ ទៅធ្វើការលើវិស័យផ្សេងៗនៅប្រទេសជប៉ុនជាបណ្តើរៗហើយ បន្ទាប់ពីបានផ្អាកកាលពីខែមេសាកន្លងទៅ ដោយសារការផ្ទុះរាតត្បាតជំងឺកូវីដ១៩។

លោក អន ប៊ុនហាក់ ប្រធានសមាគមទីភ្នាក់ងារហត្ថពលកម្មកម្ពុជា បានឲ្យដឹងនៅព្រឹកថ្ងៃទី២០ វិច្ឆិកាថា កម្មសិក្សាការីនិងពលករជំនាញ ដែលបញ្ជូនទៅធ្វើការនៅជប៉ុន គឺធ្វើទៅលើផ្នែកកសិកម្ម វេចខ្ចប់ សេវាកម្មសណ្ឋាគារ និងសំណង់។ លោកបានបន្តថា«ប្រសិនបើមិនមានការហាមប្រាមការធ្វើដំណើរឬមានបញ្ហា ដោយសារជំងឺកូវីដ១៩នោះ យើងនឹងបន្តបញ្ជូនពលករជាបន្តបន្ទាប់រហូតដល់គ្រប់ចំនួន ព្រោះជប៉ុនត្រូវការពលករខ្មែរប្រមាណ១ម៉ឺននាក់ ក្នុងមួយឆ្នាំប៉ុន្តែដោយសារកូវីដ១៩ ទើបយើងមិនអាចបញ្ជូនទៅគ្រប់ចំនួនបាន»។ លោកបានបន្តទៀតថា តាមផែនការនៅឆ្នាំ២០២០នេះ កម្ពុជាគ្រោងនឹងបញ្ជូនពលករទៅធ្វើការនៅក្រៅប្រទេសប្រមាណ២០ម៉ឺននាក់ ក្នុងនោះរួមមានប្រទេសថៃ ជប៉ុន សិង្ហបុរី ហុងកុងនិងម៉ាឡេស៊ី ប៉ុន្តែ រហូតមកដល់ពេលនេះ បញ្ជូនបានត្រឹមតែ៥ម៉ឺននាក់ប៉ុណ្ណោះ ដោយសារប្រទេសទាំងនោះ មានបញ្ហាជំងឺកូវីដ១៩។ លោកបានបន្ថែមទៀតថា ក្នុងចំណោមប្រទេសទាំងនោះ មានតែប្រទេសជប៉ុនទេ ដែលកម្ពុជាបានបញ្ជូនពលករ និងកម្មសិក្សាការីទៅធ្វើការ។ ក្រៅពីនោះនៅមិនទាន់បានបញ្ជូនទៅឡើយទេ ដោយសារមានបញ្ហាជំងឺកូវីដ១៩។

បើតាមក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈបានឲ្យដឹងថា បច្ចុប្បន្នមានកម្មសិក្សាការី និងពលករជំនាញទៅសិក្សា និងធ្វើការនៅប្រទេសជប៉ុនប្រមាណជិត១៥,០០០នាក់ ដោយធ្វើនៅក្នុងវិស័យកសិកម្ម នេសាទ សំណង់ កែច្នៃចំណីអាហារ កាត់ដេរ ថែទាំមនុស្សចាស់ គ្រឿងយន្ត-លោហធាតុ និងវិស័យផ្សេងៗទៀត។ គួរបញ្ជាក់ថាកម្ពុជាបានបញ្ជូនពលករទៅ ធ្វើការងារនៅក្រៅប្រទេសប្រមាណ១លាន២សែននាក់ នៅតាមបណ្តាប្រទេសមួយចំនួនដូចជាថៃ ជប៉ុន សិង្ហបុរី ហុងកុង កូរ៉េខាងត្បូងនិងម៉ាឡេស៊ី ដោយបានផ្ញើថវិកាមកកម្ពុជា ដើម្បីជួយទ្រទ្រង់ជីវភាពក្រុមគ្រួសារវិញ ប្រមាណជាង២ពាន់លានដុល្លារក្នុង១ឆ្នាំៗ។ **អត្ថបទ៖ សំអឿន**

## ថ្ងៃទី២៣ ខែ វិច្ឆិកា ឆ្នាំ២០២០

### នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស សម្របសម្រួលឲ្យស្ត្រី កំពុងរស់នៅប្រទេសចិន បានជួបសន្ទនាជាមួយក្រុមគ្រួសារ បន្ទាប់ពីបង្ហោះឃ្លីបវីដេអូ នៅលើបណ្តាញសង្គមហ្វេសប៊ុក

https://www.cen.com.kh/ November 21, 2020

ភ្នំពេញ៖ ក្រុមការងារប្រតិកម្មរហ័សនៃនាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជនពិនិត្យឃើញថា កាលពីថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ ២០២០ គណនីហ្វេសប៊ុកឈ្មោះ Ah Phalla ដែលកំពុងរស់នៅឯប្រទេសចិន បានផ្ញើខ្លឹមសារ អមជាមួយឃ្លីបវីដេអូ បង្ហោះក្នុងបណ្តាញទំនាក់ទំនងសង្គមហ្វេសប៊ុក អំពាវនាវចង់ជួបសន្ទនាជាមួយកូនស្រីដែលកំរស់នៅប្រទេសកម្ពុជាតាមរយៈទូរស័ព្ទ។

ដោយយល់ពីទំហំនៃសេចក្តីនឹករលឹករបស់ម្តាយចំពោះកូន ដែលបានបែកគ្នារយៈពេលជាង៧ឆ្នាំ ឯកឧត្តមឧត្តមសេនីយ៍ឯក ជីវ ផល្លី ប្រធាននាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន បានចាត់តាំងមន្ត្រីជំនាញធ្វើការស្រាវជ្រាវស្វែងរកប្រភពពិតប្រាកដនៃព័ត៌មាន និងអនុវត្តជំនាញ។ ថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០២០ កម្លាំងជំនាញនៃនាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន សហការជាមួយកម្លាំងជំនាញនៃស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ ស្រាវជ្រាវរកឃើញឈ្មោះ គឹម ថាវី អាយុ៥៧ឆ្នាំ មុខរបរ គប់ប៉េងប៉ោងនៅក្នុងសួនកម្សាន្តចំការព្រីង ស្នាក់នៅផ្ទះលេខ ២២សេ ភូមិព្រះពន្លា សង្កាត់ព្រែកប្រា ខណ្ឌច្បារអំពៅទូរស័ព្ទលេខ 096

95 94 453 ។ នៅចំពោះមុខសមត្ថកិច្ច អ្នកមីង ឌី ថាវី បានបញ្ជាក់ថា ស្ត្រីដែលបានបង្ហោះវីដេអូឃ្លីបពីប្រទេសចិនមកនោះ មានឈ្មោះ ឌី លីគុន អាយុ៣២ ឆ្នាំ ត្រូវជាកូនប្រសាក៏ប៉ុន្តែបានលែងលះគ្នាជាមួយប្តីចាប់តាំងពីកូនស្រីឈ្មោះ ទូច លីហ្សា អាយុបាន១ឆ្នាំ ដែលបច្ចុប្បន្ននេះកូនស្រីរូបនោះមានអាយុ៨ឆ្នាំហើយ និងកំពុងរស់នៅក្នុងបន្ទុកគ្រួសាររបស់គាត់ ។

តបតាមសំណូមពរស្ត្រីជាម្តាយដែលទទួលចង់ជួបសន្ទនាតាមទូរស័ព្ទជាមួយកូនស្រីរបស់ខ្លួន កម្លាំងជំនាញនៃនាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន បានខិតខំសម្របសម្រួលជូនក្រុមគ្រួសារបានជួបជជែកគ្នាតាមទូរស័ព្ទបានដោយជោគជ័យ។ ឯកឧត្តម ឧត្តមសេនីយ៍ឯក ជីវ ផល្លី បានសង្កត់ធ្ងន់ថា នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជននឹងខិតខំដោះស្រាយសំណូមពររបស់ប្រជាពលរដ្ឋ ទាំងការផ្តល់សេវាការងារជំនាញដោយផ្ទាល់ និងនៅលើបណ្តាញទំនាក់ទំនងសង្គម និងសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះសាធារណជនដែលបានសហការផ្តល់ព័ត៌មានក្នុងការចូលរួមចំណែករក្សាសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ និងសុវត្ថិភាពសង្គម ក៏ដូចជាការចូលរួមចំណែកក្នុងការងារយុត្តិធម៌សង្គមនៅកម្ពុជា ជាមួយកងកម្លាំងនគរបាលជាតិនៅទូទាំងប្រទេស ៕ **ដោយៈបញ្ញាស័ក្តិ**

## លេខាធិការដ្ឋាននៃគណៈកម្មាធិការប្រយុទ្ធប្រឆាំងបើកវគ្គបណ្តុះបណ្តាលពង្រឹងសមត្ថភាពក្រុមការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដល់រដ្ឋបាលស្រុកប្រាសាទបាគង

https://www.facebook.com/deputygovernoryousophear ថ្ងៃទី វិច្ឆិកា 21 នៅម៉ោង 8:44 AM ·

ថ្ងៃព្រហស្បតិ៍ ៤កើត ខែមិគសិរ ឆ្នាំជូត ទោស័ក ព.ស. ២៥៦៤ ត្រូវនឹងថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០២០ លេខាធិការដ្ឋាននៃគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ខេត្តសៀមរាប (គ.ខ.ប.ជ) សហការជាមួយរដ្ឋបាលស្រុកប្រាសាទបាគង និងអង្គការមូលនិធិ អេ២១ បានចុះបណ្តុះបណ្តាលពង្រឹងសមត្ថភាពដល់ក្រុមការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សនៅថ្នាក់ស្រុក និងថ្នាក់ឃុំ ដើម្បីលើកកម្ពស់ការយល់ដឹងអំពីការទប់ស្កាត់អំពើជួញដូរមនុស្ស និងអំពើកេងប្រវ័ញ្ចផ្សេងៗ និងការផ្តល់សេវាឱ្យបានសមស្របដល់ជនរងគ្រោះ និងងាយរងគ្រោះឱ្យកាន់តែមានប្រសិទ្ធភាពខ្ពស់។ វគ្គបណ្តុះបណ្តាលនេះទទួលបានការឧបត្ថម្ភគាំទ្រពីរដ្ឋបាលខេត្តសៀមរាប និងអង្គការមូលនិធិA21។

លោកស្រី យូ សុភា អភិបាលរងខេត្ត ជាប្រធានលេខាធិការដ្ឋាននៃគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ខ.ប.ជ) បានលើកឡើង អំពីការអភិវឌ្ឍលើគ្រប់វិស័យ តាមកម្មវិធីនយោបាយយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល ដោយបានផ្តោតខ្ពស់លើការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ការកេងកម្លាំងពលកម្ម ការធ្វើអាជីវកម្មផ្លូវភេទលើស្ត្រី កុមារនិងជនងាយរងគ្រោះ ព្រមទាំងបានដាក់ចេញនូវអនុសាសន៍គន្លឹះសំខាន់ៗ សំដៅពង្រឹងកិច្ចសហប្រតិបត្តិការជាតិ និងអន្តរជាតិ និងជំរុញឲ្យក្រុមការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សគ្រប់ថ្នាក់ខិតខំអនុវត្តច្បាប់ និងសហការកាន់តែខ្លាំងក្លាជាមួយគ្រប់ស្ថាប័នពាក់ព័ន្ធ អង្គការដៃគូជាតិ និងជំរុញឲ្យមានការចូលរួមពីប្រជាពលរដ្ឋ ដើម្បីរួមចំណែកលុបបំបាត់អំពើជួញដូរមនុស្សឲ្យបានជាស្ថាពរ រួមមាន៖

1,ជំរុញលើការពង្រឹងលើការរៀបចំកិច្ចប្រជុំ ត្រួតពិនិត្យ តាមដានលើបទល្មើសទាក់ទងនឹងអំពើជួញដូរមនុស្សនៅតាមមូលដ្ឋាន។

2,ត្រូវពង្រឹងលើការកំណត់អត្តសញ្ញាណជនរងគ្រោះឲ្យបានត្រឹមត្រូវ ដោយមានកិច្ចសហការជាមួយគ្រប់អ្នកពាក់ព័ន្ធ និងការផ្តល់សេវាជូនជនរងគ្រោះឲ្យបានសមស្របប្រកបដោយតម្លាភាព និងមានប្រសិទ្ធភាពខ្ពស់ទៅតាមនីតិវិធី។

3,ជំរុញលើការអនុវត្តច្បាប់ឱ្យបានម៉ឺងម៉ាត់សម្រាប់ជនល្មើសជួញដូរមនុស្ស និងជនប្រព្រឹត្តបទល្មើសរំលោភបំពានលើស្ត្រី និងកុមារ។

4, ជំរុញលើកិច្ចការពារកុមារពីការរំលោភបំពានផ្សេងៗ

5, ជំរុញឱ្យមានការគ្រប់គ្រងលើប្រព័ន្ធបញ្ជូនជនរងគ្រោះ តាមរយៈមន្ត្រីសង្គមកិច្ច

6, ជំរុញឲ្យមានការចូលរួមរាល់នីតិវិធីតុលាការ ពីមន្ត្រីសង្គមកិច្ច អាណាព្យាបាលឬ មន្ត្រីកិច្ចការនារី ឬអ្នកទទួលបន្ទុកកិច្ចការនារីឃុំ ក្នុងដំណើរការនីតិវិធីតុលាការរឿងក្តីរបស់កុមារ។

7, ជំរុញលើការរៀបចំរបាយការណ៍លទ្ធផលនៃការងារបង្ការទប់ស្កាត់អំពើជួញដូរមនុស្ស និងការគ្រប់គ្រងករណីដោយត្រូវបន្សុីគួលេខជាមួយថ្នាក់ឃុំ ថ្នាក់ស្រុក និងអង្គការដៃគូ ឲ្យបានច្បាស់លាស់ មុននឹងបញ្ជូនទៅក្រុមការងារថ្នាក់ខេត្ត ជៀសវាងជាន់ករណីគ្នាដែលធ្វើឲ្យមានការកើនឡើងទិន្នន័យ (ករណីតែមួយតែរាយការណ៍ច្រើនលើក)។

## ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិប៉ោយប៉ែត បានទទួលពលករខ្មែរ ឆ្លងដែនខុសច្បាប់ ដែលអាជ្ញាធរថៃបញ្ជូនមក មានចំនួន ០៦នាក់

https://www.facebook.com/GDIOfficial 22-11-2020

ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិប៉ោយប៉ែត នាថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០២០ វេលាម៉ោង ១៧និង១៥នាទីបានទទួលពលករខ្មែរ ឆ្លងដែនខុសច្បាប់ ដែលអាជ្ញាធរថៃបញ្ជូនមក មានចំនួន ០៦នាក់ ស្រី ០១នាក់។ ចំពោះពលករខាងលើ ត្រូវបានកម្លាំងនគរបាលប៉ុស្តិ៍ ធ្វើការអប់រំណែនាំ បន្ទាប់មកប្រគល់ជូនក្រុមការងារ ទទួលពលករមជ្ឈមណ្ឌលសំចតប៉ោយប៉ែត ដើម្បីធ្វើការបន្ត។ ជាមួយគ្នានេះដែរ អាជ្ញាធរថៃនៅតែបន្តបិទច្រកទ្វារព្រំដែនមិនទាន់បើកឱ្យអ្នកដំណើរចេញ-ចូលឆ្លងកាត់នៅឡើយ ចំពោះអ្នកជំងឺសង្គ្រោះបន្ទាន់ និងរថយន្តដឹកទំនិញធន់ធំដំណើរការជាធម្មតា៕

## ពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ២២១នាក់

https://www.facebook.com/GDIOfficial 22-11-2020

នៅថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០២០ វេលាម៉ោង ១៥និង០០នាទី ភាគីថៃនៅតែបន្តបិទច្រកទ្វារព្រំដែនអន្តរជាតិ ឆង ចម ខេត្តសុរិន្ទ ទល់មុខច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ ជាបណ្តោះអាសន្ន មិនអនុញ្ញាតឲ្យអ្នកដំណើរ គ្រប់សញ្ជាតិចេញ-ចូល ឆ្លងកាត់ ដើម្បីបង្ការនិងទប់ស្កាត់ការរាតត្បាតនៃជំងឺឆ្លងកូវីដ-១៩។ ក្នុងការបិទច្រកនេះ ភាគីថៃបានលើកលែង ទំនិញដែលទទួលបានការអនុញ្ញាត និងអ្នកបើកបររថយន្តដឹកទំនិញដែលទទួលបានការអនុញ្ញាត ព្រមទាំងបានការឆ្លងកាត់ត្រួតពិនិត្យ ដោយសមត្ថកិច្ចទាំងភាគី កម្ពុជា-ថៃ បានត្រឹមត្រូវ និងពលរដ្ឋខ្មែរ ឬពលរដ្ឋថៃ ដែលត្រូវវិលត្រឡប់ចូលប្រទេសរៀងៗខ្លួន។ ចំណែកឯពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ២២១នាក់ ស្រី ១០៧នាក់៕

## ពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ២០៥នាក់

https://www.facebook.com/GDIOfficial 21-11-2020

នៅថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០២០ វេលាម៉ោង ១៥និង០០នាទី ភាគីថៃនៅតែបន្តបិទច្រកទ្វារព្រំដែនអន្តរជាតិ ឆង ចម ខេត្តសុរិន្ទ ទល់មុខច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ ជាបណ្តោះអាសន្ន មិនអនុញ្ញាតឲ្យអ្នកដំណើរ គ្រប់សញ្ជាតិចេញ-ចូល ឆ្លងកាត់ ដើម្បីបង្ការនិងទប់ស្កាត់ការរាតត្បាតនៃជំងឺឆ្លងកូវីដ-១៩។ ក្នុងការបិទច្រកនេះ ភាគីថៃបានលើកលែង ទំនិញដែលទទួលបានការអនុញ្ញាត និងអ្នកបើកបររថយន្តដឹកទំនិញដែលទទួលបានការអនុញ្ញាត ព្រមទាំងបានការឆ្លងកាត់ត្រួតពិនិត្យ ដោយសមត្ថកិច្ចទាំងភាគី កម្ពុជា-ថៃ បានត្រឹមត្រូវ និងពលរដ្ឋខ្មែរ ឬពលរដ្ឋថៃ ដែលត្រូវវិលត្រឡប់ចូលប្រទេសរៀងៗខ្លួន។ចំណែកឯពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ២០៥នាក់ ស្រី ១០២នាក់៕

## ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិប៉ោយប៉ែត បានទទួលពលករខ្មែរ ឆ្លងដែនខុសច្បាប់ ដែលអាជ្ញាធរថៃបញ្ជូនមក មានចំនួន ១៣នាក់

https://www.facebook.com/GDIOfficial 20-11-2020

ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិប៉ោយប៉ែត នាថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០២០ វេលាម៉ោង ១៨និង០៥នាទីបានទទួលពលករខ្មែរ ឆ្លងដែនខុសច្បាប់ ដែលអាជ្ញាធរថៃបញ្ជូនមក មានចំនួន ១៣នាក់ ស្រី ០៤នាក់ និងកុមារ ០២នាក់។_ចំពោះពលករខាងលើ ត្រូវបានកម្លាំងនគរបាលប៉ុស្តិ៍ ធ្វើការអប់រំណែនាំ បន្ទាប់មកប្រគល់ជូនក្រុមការងារ ទទួលពលករមជ្ឈមណ្ឌលសំចតប៉ោយប៉ែត ដើម្បីធ្វើការបន្ត។_ជាមួយគ្នានេះដែរ អាជ្ញាធរថៃនៅតែបន្តបិទច្រកទ្វារព្រំដែន មិនទាន់បើកឱ្យអ្នកដំណើរចេញ-ចូលឆ្លងកាត់នៅឡើយ ចំពោះអ្នកជំងឺសង្គ្រោះបន្ទាន់ និងរថយន្តដឹកទំនិញធន់ធំ ដំណើរការជាធម្មតា៕

## ពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ១៥២នាក់

https://www.facebook.com/GDIOfficial 20-11-2020

នៅថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២០ វេលាម៉ោង ១៥និង០០នាទី ភាគីថៃនៅតែបន្តបិទច្រកទ្វារព្រំដែនអន្តរជាតិ ឆង ចម ខេត្តសុរិន្ទ ទល់មុខច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ ជាបណ្តោះអាសន្ន មិនអនុញ្ញាតឲ្យអ្នកដំណើរ គ្រប់សញ្ជាតិចេញ-ចូល ឆ្លងកាត់ ដើម្បីបង្ការនិងទប់ស្កាត់ការរាតត្បាតនៃជំងឺឆ្លងកូវីដ-១៩។ ក្នុងការបិទច្រកនេះ ភាគីថៃបានលើកលែង ទំនិញដែលទទួលបានការអនុញ្ញាត និងអ្នកបើកបររថយន្តដឹកទំនិញដែលទទួលបានការអនុញ្ញាត ព្រមទាំងបានការឆ្លងកាត់ត្រួតពិនិត្យ ដោយសមត្ថកិច្ចទាំងភាគី កម្ពុជា-ថៃ បានត្រឹមត្រូវ និងពលរដ្ឋខ្មែរ ឬពលរដ្ឋថៃ ដែលត្រូវវិលត្រឡប់ចូលប្រទេសរៀងៗខ្លួន។ចំណែកឯពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ១៥២នាក់ ស្រី ៦៤នាក់ និងពលរដ្ឋថៃដែលបានចាកចេញមានចំនួន ០១នាក់៕

# ថ្ងៃទី២៤ ខែ វិច្ឆិកា ឆ្នាំ២០២០

## ផែនការផ្សព្វផ្សាយសំរាប់ឆ្នាំ២០២១ ក្នុងការទប់ស្កាត់ ការជួញដូរផ្លូវភេទតាមអាជីវកម្មកំសាន្តនានានិងតាមវិស័យទេសចរ

https://www.pdikampongcham.info/ ២០ ខែវិច្ឆិកា ២០២០ **អត្ថបទដោយ៖ លោកស្រី ពុធ ធារី**

សំរាប់ខេត្តកំពង់ចាម គិតពីដើម២០២០ដល់ពេលនេះការជួញដូរផ្លូវភេទតាមអាជីវកម្មកំសាន្តនានានិងតាមវិស័យទេសចរ.មិនមានទេ បើប្រៀបធៀបទៅបណ្តាឆ្នាំកន្លងទៅ; នេះគឺយោងតាមរបាយការណ៍របស់( ការិយាល័យប្រឆាំងការជួញដូរមនុស្សនិងការពារនិតិជន )នៃស្នងការដ្ឋាននគរបាលខេត្ត។

លោកវរៈសេនីយទោ ចុល ម៉េង នាយរងការិយាល័យ ប្រឆាំងការជួញដូរមនុស្ស និងការពារនិតិជន បានលើកឡើងក្នុងកម្មវិធីសន្ទនានាមតិរបស់វិទ្យុជាតិភ្នំប្រុសភ្នំស្រី កាលពីថ្ងៃសុក្រទី១៣ តុលា ២០២០នេះថា-បច្ចុប្បន្នអំពើជួញដូរមនុស្សតាមគ្រប់រូបភាព និងតាមមធ្យោបាយរបស់ជនប្រព្រឹត្តបទល្មើស គឺត្រូវបានកំលាំងសមត្ថកិច្ចតែងតែបង្ក្រាបបាន និងចាប់ជនល្មើសយកមកផ្តន្ទាទោសតាមច្បាប់។ លោកបញ្ជាក់ទៀតថា មិនដូចកាលពីអំឡុងឆ្នាំ១៩៩០ដល់១៩៩៦ សមត្ថកិច្ចអនុវត្តតាមច្បាប់ព្រហ្មទណ្ឌអន្តរកាលគឺមានតែ១០ ក្នុងនោះគឺមិនមានចែងពីបទល្មើសសច្ចារកម្ម( គឺការទាញយកផលប្រយោជន៍ពីបុគ្គល )ដូច្នេះហើយទើបសមត្ថកិច្ចមានការលំបាកក្នុងការអនុវត្តការចាត់វិធានការ។ លោកបន្តថា តែបច្ចុប្បន្ននេះ ដោយមានវិសោធនកម្មច្បាប់ថ្មីមាន៥២មាត្រាគឺពេញលេញក្នុងការចាត់វិធានការក្នុងការបង្ក្រាប ការនាំមនុស្សចេញដោយរាប់ទាំងជើងតាមនាវា តាមផ្លូវអាកាសនិងការជួញដូរតាមខ្លឹបកំសាន្តនានានិងតាមវិស័យទេសចរទៀតផង។

ចុងក្រោយលោកបានសំណូមពរដល់ប្រជាពលរដ្ឋទាំងអស់ បើសិនជាចង់អោយសមត្ថកិច្ចអនុវត្តចំណាត់ការមានប្រសិទ្ធភាពក្នុងការចាប់ជនល្មើស ត្រូវតែមានការចូលរួមជាមួយអាជ្ញាធរនិងសមត្ថកិច្ច រាល់ការប្រជុំនៅក្នុងភូមិសហគមន៍ស្តាប់ការនែនាំរបស់អាជ្ញាធរសមត្ថកិច្ចប៉ុស្តិ៍មូលដ្ឋាន នោះទើបការចំណាត់ការអនុវត្តផ្លូវច្បាប់មានប្រសិទ្ធភាព;ហើយស្នងការដ្ឋាននគរបាលខេត្ត នៅតែអនុវត្តជាប់ជានិច្ចក្នុងគោលនយោបាយ ភូមិឃុំមានសុវត្ថភាពដើម្បីផ្តល់សុខសន្តិភាពជូនពលរដ្ឋ៕

## លោកស្រី សុំ ចិន្តា អញ្ជើញជាអធិបតីភាពក្នុងពិធីបើកបទបង្ហាញស្តីពីគម្រោង ការស្តារជីវភាពសម្រាប់ពលករ និងគ្រួសារ នៅសាលាស្រុកសង្កែ

https://www.battambang.gov.kh/ ថ្ងៃសុក្រ, 20 ខែវិច្ឆិកា, 2020 ដោយ Sotheavy

នៅព្រឹកថ្ងៃសុក្រ ៥កើត ខែមិគសិរ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤ ត្រូវនឹងថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២០ លោកស្រី សុំ ចិន្តា អភិបាលរង នៃគណៈអភិបាលខេត្ត និងជាអនុប្រធានអចិន្ត្រៃយ៍គណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស តំណាង ឯកឧត្តម ងួន រតនៈ អភិបាល នៃគណៈអភិបាលខេត្ត និងជាប្រធានគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានអញ្ជើញជាអធិបតីភាពក្នុងពិធីបើកបទបង្ហាញ ស្តីពីស្តីពីគម្រោង ការស្តារជីវភាពសម្រាប់ពលករ និងគ្រួសារ នៅសាលាស្រុកសង្កែ ដែលមានការអញ្ជើញចូលរួមពីលោកស្រីអភិបាលរងស្រុក នាយករដ្ឋបាលស្តីទីស្រុក លោកមេឃុំ មេភូមិ និងអ្នកពាក់ព័ន្ធមួយចំនួនទៀត។

លោកស្រី កែវ ដាណា នាយករងរដ្ឋបាលខេត្ត និងជាប្រធាន បានជម្រាបដល់អាជ្ញាធរមូលដ្ឋានពាក់ព័ន្ធអំពីគោលបំណងរបស់គម្រោង **ស្តារជីវភាពសម្រាប់ពលករ និងគ្រួសារ** ដែលធ្វើការគាំទ្រដល់ជីវភាពប្រចាំថ្ងៃរបស់ពលករ និងក្រុមគ្រួសាររបស់ពួកគេឱ្យមានភាពប្រសើរឡើង**តាមរយៈកសិកម្ម តាមរយៈមុខរបរខ្នាតតូច** ព្រមទាំងការ

ផ្សព្វផ្សាយដល់អ្នកទទួលផ្ទាល់ និងប្រជាពលរដ្ឋក្នុងឃុំឱ្យយល់ដឹងអំពីបញ្ហា ១៩ ការផ្តល់សេវាសុខភាព និងសេវាផ្សេងៗទៀតផងដែរ ។

សូមជម្រាបជូនថា គម្រោងស្តារជីវភាពសម្រាប់ពលករ និងគ្រួសារ មានការគាំទ្រពីអង្គការ IOM ហើយត្រូវអនុវត្តដោយលេខាធិការគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សខេត្ត ដែលអនុវត្តក្នុងឃុំគោលដៅចំនួន ២ គឺឃុំវត្តតាមិម និងឃុំអន្លង់វិល លើភូមិចំនួន ១២ ភូមិផងដែរ៕

## លោកជំទាវ ប៉ាង ដានី បើកវគ្គបណ្តុះបណ្តាល ដល់មន្ត្រីជាយន្តការគណៈកម្មាធិការប្រយុទ្ធ ប្រឆាំងការជួញដូរមនុស្ស នៅថ្នាក់ ស្រុក ឃុំ/សង្កាត់

https://www.pdikampongcham.info/ ២៣ ខែវិច្ឆិកា ២០២០

អភិបាលរងខេត្តកំពង់ចាម លោកជំទាវ ប៉ាង ដានី នៅថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០២០នេះ បានអញ្ជើញបើកវគ្គបណ្តុះបណ្តាល ដល់មន្ត្រីជាយន្តការគណៈកម្មាធិការប្រយុទ្ធ ប្រឆាំងការជួញដូរមនុស្ស នៅថ្នាក់ ស្រុក ឃុំ/សង្កាត់ ដែលរៀបចំដោយ លេខាធិការដ្ឋានគណៈកម្មាធិការខេត្ត ប្រឆាំងអំពើជួញដូរមនុស្ស នៅសាលប្រជុំធំសាលាខេត្តកំពង់ចាម។

វគ្គបណ្តុះបណ្តាលនេះ បានបង្ហាញដល់អ្នកចូលរួមទាំងអស់អំពីសភាពការណ៍រួម កម្រិតទោសទណ្ឌ អង្គលេខរបស់គណៈកម្មាធិការជួញដូរមនុស្ស បទពិសោធន៍ បញ្ហាប្រឈម និងផែនការទប់ស្កាត់ ឆ្នាំ២០២១ របស់ក្រុមការងារបង្ការ និងទប់ស្កាត់ការជួញដូរ មនុស្សខេត្តដោយលោក កុក ស៊ីជឿន អនុប្រធានមន្ទីរអប់រំ យុវជន និងកីឡា និងបទបង្ហាញអំពី និយមន័យ អំពើជួញដូរមនុស្ស និងដំណើរការ នៃការអនុវត្ត របស់ក្រុមការងារការពារជនរងគ្រោះដោយលោក ហួត សុជា អនុប្រធានមន្ទីរសង្គមកិច្ច អតីត យុទ្ធជន និងយុវនីតិសម្បទាខេត្ត។

សូមជម្រាបជូនថា បណ្តុះបណ្តាលនេះ គឺជាវគ្គទី ២ហើយ ដែលគ្រោងនឹងបញ្ចប់នៅត្រីមាសទី ៣ ឆ្នាំ ២០២០ ប៉ុន្តែអាស្រ័យដោយយើងជួបប្រទះនូវវិបត្តិជំងឺកូវីដ-១៩ ទើបការបញ្ចប់វគ្គត្រូវបានលើកមកត្រីមាសទី៤ ក្នុងឆ្នាំ ២០២០ វិញ ហើយការរៀបចំវគ្គនេះលេខាធិការដ្ឋាន បានអនុវត្តតាមគោលការណ៍ណែនាំរបស់ក្រសួងសុខាភិបាលដោយតម្រូវឲ្យសិក្ខាកាមរក្សានូវគម្លាតសុវត្ថិភាព និងពាក់ម៉ាស់គ្រប់ៗគ្នា។

## ជនជាតិចិនចំនួន ០២នាក់ ពាក់ព័ន្ធនឹងបទល្មើស បម្រើសេវាផ្លូវភេទ ត្រូវបណ្តេញចេញកម្ពុជា

https://www.cen.com.kh/ November 21, 2020

ខេត្តព្រះសីហនុ ៖ ប៉ុស្តិ៍នគរបាលច្រកទ្វារអាកាសយានដ្ឋានអន្តរជាតិ ខេត្តព្រះសីហនុ បានបណ្តេញជនជាតិចិនចំនួន ០២នាក់ ឲ្យចេញផុតពីកម្ពុជា តាមជើងយន្តហោះចេញលេខ LQ908 (KOS-CAN) ពាក់ព័ន្ធនឹងបទល្មើសបម្រើសេវាផ្លូវភេទ។ ប៉ុស្តិ៍នគរបាលច្រកទ្វារអាកាសយានដ្ឋានអន្តរជាតិ ខេត្តព្រះសីហនុ នាថ្ងៃទី២០ ខែ វិច្ឆិកា ឆ្នាំ២០២០ វេលាម៉ោង ១៩និង០០ នាទី បានសហការជាមួយ លោកវរសេនីយ៍ទោ ប៉ុន សំអុលឧត្តម នាយរងការិយាល័យ ស្នាក់ការត្រៀមបណ្តេញចេញខេត្តព្រះសីហនុ នៃនាយកដ្ឋានស៊ើបអង្កេត និងអនុវត្តនីតិវិធី ធ្វើការបណ្តេញចេញ ជនជាតិចិនចំនួន ០២នាក់ តាមជើងយន្តហោះចេញលេខ LQ908 (KOS-CAN) ឲ្យចេញផុតពីប្រទេស និងប្រថាប់ត្រាហាមចូលព្រះរាជាណាចក្រកម្ពុជា រយៈពេល ០៣ឆ្នាំ។ នគរបាលប៉ុស្តិ៍បានឲ្យដឹងថា ជនជាតិចិនទាំង ០២នាក់នេះ មាន ១. ឈ្មោះ SHI LIBAO ភេទស្រី អាយុ ៤០ឆ្នាំ និង២. ឈ្មោះ XU YING ភេទស្រី អាយុ ៣៤ឆ្នាំ ដែលស្នាក់ការត្រៀមបណ្តេញចេញខេត្តព្រះសីហនុ ទទួលពីស្នងការដ្ឋាននគរបាលខេត្តព្រះសីហនុ កាលពីថ្ងៃទី០៤ ខែតុលា ឆ្នាំ២០២០ ពាក់ព័ន្ធនឹងបទល្មើស បម្រើសេវាផ្លូវភេទ៕

## ពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ១៣៣នាក់

https://www.facebook.com/GDIOfficial 23-11-2020

នៅថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០២០ វេលាម៉ោង ១៥និង០០នាទី ភាគីថៃនៅតែបន្តបិទច្រកទ្វារព្រំដែនអន្តរជាតិ ផង ចម ខេត្តសុរិន្ទ ទល់មុខច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ ជាបណ្តោះអាសន្ន មិនអនុញ្ញាតឲ្យអ្នកដំណើរ គ្រប់សញ្ជាតិចេញ-ចូល ឆ្លងកាត់ ដើម្បីបង្ការនិងទប់ស្កាត់ការរាតត្បាតនៃជំងឺឆ្លងកូវីដ-១៩។ ក្នុងការបិទច្រកនេះ ភាគីថៃបានលើកលែង ទំនិញដែលទទួលបានការអនុញ្ញាត និងអ្នកបើកបររថយន្តដឹកទំនិញដែលទទួលបានការអនុញ្ញាត ព្រមទាំងបានការឆ្លងកាត់ត្រួតពិនិត្យ ដោយសមត្ថកិច្ចទាំងភាគី កម្ពុជា-ថៃ បានត្រឹមត្រូវ និងពលរដ្ឋខ្មែរ ឬពលរដ្ឋថៃ ដែលត្រូវវិលត្រឡប់ចូលប្រទេសរៀងៗខ្លួន។ ចំណែកឯពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ១៣៣នាក់ ស្រី ៦១នាក់៕

# ថ្ងៃទី២៥ ខែ វិច្ឆិកា ឆ្នាំ២០២០

## ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិចាំយាម បានទទួលពលករខ្មែរចំនួន ០៣នាក់ ពីសមត្ថកិច្ចថៃ ពាក់ព័ន្ធនឹងករណីឆ្លងដែនខុសច្បាប់

https://www.facebook.com/GDIOfficial 24-11-2020

នៅថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០២០ វេលាម៉ោង ១៦និង១០នាទី ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិចាំយាម បានទទួលពលករខ្មែរចំនួន ០៣នាក់ ពីសមត្ថកិច្ចថៃ ពាក់ព័ន្ធនឹងករណីឆ្លងដែនខុសច្បាប់។ នគរបាលប៉ុស្តិ៍បានឲ្យដឹងថា ពលករខ្មែរទាំង ០៣នាក់នេះ មាន ១-ឈ្មោះ ជន វឌ្ឍា ភេទប្រុស (ភេទទី៣) អាយុ ២១ឆ្នាំ នៅភូមិកំព្រៅ ឃុំញ៉ៅទី១ ស្រុកសុ៊ីធកណ្តាល ខេត្តព្រៃវែង, ២-ឈ្មោះ នាក់ សុភី ភេទស្រី អាយុ ៤២ឆ្នាំ នៅភូមិទំព័រ ឃុំស្រឡៅ ស្រុកតាំងគោក ខេត្តកំពង់ធំ, ៣-ឈ្មោះ ព្រាប ប៊ីត ភេទប្រុស អាយុ ៤៣ឆ្នាំនៅភូមិព្រែកឬស្សី ឃុំព្រែកឬស្សី ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល និងបានធ្វើការសាកសួរ អប់រំណែនាំ ដោយមានការចូលរួមត្រួតពិនិត្យសុខភាព ពីមន្ត្រីចត្តាឡីស័កប្រចាំមាត់ច្រក នូវវិធានការរបស់ក្រសួងសុខាភិបាលផងដែរ។ ដោយឡែកខាងភាគីថៃ នៅតែបន្តបិទច្រកមិនឲ្យអ្នកដំណើរ ចេញ-ចូល ចំណែកទំនិញទទួលបានការអនុញ្ញាត និងអ្នកបើកបររថយន្តចំនួន ០២នាក់ ដែលទទួលបានការអនុញ្ញាត និងបានការឆ្លងកាត់ត្រួតពិនិត្យ ដោយសមត្ថកិច្ចទាំងភាគី កម្ពុជា-ថៃ បានយ៉ាងត្រឹមត្រូវ៕

## ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិប៉ោយប៉ែត បានទទួលពលករខ្មែរ ឆ្លងដែនខុសច្បាប់ ដែលអាជ្ញាធរថៃបញ្ជូនមក មានចំនួន ០៤នាក់

https://www.facebook.com/GDIOfficial 24-11-2020

ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិប៉ោយប៉ែត នាថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០២០ វេលាម៉ោង ១៧និង០០នាទីបានទទួលពលករខ្មែរ ឆ្លងដែនខុសច្បាប់ ដែលអាជ្ញាធរថៃបញ្ជូនមក មានចំនួន ០៤នាក់។ ចំពោះពលករខាងលើ ត្រូវបានកម្លាំងនគរបាលប៉ុស្តិ៍ ធ្វើការអប់រំណែនាំ បន្ទាប់មកប្រគល់ជូនក្រុមការងារ ទទួលពលករមជ្ឈមណ្ឌលសំចតប៉ោយប៉ែត ដើម្បីធ្វើការបន្ត។ ជាមួយគ្នានេះដែរ អាជ្ញាធរថៃនៅតែបន្តបិទច្រកទ្វារព្រំដែន មិន

ទាន់បើកឱ្យអ្នកដំណើរចេញ-ចូលឆ្លងកាត់នៅឡើយ ចំពោះអ្នកជំងឺសង្គ្រោះបន្ទាន់ និងរថយន្តដឹកទំនិញធន់ធំដំណើរការជាធម្មតា៕

## ពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ១៤៤នាក់

https://www.facebook.com/GDIOfficial 24-11-2020

នៅថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០២០ វេលាម៉ោង ១៥និង០០នាទី ភាគីថៃនៅតែបន្តបិទច្រកទ្វារព្រំដែនអន្តរជាតិ ឆង ចម ខេត្តសុរិន្ទ ទល់មុខច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ ជាបណ្ដោះអាសន្ន មិនអនុញ្ញាតឲ្យអ្នកដំណើរ គ្រប់សញ្ជាតិចេញ-ចូល ឆ្លងកាត់ដើម្បីបង្ការនិងទប់ស្កាត់ការរាតត្បាតនៃជំងឺឆ្លង កូវីដ-១៩។ ក្នុងការបិទច្រកនេះ ភាគីថៃបានលើកលែង ទំនិញដែលទទួលបានការអនុញ្ញាត និងអ្នកបើកបររថយន្តដឹកទំនិញដែលទទួលបានការអនុញ្ញាត ព្រមទាំងបានការឆ្លងកាត់ត្រួតពិនិត្យ ដោយសមត្ថកិច្ចទាំងភាគី កម្ពុជា-ថៃ បានត្រឹមត្រូវ និងពលរដ្ឋខ្មែរ ឬពលរដ្ឋថៃ ដែលត្រូវវិលត្រឡប់ចូលប្រទេសរៀងៗខ្លួន។ ចំណែកឯពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ១៤៤នាក់ ស្រី ៨២នាក់៕

# ថ្ងៃទី២៧ ខែ វិច្ឆិកា ឆ្នាំ២០២០

## អាជ្ញាធរខណ្ឌដូនពេញ បិទទីតាំងហាងម៉ាស្សា DIAMOND MASSAGE

## សង្ស័យពាក់ព័ន្ធនឹងអំពើសញ្ញារកម្ម និងនាំខ្លួនបុរសម្នាក់ទៅ អធិការដ្ឋាននគរបាលខណ្ឌដូនពេញ ដើម្បីធ្វើការសាកសួរ

https://www.cen.com.kh/archives/ November 26, 2020

ភ្នំពេញ៖ អធិការដ្ឋាននគរបាលខណ្ឌដូនពេញបានចេញរបាយការណ៍លំអិត ស្ដីពីករណីចុះបង្ក្រាបទីតាំងហាងម៉ាស្សាដែលមានឈ្មោះ DIAMOND MASSAGE ដែលបានបង្ហោះក្នុងបណ្ដាញសង្គម ដែលបានធ្វើឲ្យប៉ះពាល់ដល់វប្បធម៌ ប្រពៃណីខ្មែរ នឹងខុសច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ដែលមានទីតាំងផ្ទះលេខ ៤៨C ផ្លូវ២២២ ភូមិ៤ ក្រុម១៦ សង្កាត់បឹងរាំង ខណ្ឌដូនពេញ រាជធានីភ្នំពេញ។

នៅថ្ងៃទី២៦ ខែ វិច្ឆិកា ឆ្នាំ២០២០ វេលាម៉ោង ១៤និង៣០នាទី កម្លាំងចម្រុះនៃគណៈបញ្ជាការឯកភាពខណ្ឌដូនពេញ ដែលដឹកនាំដោយលោក សេង ហៀង ជាព្រះរាជអាជ្ញានៃអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ និងមានសមាសភាពចូលរួមដូចខាងក្រោម÷ 1-លោក ម៉ម វាសនា ប្រធានមន្ទីរទេសចរណ៍រាជធានីភ្នំពេញ 2-លោក សុខ ពេញវុធ អភិបាលនៃគណៈអភិបាលខណ្ឌដូនពេញ 3-លោក ចាន់ កន្តេត អភិបាលរងខណ្ឌដូនពេញ 4-លោក វរសេនីយ៍ឯក ទៀង ច័ន្ទសារ អធិការនគរបាលខណ្ឌដូនពេញ 5- លោក វរសេនីយ៍ទោ អ៊ឹម ផល្លុន អធិការរងនគរបាលខណ្ឌដូនពេញ 6-លោក ហឿន ប្រសើរ ប្រធានការិយាល័យសេដ្ឋកិច្ច 7-លោក កាន់ វរៈ ក្រឡាបញ្ជីនៃអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ជា 8-លោក មាស បូរិន ចៅរងទី1 សាលាសង្កាត់បឹងរាំង 9-លោក វរសេនីយ៍ត្រី ប៊ុន ប្រុស នាយប៉ុស្តិ៍នគរបាលរដ្ឋបាលបឹងរាំង។ 10-លោក ភោគ សោភ័ណ្ឌ មេភូមិ4 សង្កាត់បឹងរាំង ។

ពេលចុះមកដល់ទីតាំងខាងលើនេះក្រុមការងារបានពិនិត្យឃើញជាក់ស្ដែងដូចខាងក្រោម: ទីតាំងបានបិទទ្វារ និងមានឈ្មោះ សេង ហុកសុខរស្មី ភេទប្រុស អាយុ២៦ឆ្នាំ ជនជាតិខ្មែរ ជាអ្នកមើលការខុសត្រូវទីតាំងខាងលើពេលនោះ ឈ្មោះ សេង ហុកសុខរស្មី បានសហការជាមួយកម្លាំងចំរុះ ឲ្យចូលពិនិត្យក្នុងទីតាំងខាងលើ រកឃើញវត្ថុតាងមួយចំនួន រួមមាន÷ 1- ស្រោមអនាម័យម៉ាក Strast និង ទឹករំអិល K Y Jelly មួយចំនួន 2- កុំព្យូទ័រ

Desktop ម៉ាកDell ពណ៌ខ្មៅ 01គ្រឿង រួមជាមួយម៉ាស៊ីន Printer 3- DVR ម៉ាក Hikvision ពណ៌ខ្មៅ 01គ្រឿង 4-Tablet ម៉ាក Samsung 01គ្រឿង 5-ទូរស័ព្ទដៃ ម៉ាក Oppo ពណ៌ខ្មៅ 01គ្រឿង និង កាបូបដៃ ពណ៌ខ្មៅចំនួន ( របស់ឈ្មោះ សេង ហុកសុខរស្មី) 6- បញ្ជីចំណូល ចំនួន 03ក្បាល និង ឯកសារមួយចំនួន 7-រូបថតសរសេរថា " វិញ្ញាបនបត្រលេខ(No)MOC-49851984 ពណ.ចបព ចុះថ្ងៃទី18 ខែមីនា ឆ្នាំ2020។

ដោយពិនិត្យឃើញថា អាជីវកម្មខាងលើល្មើសនិងវិធានការសុវត្ថិភាពរបស់ក្រសួងសុខាភិបាល តាមរយៈលិខិតលេខ 167សជណ.អរហ ចុះថ្ងៃទី 07 ខែមេសា ឆ្នាំ2020របស់ក្រសួងទេសចរណ៍ និងដោយពិនិត្យឃើញជាក់ស្តែងនូវវត្ថុតាងខាងលើ(ពិសេសស្រោមអនាម័យនិងទឹករំអិល)មានតម្រុវសង្ស័យពាក់ព័ន្ធនឹងអំពើសញ្ចារកម្ម ហេតុនេះក្រុមការងារចម្រុះសម្រេចចាប់យកវត្ថុតាងខាងលើ និងបិទទីតាំងអាជីវកម្មនេះជាបណ្តោះអាសន្ន។ ក្រៅពីវត្ថុចាប់យកខាងលើ ក្រុមការងារចម្រុះពុំបានដកហូត ឬធ្វើឲ្យខូចខាតសម្ភារណាមួយនៅក្នុងទីតាំងខាងលើឡើយ និងបាននាំឈ្មោះ សេង ហុងសុខរស្មី ភេទប្រុស អាយុ២៦ឆ្នាំ ទៅកាន់អធិការដ្ឋាននគរបាលខណ្ឌដូនពេញ ដើម្បីធ្វើការសាកសួរ បន្ត ៕ **ដោយៈបញ្ញាស័ក្តិ**

## កូរ៉េនៅតែទទួលពលករកម្ពុជា ខណៈបច្ចុប្បន្នពលករកម្ពុជាជិត ៥ ម៉ឺន នាក់កំពុងធ្វើការនៅទីនោះ

https://www.cen.com.kh/archives/ November 26, 2020

ភ្នំពេញ៖ ទោះបីស្ថិតក្នុងដំណាក់កាលពិបាកដោយសារជំងឺកូវីដ-១៩ សាធារណរដ្ឋកូរ៉េនៅតែព្រមទទួលយកពលករកម្ពុជាឱ្យធ្វើការនៅប្រទេសខ្លួន ដោយសារនិយោជកពេញចិត្តនឹងសមត្ថភាព ភាពស្មោះត្រង់របស់ពលករកម្ពុជា ខណៈពេលបច្ចុប្បន្នពលករកម្ពុជាប្រមាណជិត ៥០,០០០ នាក់កំពុងបម្រើការងារលើវិស័យនានានៅប្រទេសនេះ។ ការលើកឡើងនេះ ធ្វើឡើងក្នុងជំនួបពិភាក្សាការងាររវាងឯកឧត្តមបណ្ឌិត អ៊ិត សំហេង រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ជាមួយឯកឧត្តម Park Heung Kyeong ឯកអគ្គរដ្ឋទូតសាធារណរដ្ឋកូរ៉េប្រចាំកម្ពុជា នាព្រឹកថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០២០ នៅទីស្តីការក្រសួងការងារ។

ឯកឧត្តមរដ្ឋមន្ត្រី អ៊ិត សំហេង បានលើកឡើងពីវឌ្ឍនភាពលើវិស័យការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈនៅកម្ពុជា ដែលកើតចេញពីទំនាក់ទំនងកិច្ចសហប្រតិបត្តិការល្អរវាងកម្ពុជា និងកូរ៉េខាងត្បូង តាំងពីភ្ជាប់ទំនាក់ទំនងការទូតជាមួយគ្នានៅឆ្នាំ១៩៩៧មក។ ឯកឧត្តមរដ្ឋមន្ត្រីបានបញ្ជាក់បន្ថែមអំពីកិច្ចសហប្រតិបត្តិការនាពេលកន្លងមករវាងកម្ពុជា និងសាធារណរដ្ឋកូរ៉េ ក្នុងនោះបានជំរុញទំហំពាណិជ្ជកម្មកម្ពុជា-កូរ៉េក្នុងឆ្នាំ២០១៩ ឱ្យឈានដល់ជាង ១,៥០០ លានដុល្លារអាមេរិក។ ទុនវិនិយោគមកពីប្រទេសកូរ៉េនៅកម្ពុជាមានតម្លៃជាង ៥ ពាន់លានដុល្លារអាមេរិកគិតមកដល់ពេលបច្ចុប្បន្ននេះ និងបានធ្វើឲ្យកូរ៉េក្លាយជាប្រទេសទី២ ក្នុងការវិនិយោគនៅកម្ពុជា។ ឯកឧត្តមបានបន្តថា កម្ពុជា និងកូរ៉េកំពុងចរចាកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី ដើម្បីឈានទៅចុះហត្ថលេខាដាក់ឱ្យដំណើរការជាធរមាន នាពេលឆាប់ៗនេះ។

កិច្ចព្រមព្រៀងនេះនឹងជំរុញឲ្យទំហំពាណិជ្ជកម្ម និងការវិនិយោគកាន់តែមានការកើនឡើង ហើយវិនិយោគិនកូរ៉េ ក៏នឹងមកកម្ពុជាបន្ថែម ដើម្បីស្វែងរកឱកាសវិនិយោគក្នុងវិស័យជាច្រើនទៀត។ ឯកឧត្តមរដ្ឋមន្ត្រី បានបញ្ជាក់ទៅឯកឧត្តមអគ្គរដ្ឋទូតថា សម្រាប់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្នុងនាមឯកឧត្តមរដ្ឋមន្ត្រីជាប្រធានក្រុមការងារទំនាក់ទំនងវិជ្ជាជីវៈ ឯកឧត្តមនឹងខិតខំពិនិត្យ ដោះស្រាយ គាំទ្រឲ្យកាន់តែប្រសើរថែមទៀតទៅលើកិច្ចសម្រួលពាណិជ្ជកម្មនានាពាក់ព័ន្ធទៅនឹងអ្នកវិនិយោទុនកូរ៉េ ដែលមានបំណងចូលមកធ្វើការវិនិយោគនៅកម្ពុជា។ នៅក្នុងជំនួបនេះដែរឯកឧត្តមរដ្ឋមន្ត្រី ក៏បានថ្លែងអំណរគុណដល់ភាគីកូរ៉េ ដែលកន្លងមកបានជួយដល់ ទីភ្នាក់ងារជាតិមុខរបរ និងការងារ(NEA) ដើម្បីឲ្យអង្គភាពមួយនេះមានប្រសិទ្ធភាពក្នុងការផ្តល់សេវាការងារ ជូនដល់

អ្នកស្វែងរកការងារធ្វើ ក៏ដូចជានិយោជកដែលមានតម្រូវការជ្រើសរើសកម្លាំងពលកម្ម។ ចំណែកផ្នែកបណ្តុះបណ្តាលបច្ចេកទេស វិជ្ជាជីវៈ តាមរយៈអង្គការ KOSHA បានជួយបណ្តុះបណ្តាលមន្ត្រីកម្ពុជា និងបានបង្កើតនូវវិទ្យាស្ថានបណ្តុះបណ្តាលពហុបច្ចេកទេសកម្ពុជា(NPIC) ដែលជាវិទ្យាស្ថានមួយ មានបច្ចេកទេសស្តង់ដាខ្ពស់ ព្រមទាំងមានការគាំទ្រពីសាធារណជន សិស្ស និស្សិតខ្លាំងផងដែរ។ ចំពោះបេឡាជាតិសន្តិសុខសង្គម ក៏ភាគីកូរ៉េជួយទៅលើបច្ចេកទេសជាច្រើន ដល់កម្ពុជា ដោយអនុវត្តបានជោគជ័យទៅលើរបបគ្រោះថ្នាក់ការងារ ដើម្បីការពារកម្មករនិយោជិតករណីជួបគ្រោះថ្នាក់អ្វីមួយ ក្នុងពេលបំពេញការងារខ្លួន រួមទាំងរបបថែទាំសុខភាពជាដើម។

កិច្ចសហប្រតិបត្តិការ របស់បេឡាជាតិសន្តិសុខសង្គមនៅតែបន្តរហូតមក។ ទន្ទឹមនេះដែរ ភាគីកូរ៉េកំពុងជួយកម្ពុជាក្នុងការរៀបចំសេចក្តីព្រាងស្តីពីសុវត្ថិភាព និងសុខភាពការងារ ដែលកម្ពុជា មិនទាន់មានច្បាប់នេះនៅឡើយ នាពេលអនាគតកម្ពុជា នឹងបង្កើតឲ្យមានក្របខណ្ឌច្បាប់នេះ ដើម្បីធានាបានប្រសើរថែមទាំង លើការការពារសុវត្ថិភាព និងសុខភាពការងារនៅកន្លែងធ្វើការ។ ជាមួយគ្នានេះ ភាគីកូរ៉េគ្រោងនឹងបង្កើតវិទ្យាស្ថានជាតិបណ្តុះបណ្តាលផ្នែកសុខភាព និងសុវត្ថិភាពការងារ ក្នុងពេលឆាប់ៗខាងមុខនេះ ដើម្បីបណ្តុះបណ្តាលដល់ភាគីពាក់ព័ន្ធឲ្យយល់ពីប្រព័ន្ធសុវត្ថិភាព និងសុខភាពនៅកន្លែងធ្វើការ។

ពាក់ព័ន្ធនឹងការបញ្ជូន-ទទួលពលករកម្ពុជាធ្វើការនៅប្រទេសកូរ៉េ ឯកឧត្តមបណ្ឌិតរដ្ឋមន្ត្រីបានលើកឡើងថា បន្ទាប់ពីស្ថានភាពកូវីដ-១៩ នៅប្រទេសកូរ៉េមានភាពធូរស្រាល ដែលអាចទទួលយកកម្លាំងពលកម្មបរទេសបាន កម្ពុជារំពឹងថានឹងក្លាយជាប្រទេសអាទិភាពមួយក្នុងចំណោមប្រទេសចំនួន ១៥ ផ្សេងទៀត ដោយសារកម្ពុជាមានស្ថានភាពកូវីដល្អប្រសើរ មានជើងហោះហើរច្រើន។ ឯកឧត្តមឯកអគ្គរដ្ឋទូតសាធារណរដ្ឋកូរ៉េបានលើកឡើងថា នៅក្នុងឆ្នាំ២០១៩ ពលករកម្ពុជាមានចំនួនច្រើនជាងគេក្នុងចំណោមពលករដែលធ្វើការនៅប្រទេសកូរ៉េ ហើយក្នុងដំណាក់កាលជំងឺកូវីដ-១៩ ឆ្នាំ២០២០នេះរដ្ឋាភិបាលសាធារណរដ្ឋកូរ៉េនៅតែអនុញ្ញាតទទួលពលករកម្ពុជាដដែល។ ឯកឧត្តមទូតបានបញ្ជាក់ថា «មូលហេតុដែលកូរ៉េអនុញ្ញាតទទួលពលករកម្ពុជាយ៉ាងដូច្នេះ គឺដោយសារនិយោជកមានការពេញចិត្តនឹងសមត្ថភាពខ្ពស់របស់ពលករកម្ពុជា មានភាពស្មោះត្រង់នឹងការងារ និងអនុវត្តតាមការណែនាំរបស់ផ្នែកសុខាភិបាលរបស់រដ្ឋាភិបាលកូរ៉េបានយ៉ាងហ្មត់ចត់»។

សូមជម្រាបថា ចាប់ពីឆ្នាំ២០០៧មក កម្ពុជាបានបញ្ជូនពលករសរុប ៦៨,២៩៤ នាក់ (ស្រី ១៤,២៥៥ នាក់) ឱ្យទៅធ្វើការនៅប្រទេសកូរ៉េ ដែលរួមមានវិស័យឧស្សាហកម្ម កសិកម្ម និងសំណង់ ដែលអាណត្តិការងារមានរយៈពេល ៤ ឆ្នាំ ១០ ខែខណៈពេលបច្ចុប្បន្ន ពលករកម្ពុជាដែលកំពុងធ្វើការនៅកូរ៉េមានចំនួនជិត ៥០,០០០ នាក់ ៕ដោយ៖CEN

## ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិប៉ោយប៉ែត បានទទួលពលករខ្មែរ ឆ្លងដែនខុសច្បាប់ ដែលអាជ្ញាធរថៃបញ្ជូនមក មានចំនួន ០៩នាក់

https://www.facebook.com/GDIOfficial 26-11-2020

ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិប៉ោយប៉ែត នាថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០២០ វេលាម៉ោង ១៧និង១៥នាទីបានទទួលពលករខ្មែរ ឆ្លងដែនខុសច្បាប់ ដែលអាជ្ញាធរថៃបញ្ជូនមក មានចំនួន ០៩នាក់ ស្រី០៣នាក់។ ចំពោះពលករខាងលើ ត្រូវបានកម្លាំងនគរបាលប៉ុស្តិ៍ ធ្វើការអប់រំណែនាំ បន្ទាប់មកប្រគល់ជូនក្រុមការងារ ទទួលពលករមជ្ឈមណ្ឌលសំចតប៉ោយប៉ែត ដើម្បីធ្វើការបន្ត។ ជាមួយគ្នានេះដែរ អាជ្ញាធរថៃនៅតែបន្តបិទច្រកទ្វារព្រំដែន មិនទាន់បើកឱ្យអ្នកដំណើរចេញ-ចូលឆ្លងកាត់នៅឡើយ ចំពោះអ្នកជំងឺសង្គ្រោះបន្ទាន់ និងរថយន្តដឹកទំនិញធន់ធំ ដំណើរការជាធម្មតា៕

## ពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ១៥២នាក់

https://www.facebook.com/GDIOfficial 26-11-2020

នៅថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០២០ វេលាម៉ោង ១៥និង០០នាទី ភាគីថៃនៅតែបន្តបិទច្រកទ្វារព្រំដែនអន្តរជាតិ ឆង ចម ខេត្តសុរិន្ទ ទល់មុខច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ ជាបណ្ដោះអាសន្ន មិនអនុញ្ញាតឲ្យអ្នកដំណើរ គ្រប់សញ្ជាតិចេញ-ចូល ឆ្លងកាត់ ដើម្បីបង្ការនិងទប់ស្កាត់ការរាតត្បាតនៃជំងឺឆ្លងកូវីដ-១៩។ ក្នុងការបិទច្រកនេះ ភាគីថៃបានលើកលែង ទំនិញដែលទទួលបានការអនុញ្ញាត និងអ្នកបើកបររថយន្តដឹកទំនិញដែលទទួលបានការអនុញ្ញាត ព្រមទាំងបានការឆ្លងកាត់ត្រួតពិនិត្យ ដោយសមត្ថកិច្ចទាំងភាគី កម្ពុជា-ថៃ បានត្រឹមត្រូវ និងពលរដ្ឋខ្មែរ ឬពលរដ្ឋថៃ ដែលត្រូវវិលត្រឡប់ចូលប្រទេសរៀងៗខ្លួន។ចំណែកឯពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ១៥២នាក់ ស្រី ៩៧នាក់៕

## កិច្ចប្រជុំត្រួតពិនិត្យតាមដានការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស របស់លេខាធិការដ្ឋាននៃ គណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សខេត្តសៀមរាប (គ.ខ.ប.ជ)

https://www.facebook.com/deputygovernoryousophear 26-11-2020

នៅព្រឹកថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០២០ លេខាធិការដ្ឋាននៃគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សខេត្តសៀមរាប (គ.ខ.ប.ជ) បានរៀបចំកិច្ចប្រជុំប្រចាំខែវិច្ឆិកា ឆ្នាំ២០២០ ក្រោមកិច្ចដឹកនាំរបស់ លោកស្រី យូ សុភា អភិបាលរងខេត្ត និងជាប្រធានលេខាធិការដ្ឋាន គ.ខ.ប.ជ ខេត្តសៀមរាប ព្រមទាំងមានការអញ្ជើញចូលរួមពីលោក លោកស្រី សមាជិក សមាជិកា លេខាធិការដ្ឋាន គ.ខ.ប.ជ ពីមន្ទីរអង្គភាពពាក់ព័ន្ធ ព្រមទាំងតំណាងអង្គការ ដៃគូពាក់ព័ន្ធសរុប៥៤នាក់ ស្រី ៣៤នាក់។

អង្គប្រជុំបានពិនិត្យទៅលើកំណត់ហេតុ និងត្រួតពិនិត្យលើផែនការដែលអង្គប្រជុំបានដាក់ចេញកាលពីកិច្ចប្រជុំប្រចាំខែតុលា ឆ្នាំ២០២០ កន្លងទៅ និងបានពិភាក្សាលើបញ្ហាប្រឈម មួយចំនួន ដែលក្រុមការងារបានអនុវត្តសកម្មភាពប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស តាមគ្រប់រូបភាព ដោយមានការចូលរួមសហការពីគ្រប់ភាគីពាក់ព័ន្ធទាំងអស់ នៅតាមមូលដ្ឋានភូមិ ឃុំ ដូចជា ធ្វើការផ្សព្វផ្សាយច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ច្បាប់ពាក់ព័ន្ធនានា គោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព វេទិកាសាធារណៈ ច្បាប់ទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារនិងកិច្ចការពារជនរងគ្រោះ ការធ្វើចំណាកស្រុកដោយសុវត្ថិភាព ស្ប៉តអប់រំ ការផ្សាយតាមវិទ្យុទូរទស្សន៍ ជាដើម។ល។ បន្ថែមពីនេះ ក៏មានការស៊ើបអង្កេត និងបង្ក្រាបបទល្មើស ដើម្បីយកទៅផ្តន្ទាទោសតាមនីតិវិធីច្បាប់បានរាល់ករណីផងដែរ ពិសេសការស្រាវជ្រាវស្វែងរកចាប់និងឃាត់ខ្លួនមេខ្យល់ ។

នៅក្នុងកិច្ចប្រជុំនេះផងដែរ ក៏បានលើកយកបញ្ហាជាច្រើនមកពិភាក្សា ដើម្បីស្វែងរកដំណោះស្រាយរួមគ្នាសម្រាប់ការពារជនរងគ្រោះ និងងាយរងគ្រោះ ដោយអំពើហិង្សាទាក់ទងនឹងយេនឌ័រ ឬការរំលោភបំពានផ្សេងៗ ដែលពាក់ព័ន្ធទៅនឹងច្បាប់ស្តីពី ការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ។

# ថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ២០២០

## នារីខ្មែរ ៨ នាក់ ត្រូវបានសង្គ្រោះពីព្រំដែនវៀតណាម-ចិន ពេលមេខ្យល់កំពុងនាំឆ្លងដែន

https://www.postkhmer.com/ ឃុត សុភចរិយា | Publication date 27 November 2020 | 14:00 ICT

**ភ្នំពេញ៖** ស្ថានឯកអគ្គរាជទូតនៃព្រះរាជាណាចក្រកម្ពុជាប្រចាំប្រទេសវៀតណាម កាលពីថ្ងៃទី ២៥ ខែ វិច្ឆិកា ឆ្នាំ ២០២០ បានសហការសម្របសម្រួលជាមួយអាជ្ញាខេត្តការ៉វបាង បញ្ជូននារីខ្មែរ ៨ រូប ត្រឡប់មកកម្ពុជាវិញ បន្ទាប់ពីត្រូវបានចាញ់បោកមេខ្យល់លួចឆ្លងដែនទៅកាន់ប្រទេសចិន ដោយឆ្លងកាត់ប្រទេសវៀតណាម ដោយខុសច្បាប់។ យោងតាមសេចក្ដីជូនដំណឹងរបស់ស្ថានឯកអគ្គរាជទូតកម្ពុជាប្រចាំប្រទេសវៀតណាម ចុះថ្ងៃទី ២៥ ខែ វិច្ឆិកា ឆ្នាំ ២០២០ ដែល ភ្នំពេញ ប៉ុស្ដិ៍ ទទួលបានកាលពីថ្ងៃទី ២៦ វិច្ឆិកា ថា នារីខ្មែរទាំង ៨ នាក់នោះ មានទីលំនៅក្នុងខេត្តកណ្ដាល កំពង់ចាម បន្ទាយមានជ័យ និងរាជធានីភ្នំពេញ។ ក្នុងចំណោមនារីទាំង ៨ នាក់ មាន ៤ នាក់ជាអនីតិជន។ សេចក្ដីជូនដំណឹងនោះបានបញ្ជាក់ថា៖ «ពួកនាងត្រូវបានឆបោកនាំពីកម្ពុជា» នៅថ្ងៃទី ២៥ ខែតុលា និងថ្ងៃទី ០៧ ខែ វិច្ឆិកា ឆ្នាំ ២០២០ តាមផ្លូវលំ ក្បែរច្រកទ្វារអន្តរជាតិ បាវិត-ម៉ុកបាយ ឆ្ពោះទៅព្រំដែនវៀតណាម-ចិន នៃខេត្តការ៉វបាង ហើយត្រូវបានអាជ្ញាធរខេត្តការ៉វបាង ជួយសង្គ្រោះបាននៅថ្ងៃទី ០៦ និង ថ្ងៃទី ១០ ខែ វិច្ឆិកា ឆ្នាំ ២០២០ នៅចំណុចព្រំដែនវៀតណាម-ចិន ដែលមានចម្ងាយប្រមាណ ៣៧០ គីឡូម៉ែត្រ ពីទីប្រជុំជននៃក្រុងហាណូយ។

ក្រោយពីមានកិច្ចអន្តរាគមន៍សម្របសម្រួលពីស្ថានអគ្គរាជទូតកម្ពុជាប្រចាំប្រទេសវៀតណាម អាជ្ញាធរខេត្តការ៉វបាង នៅថ្ងៃទី ២៥ ខែ វិច្ឆិកា ឆ្នាំ ២០២០ បានសម្រេចបញ្ជូនពួកនាងតាមរថភ្លើងមកកាន់ទីក្រុងហូជីមិញ ដែលតាមគម្រោង នៅវេលាម៉ោង ៥:០០ ព្រឹក ថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ ២០២០ ពួកនាងនឹងមកដល់ទីក្រុងហូជីមិញ ជាទីដែលមានស្ថានអគ្គកុងស៊ុលកម្ពុជា រង់ចាំដើម្បីសម្របសម្រួលការធ្វើដំណើរបន្តទៅច្រកទ្វារព្រំដែនអន្តរជាតិបាវិត-ម៉ុកបាយ។ យ៉ាងណាក៏ដោយ នៅក្នុងសេចក្ដីជូនដំណឹងនោះ ស្ថានអគ្គរាជទូតកម្ពុជាប្រចាំប្រទេសវៀតណាម មិនបានបញ្ជាក់ឲ្យច្បាស់អំពីទិសដៅពិតប្រាកដរបស់ពួកនាងដែលត្រូវទៅនោះទេ ហើយក៏មិនបានបញ្ជាក់ពីមូលហេតុដែលនាំឲ្យពួកនាងត្រូវបានគេបោកបញ្ឆោតពីកម្ពុជានោះដែរ។

លោក កុយ គួង អ្នកនាំពាក្យក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិបានប្រាប់ ភ្នំពេញ ប៉ុស្ដិ៍ ថា គោលបំណងរបស់ក្រុមនារីរងគ្រោះ គឺទៅប្រទេសចិន ដោយឆ្លងកាត់ប្រទេសវៀតណាម។ លោកបានបន្តថា នៅពេលនេះអគ្គកុងស៊ុលកម្ពុជាប្រចាំក្រុងហូជីមិញ នឹងសហការជាមួយអាជ្ញាធរវៀតណាម ជួយសម្រួលស្ត្រីរងគ្រោះ ដើម្បីឆ្លងកាត់ព្រំដែនមកកម្ពុជាវិញ ដោយមានមន្ត្រីសង្គមកិច្ចខេត្តស្វាយរៀងចាំទទួលនៅច្រកព្រំដែន និងអនុវត្តតាមវិធានការរបស់ក្រសួងសុខាភិបាល។

អ្នកស្រី ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស បានប្រាប់ ភ្នំពេញ ប៉ុស្ដិ៍ ថា នៅថ្ងៃទី ២៦ ខែវិច្ឆិកាថា ជាទូទៅជនរងគ្រោះដែលត្រូវបានចាញ់បោកមេខ្យល់នាំពីកម្ពុជាទៅកាន់ប្រទេសវៀតណាម គោលដៅរបស់ពួកគេភាគច្រើន គឺទៅប្រទេសចិន។ ចំណែកមូលហេតុ គឺក្រុមជនរងគ្រោះ ជឿលង់ការបញ្ឆោតរបស់ក្រុមមេខ្យល់ តាមរយៈរូបភាពរៀបអាពាហ៍ពិពាហ៍ក្លែងក្លាយ និងការធានាផ្ដល់ការងារធ្វើនៅតាមផ្ទះ ដែលមានប្រាក់ខែខ្ពស់ជាដើម។ អ្នកស្រីបានបញ្ជាក់ថា៖ «យោងតាមរបាយការណ៍នៃការសិក្សាស្រាវជ្រាវ ជនរងគ្រោះជាស្ត្រីកម្ពុជា ៦០ នាក់ ក្នុងមួយឆ្នាំ ត្រូវបានរកឃើញថា ចាញ់បោកមេខ្យល់នាំយកទៅលក់នៅប្រទេសចិន ហើយត្រូវបានអគ្គកុងស៊ុលកម្ពុជា ប្រចាំប្រទេសចិន សហការជាមួយអាជ្ញាធរចិន ជួយអន្តរាគមន៍បញ្ជូនមកកាន់កម្ពុជាវិញ»។

ចំពោះករណីនារីខ្មែរទាំង ៨ នាក់ ដែលត្រូវបានចាញ់បោកមេខ្យល់នាំពីកម្ពុជាទៅកាន់ព្រំដែនវៀតណាម-ចិន នៃខេត្តកាវបាង និងដែលត្រូវបានបញ្ជូនត្រឡប់មកដល់ច្រកទ្វារព្រំដែនអន្តរជាតិបាវិត-ម៉ុកបាយ នៅព្រៃថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ ២០២០ នោះ ក្រុមការងាររបស់អ្នកស្រី កំពុងសហការជាមួយសមត្ថកិច្ចជំនាញនៃលេខាធិការដ្ឋានគណៈកម្មាប្រយុទ្ធប្រឆាំងការជួញដូរមនុស្សខេត្តស្វាយរៀង មន្ត្រីជំនាញពីក្រសួងសង្គមកិច្ច ក្រសួងសុខាភិបាល និងសមត្ថកិច្ចនគរបាលប្រចាំច្រកទ្វារព្រំដែនអន្តរជាតិបាវិត-ម៉ុកបាយ ដើម្បីទទួលពួកនាងយកទៅធ្វើចត្តាឡីស័ក្តិ ១៤ ថ្ងៃ។ អ្នកស្រីបញ្ជាក់ថា៖ «នៅពេលពួកគាត់មកដល់មន្ទីរសុខាភិបាល នឹងដាក់ឲ្យធ្វើចត្តាឡីស័ក ១៤ ថ្ងៃសិន។ ក្រោយពីបញ្ចប់ការធ្វើចត្តាឡីស័ក្តិ ទើបក្រុមការងារយើងខ្ញុំ អាចដំណើរការសាកសួរពួកនាង នូវព័ត៌មានផ្សេងៗមួយចំនួនបាន»៕

## ពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ១៣៨នាក់

https://www.facebook.com/GDIOfficial 29-11-2020

នៅថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០២០ វេលាម៉ោង ១៥និង០០នាទី ភាគីថៃនៅតែបន្តបិទច្រកទ្វារព្រំដែនអន្តរជាតិ ធង ចម ខេត្តសុរិន្ទ ទល់មុខច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ ជាបណ្ដោះអាសន្ន មិនអនុញ្ញាតឲ្យអ្នកដំណើរ គ្រប់សញ្ជាតិចេញ-ចូល ឆ្លងកាត់ដើម្បីបង្ការនិងទប់ស្កាត់ការរាតត្បាតនៃជំងឺឆ្លង កូវីដ-១៩។ ក្នុងការបិទច្រកនេះ ភាគីថៃបានលើកលែង ទំនិញដែលទទួលបានការអនុញ្ញាត និងអ្នកបើកបររថយន្តដឹកទំនិញដែលទទួលបានការអនុញ្ញាត ព្រមទាំងបានការឆ្លងកាត់ត្រួតពិនិត្យ ដោយសមត្ថកិច្ចទាំងភាគី កម្ពុជា-ថៃ បានត្រឹមត្រូវ និងពលរដ្ឋខ្មែរ ឬពលរដ្ឋថៃ ដែលត្រូវវិលត្រឡប់ចូលប្រទេសរៀងៗខ្លួន។ ចំណែកឯពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ១៣៨នាក់ ស្រី ៥៥នាក់៕

## ពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ១២០នាក់

https://www.facebook.com/GDIOfficial 28-11-2020

នៅថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០២០ វេលាម៉ោង ១៥និង០០នាទី ភាគីថៃនៅតែបន្តបិទច្រកទ្វារព្រំដែនអន្តរជាតិ ធង ចម ខេត្តសុរិន្ទ ទល់មុខច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ ជាបណ្ដោះអាសន្ន មិនអនុញ្ញាតឲ្យអ្នកដំណើរ គ្រប់សញ្ជាតិចេញ-ចូល ឆ្លងកាត់ដើម្បីបង្ការនិងទប់ស្កាត់ការរាតត្បាតនៃជំងឺឆ្លង កូវីដ-១៩។ ក្នុងការបិទច្រកនេះ ភាគីថៃបានលើកលែង ទំនិញដែលទទួលបានការអនុញ្ញាត និងអ្នកបើកបររថយន្តដឹកទំនិញដែលទទួលបានការអនុញ្ញាត ព្រមទាំងបានការឆ្លងកាត់ត្រួតពិនិត្យ ដោយសមត្ថកិច្ចទាំងភាគី កម្ពុជា-ថៃ បានត្រឹមត្រូវ និងពលរដ្ឋខ្មែរ ឬពលរដ្ឋថៃ ដែលត្រូវវិលត្រឡប់ចូលប្រទេសរៀងៗខ្លួន។ចំណែកឯពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ១២០នាក់ ស្រី ៥៤នាក់ និងបានទទួលពលរដ្ឋខ្មែរចំនួន ០១នាក់ ពីភាគីថៃ ពាក់ព័ន្ធនឹងបទលួចចូលកាប់ឈើខុសច្បាប់ ក្នុងទឹកដីប្រទេសថៃ៕

## ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិប៉ោយប៉ែត បានទទួលពលករខ្មែរ ឆ្លងដែនខុសច្បាប់ ដែលអាជ្ញាធរថៃបញ្ជូនមក មានចំនួន ៣៦នាក់

https://www.facebook.com/GDIOfficial 27-11-2020

ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិប៉ោយប៉ែត នាថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០២០ បានទទួលពលករខ្មែរឆ្លងដែនខុសច្បាប់ ដែលអាជ្ញាធរថៃបញ្ជូនមក មានចំនួន ៣៦នាក់ ស្រី១៤នាក់។ ចំពោះពលករខាងលើ ត្រូវបានកម្លាំងនគរបាលប៉ុស្តិ៍ ធ្វើការអប់រំណែនាំ បន្ទាប់មកប្រគល់ជូនក្រុមការងារ ទទួលពលករមជ្ឈមណ្ឌលសំចតប៉ោយប៉ែត ដើម្បីធ្វើការបន្ត។ ជាមួយគ្នានេះដែរ អាជ្ញាធរថៃនៅតែបន្តបិទច្រកទ្វារព្រំដែន មិនទាន់បើកឱ្យអ្នកដំណើរចេញ-ចូលឆ្លងកាត់នៅឡើយ ចំពោះអ្នកជំងឺសង្គ្រោះបន្ទាន់ និងរថយន្តដឹកទំនិញធន់ធំ ដំណើរការជាធម្មតា៕

## ពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ១០២នាក់

https://www.facebook.com/GDIOfficial 27-11-2020

នៅថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០២០ វេលាម៉ោង ១៥និង០០នាទី ភាគីថៃនៅតែបន្តបិទច្រកទ្វារព្រំដែនអន្តរជាតិ ផង ចម ខេត្តសុរិន្ទ ទល់មុខច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ ជាបណ្តោះអាសន្ន មិនអនុញ្ញាតឲ្យអ្នកដំណើរ គ្រប់សញ្ជាតិចេញ-ចូល ឆ្លងកាត់ ដើម្បីបង្ការនិងទប់ស្កាត់ការរាតត្បាតនៃជំងឺឆ្លងកូវីដ-១៩។ ក្នុងការបិទច្រកនេះ ភាគីថៃបានលើកលែង ទំនិញដែលទទួលបានការអនុញ្ញាត និងអ្នកបើកបររថយន្តដឹកទំនិញដែលទទួលបានការអនុញ្ញាត ព្រមទាំងបានការឆ្លងកាត់ត្រួតពិនិត្យ ដោយសមត្ថកិច្ចទាំងភាគី កម្ពុជា-ថៃ បានត្រឹមត្រូវ និងពលរដ្ឋខ្មែរ ឬពលរដ្ឋថៃ ដែលត្រូវវិលត្រឡប់ចូលប្រទេសរៀងៗខ្លួន។ចំណែកឯពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ១០២នាក់ ស្រី ៤២នាក់៕

## លោកជំទាវ ឯក សុវណ្ណភារៈ អភិបាលរងខេត្តស្វាយរៀង បានធ្វើការទទួលពលរដ្ឋខ្មែរចំនួន ១៣នាក់ ពីតំណាងមន្ទីរសង្គមកិច្ចក្រុងហូជីមិញ ប្រទេសវៀតណាម

https://www.facebook.com/GDIOfficial 27-11-2020

នៅថ្ងៃសុក្រ ១២កើត ខែមិគសិរ ឆ្នាំជូត ព.ស.២៥៦៤ ត្រូវនឹងថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០២០ វេលាម៉ោង ០៩និង០០នាទី ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិបាវិត បានពិនិត្យឃើញ លោកជំទាវ ឯក សុវណ្ណភារៈ អភិបាលរងខេត្តស្វាយរៀង ដឹកនាំមន្ទីរសង្គមកិច្ចយុទ្ធជន និងយុវនីតិសម្បទា ខេត្តស្វាយរៀង សហការជាមួយតំណាងមន្ទីរសង្គមកិច្ចក្រុងហូជីមិញ បានធ្វើការទទួលពលរដ្ឋខ្មែរចំនួន ១៣នាក់។ នគរបាលប៉ុស្តិ៍បានឲ្យដឹងថាពលរដ្ឋខ្មែរទាំង ១៣នាក់នេះ មាន នារីខ្មែរ ០៨នាក់ ដែលបានចាញ់បោកមេខ្យល់ នាំយកទៅជួញដូរនៅប្រទេសចិន និងពលរដ្ឋខ្មែរ ០៥នាក់ ស្រី ០២នាក់ រកស៊ីមិនស្របច្បាប់។ ដោយយោងតាមសេចក្តីប្រកាស របស់ក្រសួងសុខាភិបាលក្រុមការងារចត្តាឡីស័ក បានអនុវត្តវិធានការរបស់ក្រសួង៕

## តម្រួតថៃ ឃាត់ខ្លួនពលរដ្ឋខ្មែរចំនួន ៦ នាក់ តែងកាយជាព្រះសង្ឃដើរបិណ្ឌបាត

http://kampucheathmey.com/ November 28, 2020 Dy Bunnar

ជនជាតិខ្មែរចំនួន ៦ នាក់ ដែលមានគ្រងស្បង់ជីពរ ជាព្រះសង្ឃ ត្រូវបានកម្លាំងតម្រួតថៃ តាមស្រាវជ្រាវពេញមួយព្រឹក រហូតឈានដល់ការឃាត់ខ្លួន ខណៈដែលសង្ឃទាំងអស់នេះ កំពុងនិមន្តបិណ្ឌបាតនៅតាមតំបន់នានា ក្នុងក្រុងបាងកក ។

យោងតាមការផ្សាយរបស់សារព័ត៌មានថៃមួយបានបញ្ជាក់ថា ការឃាត់ខ្លួនសង្ឃទាំង ៦ អង្គនេះ គឺបានធ្វើឡើងកាលពីវេលាម៉ោង ១០ព្រឹក ថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ២០២០ ត្រង់ចំណុចព្រៃមួយកន្លែងក្បែរផ្លូវ បាងណាត្រាត ជិតផ្លូវចូលទៅព្រលានយន្តហោះ សុវណ្ណភូមិ កណ្តាលទីក្រុងបាងកក ប្រទេសថៃ។ ព័ត៌មានបានបន្តថា នៅមុនពេលឃាត់ខ្លួនគឺតម្រួតថៃបានតាមប្រមាញ់តាំងពីព្រឹក រហូតដល់ម៉ោង ១០ ទើបប្រទះឃើញព្រះសង្ឃទាំង ៦ អង្គនិមន្តចូលទៅតាមផ្លូវព្រលានយន្តហោះ ទើបសមត្ថកិច្ចថៃបានដេញរហូតដល់កន្លែងស្នាក់នៅរបស់ព្រះសង្ឃទាំងនោះតែម្តង គឺស្ថិតក្នុងព្រៃមួយកន្លែង ដោយនៅទីនោះមានសម្ភារៈមួយចំនួនដូចជា អង្រឹងនិង ខ្នមសម្រាប់ស្នាក់នៅ មានសម្ភារៈចានឆ្នាំង និងស្បៀងអាហារមួយចំនួន ដូចជាត្រីខ កំប៉ុងជាដើម ។

ស្ថិតក្នុងស្បង់ជីពរដែលកំពុងគ្របដណ្តប់លើរាងកាយ តម្រួតថៃបានបញ្ជាអោយព្រះសង្ឃទាំងនោះសូត្រធ៌មទៅតាមទំនៀម ទំលាប់សាសនា ប៉ុន្តែមានតែមួយចំនួនតូចតែប៉ុណ្ណោះដែលចេះសូត្រ ដោយឡែកមួយចំនួនទៀតមិនមានចេះធ៌មអារ្យអ្វីនោះទេ ដោយគ្រាន់តែដើរៗតាមគេដើម្បីបិណ្ឌបាតយកបច្ច័យតែប៉ុណ្ណោះ ដែលជាសទ្ធាជ្រះថ្លារបស់ពលរដ្ឋ ។ បច្ចុប្បន្នព្រះសង្ឃក្លែងក្លាយទាំង ៦ អង្គ ត្រូវបានកម្លាំងតម្រួតបញ្ជូនទៅអោយខាងធម្មការផ្សើក និងបញ្ជូនខ្លួនទៅតាមផ្លូវច្បាប់ ដោយសារបានលបឆ្លងដែនចូលទៅក្នុងទឹកដីថៃ ដោយគ្មានច្បាប់អនុញ្ញាត និងម៉្យាងទៀតបានតែងកាយបន្លំខ្លួនជាព្រះសង្ឃ ៕ អត្ថបទ៖ សោ និយមរ័ត្ន